ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សុន សេន
- ប៉ាកវិកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

លេខ១០ ខែតុលា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១០ ខែតុលា ឆ្នាំ២០០០

## មាតិកា


◆ សំបុត្រៈ ត្រីងៀតឆ្អៀតពង........................................ ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់អ្នកទោស សួរ ទូន........................ ២
◆ ប្រវត្តិរូប សុន សេន................................................ ៧
◆តើ សុន សេន ជាខ្មាំងបង្កប់........................................ ៨
◆ ប្រវត្តិរូបសមមិត្ត គង់ ឬ សួង ស៊ីគៀន........................ ១៣
◆ ប្រាក់ ខន និងការសួរសួរចម្លើយនៅមន្ទីរ ស-២១............ ១៦
◆ របណ្ដាសាកសពប្រល័យពូជសាសន៍ខេត្តបន្ទាយមានជ័យ.......... ២០
◆ ខួបឆ្នាំទី២៥ នៃកំណើតបក្សកុម្មុយនិស្តកម្ពុជា.................. ២៣
◆ លក្ខណៈសម្បត្តិ១០“ខ”របស់បក្ស.................................. ២៤

**ផ្នែកប្រវត្តិសាស្ត្រ**

◆ សម្លេងពីមន្ទីរស-២១................................................ ២៧

**ផ្នែកច្បាប់**

◆ គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់................ ៣១
◆ វិធីប្លូនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្ម........................ ៣៤
◆ ទោសភាពនិងទង្វើដែលទាក់ទងនឹងទោសភាព........................ ៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ទស្សនៈខ្មែរក្រហមចំពោះទឹកដីកម្ពុជាក្រោម........................ ៤០
◆ ជនដៃដល់ ឬ ជនរងគ្រោះ? ...................................... ៤៣
◆ ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ............................ ៤៦
◆ ស្នាដៃតាម៉ុក.......................................................... ៥១
◆ ព្រលឹងវិលវល់........................................................ ៥៣

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការសម្លាប់រង្គាលនៅបឹងទន្លេសាប.................................. ៥៥
◆ រឿងខ្ញុំក្នុងថ្ងៃជម្លៀស................................................ ៥៧

**សិល្បៈខ្មែរក្រហមៈ**

កំណាព្យៈ មហាចលនាសម្រុកធ្វើស្រែវស្សា........................ក្របក្រោយ




កម្មាភិបាលថ្នាក់ក្រោម



ប៉ុល ពត



សុន សេន



អៀង សារី


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**វាគ្មិនលេខនេះ** ចាយ៉ា វ៉ាមដី, អេលីហ្សាប៉ែត វ៉ាន់ស្កាក់, គ្រេក អ៊ិចឆេសាន់, យ៉ន វ៉ាន់ គ្រីនផិន, ដេវីត ឆេនដល័រ, យិមស៊ុត វ៉ាណាជិត, អៀ ម៉េងទ្រី, ស្ទីវ ហេឌ័រ, អ៊ីសា ខស្មាន, លឹម តី **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃឹម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

***សំបុត្រ:***

# ត្រីខៀតឆ្លៀតពង

ទឹកជំនន់បានស្រកពីភូមិស្រុកស្រែចម្ការ ហើយបាននាំយកជាមួយនូវព្រលឹងដូនតាវិលត្រឡប់ទៅកាន់ភពរបស់គាត់រៀងៗខ្លួនវិញ ។ រឿងទឹកជំនន់គឺជារឿងពិត រឿងព្រលឹងដូនតាឬរឿងប្រេតគឺជាជំនឿរបស់ប្រជាជនខ្មែរ ។ ផលវិបាកពីទឹកជំនន់ត្រូវបានប្រជាជនខ្លួនឯង ព្រមទាំងភាពឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជា គណបក្សនយោបាយនានា អង្គការក្រៅរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិ កំពុងដោះស្រាយ ។ ភាពប្រក្រតីនៅតាមភូមិដ្ឋាននឹងកើតមានសាជាថ្មីឡើងវិញ ព្រោះជីវិតមនុស្សជាមូលដ្ឋាននៃការអភិវឌ្ឍនេះ ។ ទន្ទឹមនឹងគ្នានេះដែរ បញ្ហា អៀង សារី និងមេដឹកនាំខ្មែរក្រហមដទៃទៀតដែលមិនបានបង្កឲ្យមានទឹកជំនន់ ប៉ុន្តែដែលបានកម្ទេចជីវិតមនុស្សរាប់លាននាក់ និងដាក់ប្រជាជនទូទាំងប្រទេសឲ្យធ្វើជាទាសករដើម្បីកសាងជាតិ មិនទាន់រសាត់ផុតពីយើងទាំងអស់គ្នាដែលជាជនរងគ្រោះ ហើយក៏ពុំទាន់ត្រូវបានវិនិច្ឆ័យតាមបទដ្ឋានច្បាប់ណាមួយនៅឡើយទេ ។ បច្ចុប្បន្ននេះហាក់ដូចជាកំពុងតែរីកដុះដាលនូវភាពមិនច្បាស់លាស់មួយស្តីអំពីករណីរបស់ អៀង សារី និងពង្រាងច្បាប់ខ្មែរក្រហម ។ ក្រុមចរចារបស់កម្ពុជាស្តីពីតុលាការខ្មែរក្រហមក៏ហាក់ដូចជាមិនទាន់បាន «ឆ្លើយតបទៅនឹងបញ្ហា» ជាដុំកំភួននិងជាផ្លូវការនៅឡើយដែរ ។

### ការលើកលែងទោស អៀង សារី



អៀង សារី

ប្រជាជនកម្ពុជាគួរកត់សម្គាល់ថា ច្បាប់និងភស្តុតាងមានគ្រប់គ្រាន់ហើយ ប៉ុន្តែនៅខ្វះ«ចេតនា» (ដែលមានន័យខុសគ្នានឹង«ឆន្ទៈ») ផ្នែកនយោបាយតែប៉ុណ្ណោះក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ ឆ្លៀតឱកាសនេះ អៀង សារី កំពុងតែប្រឹងប្រែងធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីធ្វើឲ្យការលើកលែងទោសរបស់ខ្លួនមានភាព «ឥតខ្ចោះ» ។ ខ្ញុំគិតថាការផ្តល់នូវការលើកលែងទោសដល់ អៀង សារី ពីបទឧក្រិដ្ឋកម្មសង្គ្រាម ឬអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងមិនឲ្យចូលរួមក្នុងឆាកនយោបាយនៅក្នុងប្រទេសកម្ពុជាអស់មួយជីវិតដោយហេតុផលនយោបាយគឺប្រសើរជាងយកហេតុផលថាគ្មានភស្តុតាងនិងច្បាប់គ្រប់គ្រាន់សម្រាប់ធ្វើការកាត់ទោស ។

ក្នុងការដែលឃើញ អៀង សារី ដែលជាមេដឹកនាំខ្មែរក្រហមម្នាក់ «**ដើរហើរសេរី**» ពាសពេញស្រុកខ្មែរ និងប្រហែលជាកំពុងព្យាយាមចេញទៅបរទេសដោយគ្មាននរណាចាប់ឬឃុំឃាំងហើយនៅក្នុងពេលជាមួយគ្នាដដែលនេះមើលឃើញកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដូចជា ឈូក រិន ឌុច ឬ នួន ប៉ែត ដែលត្រូវបានដាក់ទោសជាប់គុកអស់មួយជីវិត គឺជារឿងមួយដែលមិនយុត្តិធម៌ទាល់តែសោះ ។ ខណៈដែល អៀង សារី ធ្វើពើដូចជាមិនយល់ពីប្រវត្តិសាស្ត្រនិងការពិត និងសម្តែងឲ្យឃើញថាមានបំណងល្អចំពោះសង្គមកម្ពុជា គឺមានន័យថាការស្រាវជ្រាវរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជាពិតប្រាកដមួយបានចាប់ផ្តើមហើយ ។ ការនេះត្រូវតែធ្វើឲ្យបានច្បាស់ទាំងអស់គ្នាសម្រាប់ប្រជាជនកម្ពុជានិងពិភពលោកទាំងមូល ដើម្បីប្រវត្តិសាស្ត្រនិងការយល់ដឹងសម្រាប់មនុស្សជំនាន់ក្រោយ ។

ព្រះមហាក្សត្រខ្មែរបានប្រទានការលើកលែងទោសដល់ អៀង សារី ។ ទាក់ទងដល់ការលើកលែងទោសដល់ អៀង សារី នេះ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៦ មានការឆ្លើយឆ្លងរវាងព្រះមហាក្សត្រជាមួយនឹងលោក ញៀ សេន អគ្គលេខានៃអង្គការលើកលែងទោសអន្តរជាតិដែលមានសេចក្តីថា «...ក្នុងព្រះនាមជាព្រះមហាក្សត្រដែលគោរពតាមរដ្ឋធម្មនុញ្ញ គ្រងរាជ្យតែមិនកាន់អំណាច ខ្ញុំសូមអនុវត្តតាមសហនាយករដ្ឋមន្ត្រីទាំងពីរនៃរាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាលើកលែងទោស

ដល់ អៀង សារី និងបក្សពួក (អតីតខ្មែរក្រហម) ។ ក៏ប៉ុន្តែខ្ញុំសូមទាមទារចំពោះបញ្ហានេះថាគួរតែមានសំឡេងពីរភាគបីនៃសមាជិកសភាគាំទ្រដល់សំណើរបស់នាយករដ្ឋមន្ត្រីទាំងពីររបស់យើងមុនពេលការលើកលែងទោសត្រូវបានយល់ព្រមជាផ្លូវការ» ។ ព្រះមហាក្សត្រក៏បានបន្តទៀតថា «...ប្រសិនបើថ្ងៃណាមួយតុលាការអន្តរជាតិមួយនឹងកើតមានឡើងនៅទីកន្លែងណាមួយដើម្បីជម្រះទោស ប៉ុល ពត អៀង សារី តាម៉ុក ខៀវ សំផន នួន ជា សុន សេន ព្រមទាំងពួកខ្មែរក្រហមយង់ឃ្នងដទៃផ្សេងទៀតនោះ ក្នុងនាមជាពលរដ្ឋកម្ពុជាមួយរូបខ្ញុំសូមគាំទ្រ» ។

ជាការពិតដែលថា អៀង សារី មិនដែលត្រូវបានយកមកកាត់ទោសដោយតុលាការចម្រុះណាមួយជាលក្ខណៈអន្តរជាតិនៅឡើយទេ ។

## ពង្រាងច្បាប់ខ្មែរក្រហម

វាហាក់ដូចជាមានសញ្ញាបញ្ជាក់ថាមានមតិភាគច្រើននៃសមាជិកសភាជាតិកម្ពុជាមានបំណងឲ្យបញ្ហាច្បាប់ខ្មែរក្រហមធ្វើដំណើរទៅមុខឲ្យបានលឿនបំផុត ។ ការយឺតយ៉ាវមកទល់សព្វថ្ងៃនេះប្រហែលដោយសារមកពីក្រុមចរចារបស់កម្ពុជាស្តីពីតុលាការខ្មែរក្រហមមិនទាន់បានបញ្ជាក់ឲ្យបានច្បាស់លាស់លើចំណុចមួយចំនួននៃពង្រាងច្បាប់ខ្មែរក្រហមក៏អាចថាបាន ។ ចំពោះការធ្វើពង្រាងច្បាប់នេះស្តាប់ទៅហាក់ដូចជាគួរឲ្យទុកចិត្ត ប៉ុន្តែធាតុពិតពុំមានជាសាច់ការច្បាស់លាស់ណាមួយជាផ្លូវការនៅឡើយទេ ។ ឥឡូវនេះប្រហែលជាដល់ពេលដែលសមាជិកសភាទាំងអស់ត្រូវសម្តែងឲ្យឃើញពី«ឆន្ទៈនិងចេតនា»របស់ខ្លួនចំពោះពង្រាងច្បាប់ខ្មែរក្រហមនិងការផ្សារទាំងឡាយដែលពាក់ព័ន្ធដល់រឿងតុលាការខ្មែរក្រហម ។ និយាយយ៉ាងដូច្នេះក៏មានន័យដែរថាយើងបានដឹងនិងឮរួចមកហើយអំពីការជជែកវែកញែករកហេតុផលប្រឆាំងនិងគាំទ្ររបស់គណបក្សនយោបាយនានាចំពោះពង្រាងច្បាប់ខ្មែរក្រហម ។ សមាជិកសភាទាំងអស់គួរតែបញ្ចេញគំនិតយោបល់និងជំហររបស់ខ្លួនឲ្យបានច្បាស់លាស់លើបញ្ហាការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងនាមជាអ្នកតំណាងឲ្យរាស្ត្រនិងអ្នកបម្រើរាស្ត្រហើយជាអ្នកដែលរាស្ត្របានប្រគល់សន្លឹកឆ្នោតជូន ។

ភាពយឺតយ៉ាវបន្តបន្ទាប់នៃការពិភាក្សាលើពង្រាងច្បាប់ខ្មែរក្រហមនៅឯសភាជាតិកម្ពុជានេះ បានធ្វើឲ្យអង្គការសហប្រជាជាតិដែលជាផ្នែកមួយសំខាន់ក្នុងការធានាដល់ក្តីសង្ឃឹមដល់ប្រជាជនខ្មែរចំពោះតុលាការខ្មែរក្រហម អស់កម្លាំងនិងអស់ទឹកចិត្តក្នុងការចូលរួមដោះស្រាយនិងស្វែងរកយុត្តិធម៌ពិតប្រាកដមួយជូនដល់កម្ពុជា ។

ប្រសិនបើសមាជិកសភាស្ងាត់ស្ងៀមមិនព្រមចេញវាចាសោះនិងមិនព្រមបញ្ចេញជំហរឲ្យបានច្បាស់លាស់ទេនោះ សមាជិកសភាទាំងអស់គួររៀបចំខ្លួនឲ្យហើយទៅក្នុងការទទួលកំហុសជាប្រវត្តិសាស្ត្រស្តីអំពីការបរាជ័យក្នុងរឿងស្វែងរកយុត្តិធម៌ជូនប្រជារាស្ត្រខ្មែរ ។ **ឆាំង យុ**

# ចម្លើយសារភាពរបស់អ្នកទោស សួរ ទួន

សួរ ទួន ឈ្មោះបដិវត្ត ម៉ៅ មានស្រុកកំណើតនៅភូមិព្រៃចេក ឃុំស្រែចែង ស្រុកស្រែ ក្នុងតំបន់៣៥ ខេត្តសៀមរាប ។ ម៉ៅ ត្រូវអង្គការចាប់ខ្លួនសួរចម្លើយនៅថ្ងៃទី ១៣ ខែឧសភា ឆ្នាំ១៩៧៧ ដោយចោទថាក្បត់អង្គការ ។

យោងតាមឯកសារលេខ J០០២៨៩ ម៉ៅ បានសារភាពថា «ពេលដែលខ្ញុំចូលធ្វើបដិវត្តន៍នោះមានគោលបំណងពីរយ៉ាង ១) ចូលបដិវត្តន៍មានគោលបំណងស៊ីរូងផ្ទៃក្នុងបដិវត្តន៍បំផ្លាញបដិវត្តន៍ ២) ពេលចូលបដិវត្តន៍មានគោលបំណងកសាងកម្លាំងក្បត់នៅក្នុងបដិវត្តន៍ដើម្បីវាយបកមកបដិវត្តន៍ក្នុងពេលដែលកសាងកម្លាំងក្បត់បាន» ។

ក្រោយមកនៅឆ្នាំ១៩៥៩ មានឈ្មោះ ទួន ម្នាក់ទៀត (មិនមែន សួរ ទួន ហៅ ម៉ៅទេ) ជាមេគិញក្បត់របស់ច័ន្ទរង្សី នៅក្នុងឃុំស្រែចែង ជាមួយគ្នាបានទៅបំផុសចលនាក្បត់ថាមានយួនលាក់កាំភ្លើងទុក ហើយមាននារីយួនម្នាក់បានដឹងពីកន្លែងកប់ ។ ការឃោសនាបានឮដល់ច័ន្ទរង្សី ។ ច័ន្ទរង្សី បានឲ្យនារីនោះនាំទៅគាស់យកកាំភ្លើងទាំងនោះ ហើយនឹងផ្តល់រង្វាន់ដល់ជន

ណាដែលបានរកឃើញការកាំភ្លើង ដោយប្រកាសថា«បើនរណាចូលរួមសកម្មភាពក្បត់របស់វាៗនឹងឲ្យប្រាក់ខែម្នាក់៥០០រៀលក្នុងមួយខែ ហើយបើនរណារកកាំភ្លើងឃើញវានឹងឲ្យរង្វាន់ថែមទៀត» ។ ម៉ៅ បានចូលរួមនឹងគេដែរ ពេលចូលរួមនោះមានឈ្មោះឌុល គយ អុន (បដិវត្តន៍កម្ទេច) ជីម ជឹម ឆេង ជីន ទឹម សួត ទី ។ បន្ទាប់ពីចុះឈ្មោះហើយ ទួន (មិនមែន ម៉ៅ) បានចាត់តាំងភារកិច្ច «ទី១រកកាំភ្លើង ទី២ស៊ើបកម្លាំងក្បត់ចាស់ដែលនៅបង្កប់ក្នុងជួរប្រជាជន» ។ ចង្ហាហឿន ជាគ្រូអាយ៉ៃនៅភូមិត្រពាំងវែង ស្រុកជីក្រែង ខេត្តសៀមរាប ជាអ្នកតាមដាននិងក្តាប់ការងារដែរ ។ ការដើរស្វែងរកអាវុធអស់រយៈពេលពីរ-បីខែ ម៉ៅ បានរកឃើញអាគុយពីរគ្រឿង រាយការណ៍ទៅឲ្យ ចន្ទ័រង្សី យករង្វាន់ ។ បន្ទាប់មក ម៉ៅ រាយការណ៍អ្នកបដិវត្តចាស់ម្នាក់ឈ្មោះ ញ៉ែម ខាន់ ឲ្យជាប់គុកអស់ពីរ-បីខែទើបរួច ។

ចម្លើយសារភាពបាននិយាយទៀតថាឆ្នាំ១៩៦១-៦២ ម៉ៅ បានទៅជួបបងម្នាក់ឈ្មោះ សាធ បាននិយាយថាគាត់នឹកដល់ខ្មោចតារបស់គាត់ដែលចូលរួមការងារបដិវត្តន៍ដែរ ប៉ុន្តែគាត់ស្លាប់ទៅហើយ ។ ពាក្យថា«រួមការងារបដិវត្តន៍»ធ្វើឲ្យ ម៉ៅ នឹកឆ្ងល់ហើយបានសួរទៅបង សាធ គាត់ឆ្លើយថា គឺ«ឯងធ្វើរាល់ថ្ងៃឯងឥតដឹងទេ ដូចជារួមការងារបង្កបង្កើនផល រួមគ្នាសាមគ្គីធ្វើសមាគមខ្មោច និងជួយក្នុងពេលមានជំងឺម្តងៗជួយឧបត្ថម្ភគ្នា នេះជារូបភាពជួយការងារគ្នាពេលដែលគ្នាមានធុរៈម្តងៗជាខ្លឹមសារវិញបម្រើនយោបាយ» ។ ពេលត្រឡប់មកវិញ ម៉ៅ រាយការណ៍ទៅ ទួន (មិនមែន ម៉ៅ) ថាអ្នកបដិវត្តចាស់គ្មានទេ មានតែអ្នកបដិវត្តថ្មីៗ ។ ឈ្មោះ ទួន នេះ សួរវិញថា «អ្នកណាបដិវត្តថ្មី» ម៉ៅ បានឆ្លើយ «យើងទាំងអស់គ្នារាល់ថ្ងៃហ្នឹងជារូបភាពយើងជួយគ្នាសម្រាលការងារគ្នា ប៉ុន្តែខ្លឹមសារវិញគឺបម្រើការងារនយោបាយបដិវត្តន៍ខ្លួនឯងនិងធ្វើជាប្រធានដឹកនាំគេផងក្នុងការធ្វើសមាគមខ្មោច» ទួន បានបដិសេធមិនព្រមទទួលស្គាល់នឹងសម្តី ម៉ៅ ។


អ្នកទោសគុកទួលស្លែង

ឆ្នាំ១៩៦៤-១៩៦៨ ចលនាបដិវត្តន៍ចេះតែមានជាបន្តបន្ទាប់ សាធ បានដឹកនាំ ម៉ៅ បំផុសឲ្យប្រឆាំងការហត្ថកម្មនិងការរើអង្ករសរបស់រដ្ឋាភិបាល និងណែនាំឲ្យប្រុងប្រយ័ត្នការពារខ្លួន លាក់ស្រូវអង្ករក្រែងស្រុកមិនស្រួល ម៉ៅ បានរាយការណ៍បន្ត ។ ទួន (មិនមែនម៉ៅ) ចេះតែដេញដោលសួររកមេសំខាន់ៗរបស់បដិវត្តន៍ខាងលើ ។ ម៉ៅ និយាយថា «ខ្ញុំបានសួរទៅគាត់(សាធ) ដែរ គាត់ឆ្លើយសំអាងលើវិទ្យុផ្សាយនៅខេត្តបាត់ដំបងថា មានចលនាបដិវត្តន៍កុប្បកម្មអាវុធរត់ចូលព្រៃ ដូចនេះយើងត្រូវប្រុងប្រយ័ត្នអំពីការប្រឆាំងការហត្ថកម្មនិងការរើអង្ករសរបស់រដ្ឋាភិបាលធ្វើសាលាសកលវិទ្យាល័យនេះជាទីតាំងជាបន្ទាយរបស់ខ្មាំងទេ មិនមែនជារឿងរបស់ប្រជាជនយើងទេ ដូចនេះយើងត្រូវតស៊ូត្រូវប្រឆាំង» ។ ក្នុងចម្លើយបាននិយាយថា ឆ្នាំ១៩៦៨ ខែ២ ថ្ងៃទី២៥ មានកុប្បកម្មមួយបានផ្ទុះឡើង ។ ម៉ៅ បានចូលចលនាកុប្បកម្មនេះ មិត្តប្រេស បានចាត់តាំងធ្វើជានិរសា ។ លុះដល់ ខែ៥-៦ ទួន (មិនមែន ម៉ៅ) ត្រូវអង្គការកម្ទេចចោល ។ ម៉ៅ ត្រឡប់ទៅមូលដ្ឋានវិញ ។

ខែ១០ ឆ្នាំ១៩៦៩ អង្គការតម្រូវឲ្យ ម៉ៅ ទៅធ្វើការនៅមន្ទីររបស់អង្គការរហូតដល់ឆ្នាំ១៩៧០ ហើយអង្គការបានចាត់តាំង តាហឿន ឲ្យទៅទទួលខុសត្រូវនៅទីនោះដែរ ។ តាហឿន ក៏បានទទួលស្គាល់ ម៉ៅ ធ្វើការងារក្បត់ទៀត ។ ក្រោយថ្ងៃរដ្ឋប្រហារ តាហឿន បានចាត់តាំង ម៉ៅ ធ្វើការនៅភូមិក្រសាំងនឹងតាមបណ្តោយផ្លូវជាតិលេខ១៤ ជាមួយមិត្ត កែវ មិត្តសាន រហូតដល់ ខែ១០ ឆ្នាំ១៩៧០ ទើប តាហឿន ហៅឈ្មោះទាំងបី រួច ប្រកាសដកមិត្តកែវ មិត្តសាន ចេញពីមូលដ្ឋានចាស់ទៅអង្គភាពផ្សេង ។ ម៉ៅ ទទួលខុសត្រូវអង្គភាពយោធា តាងៃ ទទួលជាលេខាស្រុក សុខ លេខាឃុំ ។ ម៉ៅ បានរាយការណ៍ប្រាប់ តាហឿន ថាពេលតាឲ្យខ្លួនមកធ្វើការជាមួយមិត្ត កែវ មួយរយៈឥតបានធ្វើអ្វីទាំងអស់ ការងារបដិវត្តន៍ឥតបានធ្វើ ពីព្រោះកម្លាំងទាំងអស់ឋិតលើមិត្ត កែវ និង

មិត្តសាន» តា ហឿន បានប្រាប់ទៅវិញ «ឥឡូវនេះកម្លាំងនៅលើយើងទាំងអស់ហើយខំកសាងឲ្យមែនទែន» ។

ខែ២ ឆ្នាំ១៩៧១ តាហឿន បានជួបម៉ៅ ម្តងទៀត ។ ម៉ៅ បានរាយការណ៍អំពីសភាពការណ៍អង្គភាពនិងឈ្មោះដែលកសាងបានមាន សាធ កម្មាភិបាលអនុសេនាតូច ឈ្មោះ សយ កម្មាភិបាលក្រុម ។ តាហឿន បានណែនាំ ម៉ៅ បន្ថែមថា «មិត្តឯងអង្គការតម្រូវឲ្យអង្គភាពរបស់មិត្តមួយកងអនុសេនាតូចនេះឡើងទៅតំបន់ទាំងអស់នៅដើមខែ៣ខាងមុខនេះ ដូចនេះពេលមិត្តឯងដឹកនាំអង្គភាពទៅតំបន់ខំក្តាប់អង្គភាពរបស់ខ្លួនឲ្យជាប់» និងសហការជាមួយមិត្ត ក្វាង អនុលេខាអនុសេនាធំ ដើម្បីធ្វើសកម្មភាពក្បត់ ។ ក្រោយមក ម៉ៅ បានសុំ តាហឿន ទៅតំបន់៣៥មួយអាទិត្យ ដោយអង្គភាពប្រគល់ឲ្យ សាធ មើលការខុសត្រូវជំនួស ។ ពេលត្រឡប់មកដល់ឃុំផុង ម៉ៅ ទទួលដំណឹងថាអង្គភាពអនុសេនាតូចរបស់ខ្លួនត្រូវកម្មាភិបាលកងអនុសេនាធំតំបន់រំសាយចូលទៅក្នុងអង្គភាពចាស់អស់ ។ ហើយដឹងថាបក្សមានផែនការឲ្យអង្គភាពឡើងធ្វើការវាយឈ្លបមូលដ្ឋាន ម៉ៅ បានដឹកនាំអង្គភាពរួមប្រយុទ្ធបានតែពាក់កណ្តាលផ្លូវត្រឡប់មកកន្លែងវិញ ។ ពេលមកដល់កន្លែងវិញ អង្គការមានផែនការឲ្យអង្គភាពឡើងធ្វើការវាយខ្មាំងប៉ុន្តែត្រូវខ្មាំងវាយសម្រុកបន្តបន្ទាប់ ។ ម៉ៅ បានកសាងកម្លាំងបីនាក់ឈ្មោះសុភី កម្មាភិបាលអង្គភាព មិត្ត បឿន កម្មាភិបាលក្រុម មិត្តលន់ ជាយុទ្ធជនរបស់តំបន់៣៣ ។ ខែ១២ ម៉ៅ ត្រូវកម្មាភិបាលវរសេនាតូចដកឲ្យមកទទួលខុសត្រូវនៅកងអនុសេនាតូចថ្មីមួយទៀតរបស់តំបន់៣៣ ។

នៅខែ៣ ឆ្នាំ១៩៧២ អង្គការបានចាត់ឲ្យទៅកាន់កងអនុសេនាធំមួយកងនៅស្រុក៥៥ អង្គបូរី ។ ឈ្មោះ ហ៊ឹម នៅទីនោះចេះតែនិយាយចុះឡើងអំពីប្រព័ន្ធចាត់តាំង«អំពីការចាត់តាំងវរាងចាស់និងដែលធ្លាប់នៅព្រៃ ឲ្យទទួលខុសត្រូវត្រឹមសមាជិកប៉ុណ្ណោះ ឯមនុស្សថ្មីក្រោយរដ្ឋប្រហារ អុន ចាត់ឲ្យទទួលលេខាស្រុក ឬឃុំ» ។ ពេលនោះ ម៉ៅ និងមិត្ត ហ៊ឹម បានមកកាន់មន្ទីរតំបន់ដើម្បីរៀនសូត្រ ប៉ុន្តែត្រូវ អុន ឲ្យត្រឡប់ទៅទទួលជាអនុលេខាស្រុក៥៦វិញ ។ ម៉ៅ នៅមន្ទីរតំបន់ចំនួនពីរ-បីថ្ងៃក៏ឡើងមកជួបតាហឿន ។ តាហឿន និយាយថា «គាត់រៀនលើកនេះ ជ្រះស្រឡះលែងគិតគូរពីរឿងចាស់ថ្មីទៀតហើយឲ្យតែគេប្រគល់ឲ្យធ្វើត្រូវតែធ្វើ ឯរឿងយើងបន្តទៅទៀត» ។ ម៉ៅ បានរាយការណ៍អំពីភារកិច្ចដែល អុន បានទៅក្តាប់កងចល័តស្តាប់ចប់ តាហឿន បានណែនាំថា «រឿងយើងគ្មានអ៊ីទេ ពេលទៅដល់កន្លែងណាធ្វើសកម្មភាពកន្លែងនោះកសាងកម្លាំងក្បត់នៅក្នុងអង្គភាព ដូចនេះការងារក្បត់របស់យើងត្រូវតែបន្តទៅទៀត» ។ មួយថ្ងៃបន្ទាប់ពីតា១៥(តាម៉ុក យោងតាមសម្តីរបស់យាយ គល់ មី ប្អូនជីដូនមួយរបស់ តាម៉ុក បាននិយាយថា តាម៉ុកមានរហស្សនាមថា«តា១៥» ព្រោះគាត់កើតនៅខេត្តតាកែវ ដែលមានលេខកូដ១០៥) បានហៅកងរបស់ភាគប្រចាំការនៅខាងត្បូងផ្លូវជាតិលេខ៤មកប្រជុំដកពិសោធន៍សមរភូមិ ស្រាប់តែមានសំបុត្រអនាមិកមួយ ។ ក្នុងសំបុត្រនោះបាននិយាយអំពីទំនាស់ភារកិច្ចនាទីចាស់ថ្មី ម៉ៅ ក៏រាយការណ៍ទៅ តា១៥ ដើម្បីលាងខ្លួនកុំឲ្យគេចាប់អារម្មណ៍ខ្លួនជាមួយ តាហឿន ។ តាហឿន ត្រូវតា១៥ចាប់ ។

ខែ២ ឆ្នាំ១៩៧៣ អង្គការបានដក ម៉ៅ ឲ្យទៅវាយខ្មាំងជាមួយអង្គភាព ។ វាយចប់អង្គភាពបានឆ្លងមកកាន់ត្រើយខាងកើតផ្លូវជាតិលេខ២ រៀបចំកងវរសេនាធំ ។ ពេលរៀបចំកម្លាំងកងវរសេនាធំហើយបក្សមានផែនការវាយខ្មាំងនៅចន្លោះផ្លូវជាតិលេខ៣-៤ អង្គភាពសម្រេចបានផែនការទី១ ផែនការបក្សទី២បានទប់ទល់ខ្មាំងអស់ពេលមួយអាទិត្យ ពេលនោះគ្រាន់តែព្ទសួរ«មិនទាន់បានប្រយុទ្ធផង អង្គភាពនេះមានផែនការបំផ្លាញផែនការតាមផ្លូវជាតិលេខ៤ បើកឲ្យខ្មាំងវាយយកផ្លូវជាតិលេខ៣ ។ តែផែនការនេះសម្រេចមិនបានមូលហេតុ «មិនសម្រេចនេះមកពីមានទស្សនៈគោលជំហរប្រឆាំងនឹងបក្ស»អ្នកអនុវត្តផែនការមានមិត្តសោម កែវ សាវឿន មិត្តឈឺន និងម៉ៅ ។

ឆ្នាំ១៩៧៤ បក្សមានផែនការថ្មីវាយសមរភូមិក្រុងភ្នំពេញ បក្សបានហៅកម្មាភិបាលទាំងអស់ទៅរៀនសូត្រដើម្បី«ជ្រះស្រឡះ»មុនពេលទៅកាន់អង្គភាព ។ តាមមុខសញ្ញានីមួយៗភារកិច្ចមានពីរ «ទី១វាយបុកជាមុខសញ្ញាស្រួច ទី២ភារកិច្ចការពារ» ដែលកងវរសេនាតូច១២២ មានភារកិច្ចវាយបុកជាមួយអង្គភាពផ្សេងទៀត ។ ម៉ៅ ទទួលមុខសញ្ញាផ្សេងធ្វើការប្រឆាំងនឹងផែនការបក្សម្តងៗ រីឯខ្សែរយៈទាក់ទងធ្វើសកម្មភាព

ក្បត់នៅសមរភូមិខាងលើគឺ «សោម ដឹកនាំ ខាងក្រោមមាន សំអុន សេនាធិការកងពលសហការធ្វើសកម្មភាពក្បត់នៅក្នុងសមរភូមិកាលពីឆ្នាំ១៩៧៣-៧៤» ។ ឆ្នាំ១៩៧៥ ផែនការវាយរំដោះក្រុងភ្នំពេញពេលនោះអង្គភាពកងពល១១មានភារកិច្ចការពារដងទន្លេបាសាក់ ឯអង្គភាពផ្សេងវាយនៅមុខសញ្ញាសំខាន់ផ្សេងទៀត ។ ថ្ងៃទី១ ខែ១ ឆ្នាំ១៩៧៥ ចាប់ផ្ដើមផ្ទុះកាំភ្លើងនៅជុំវិញភ្នំពេញនិងដងទន្លេមេគង្គ អង្គភាពរបស់កងពលវាយបានជ័យជម្នះជាបន្តបន្ទាប់ ។ ដោយឡែកកងពល១១ដែលមានភារកិច្ចការពារដងទន្លេបាសាក់មិនត្រឹមតែការពារមិនបានទេធ្វើឲ្យខ្មាំងយក «វត្តឈូកលាប» បាន ដែលវត្តនោះរំដោះតាំងពីឆ្នាំ១៩៧៣ម៉្លេះ ។ កម្មាភិបាលដែលធ្វើសកម្មភាពប្រឆាំងសមរភូមិទន្លេបាសាក់ «១)សមមិត្ត សោម ជាមេដឹកនាំ ២)មិត្តសំអុន ជាសេនាធិការជាអ្នកចាត់ចែងធ្វើសកម្មភាព ៣)តូនឹម នៅវរសេនាធំសហការជាមួយវរសេនាតូច១២៤ មានមិត្ត ស្រេង មិត្តគា មិត្តមាន់៤ ហឿង វរសេនាតូចសាវីន និង ម៉ៅ វរសេនាធំសហការចលនាធ្វើសកម្មភាពប្រឆាំងនឹងផែនការសមរភូមិរបស់បក្សនៅឆ្នាំ១៩៧៥» ។ ខែ៣ឆ្នាំដដែលនេះ កងពល១២បានត្រឡប់មកទន្លេមេគង្គមកជួយកងពល១១រុញខ្មាំងអស់ពីកោះអន្លុងចិនពីវត្តសិត្បូដល់ព្រែកតាំហុន ពោធិសាញ ។ ម៉ៅ បានចូលរួមប្រយុទ្ធជាមួយកងពល១២ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម៉ៅ ត្រូវរបួសដេកមន្ទីរពេទ្យអស់ជាងមួយខែ ។ ពេលចេញពីមន្ទីរពេទ្យ ម៉ៅ បានឲ្យនិរសាជូនមកជួបឈ្មោះ ឈឺន នៅកងពល៨១១ ដើម្បីណែនាំបន្ថែម «អំពីការធ្វើសកម្មភាពក្បត់ឲ្យខិតខំអនុវត្ត ហើយកសាងកម្លាំងក្បត់ឲ្យបានជាខ្សែសង្វាក់» បន្ទាប់ពីណែនាំហើយ ម៉ៅ បានត្រឡប់ទៅសម្រាកនៅពេទ្យ១៧វិញ រង់ចាំមិត្ត សោម ប្រាប់ពីកម្លាំងក្បត់ឡើងវិញ ។ ចម្លើយនោះនិយាយទៀតថា ម៉ៅ បានហៅកម្មាភិបាលក្បត់មកណែនាំឲ្យធ្វើសកម្មភាពប្រឆាំងនឹងបក្សមិនឲ្យរីកចំរើននូវផែនការដឹកប្រឡាយខាងលិចខេត្តកំពង់ស្ពឺ ដោយបំផុសថា «ទី១ឲ្យចលនាយុទ្ធជនរត់ចោលអង្គភាព ទី២ចលនាដករបបយុទ្ធជនដែលអង្គការកំណត់ ដើម្បីឲ្យយុទ្ធជនឈឺថយកម្លាំងពលកម្ម» នៅពេលដែលដាក់ផែនការឃើញថា


ទារុណកម្មលើអ្នកទោសនៅគុកទួលស្លែង(ស-២១)

«ផែនការនេះមានប្រសិទ្ធភាពយុទ្ធជនរត់ចោលជួរជាបន្តបន្ទាប់ មួយផ្នែកឈឺជាប់ជាហូរហែ»។ ក្រៅពីការផ្សារបំផុស ម៉ៅ កសាងកម្លាំងក្បត់ពីរនាក់ឈ្មោះ សរិទ្ធ យឿន សឹង និង ហេង។

ឆ្នាំ១៩៧៦ សោម បានប្រាប់ ម៉ៅ ឲ្យរៀបចំកម្លាំងក្បត់ឡើងវិញ(ពីមុនត្រូវបានរំសាយ) ត្រៀមធ្វើសកម្មភាពក្នុងពេលខាងមុខ។ បន្ទាប់មក ម៉ៅ បានរាយការណ៍ពីកម្លាំងដែលរៀបចំ ចូលទៅក្នុងកងកាំភ្លើងធំមាន គត់ ផាន ប៊ួយ សែម គ្រោះ ថល ភាព ចយ សួន ដែលត្រូវបានបញ្ចូលទៅក្នុងកងកាំភ្លើងធំត្រៀមធ្វើសកម្មភាព។ សោម បានដាក់ផែនការគឺ«ជាផែនការធ្វើវិច្ឆេទកម្មអុកឡុកថ្ងៃបុណ្យរំឭកខួបថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ដែលត្រូវធ្វើនៅក្នុងខែ៤-៧៦ ខាងមុខនេះ ផែនការនេះគ្រាន់តែធ្វើប្រឆាំងនឹងផែនការបុណ្យរបស់បក្សដើម្បីកុំស្ងាត់ស្ងៀមទៅបានធ្វើយ៉ាងម៉េចឲ្យវាចលាចលក្នុងពេលកំពុងបុណ្យផែនការនេះគ្រាន់តែសាកមើលទេ តើធ្វើបានឬមិនបាន»។ មិត្ត សារ៉ន បានរៀបចំកម្លាំងអនុសេនាធំ៤នាក់ត្រៀមនូវផែនការនេះ ប៉ុន្តែត្រូវផ្អាកទៅវិញ។

ខែ៥ ឆ្នាំ១៩៧៦ បក្សបានដាក់ផែនការឲ្យកម្មាភិបាលធ្វើស្រូវស្រាលមួយកងពលឲ្យបាន២០០ទៅ៣០០ហិកតា តាមតម្រូវការអង្គភាព។ ពេលបង្កបង្កើនផល ម៉ៅ ចាប់ផ្តើមបំផ្លាញផែនការរហូតមកដូចជាពេលភ្លៀងចាប់ផ្តើមធ្លាក់ បក្សឲ្យធ្វើស្រូវស្រាល៣ខែ សាបតែរយៈពេល១៥-១៨ថ្ងៃ ពេលនោះទុកដល់ទៅ២០ទៅ២៥ថ្ងៃទើបឲ្យដកស្ទូង។ ហើយកម្មាភិបាល៤នាក់ឈ្មោះ ហ៊ី សួន អ៊ុក ឡុង របស់ សារ៉ន ក៏បានចូលរួមសកម្មភាព ឡុង និង ហ៊ី ត្រៀមធ្វើការនៅពោធិចិនតុង មិត្ត ធី នៅទទួលខុសត្រូវតំបន់៣៣ដែលជាតំបន់ប្រមូលផលមិត្ត អ៊ុក នៅក្នុងវរសេនាតូច១២៨អង្គការដកទុក។

ខែ១ ឆ្នាំ១៩៧៧ មិត្តសោម បានប្រជុំនៅទួលទំពូងផ្ទះមិត្តផល។ សមាជិកដែលចូលរួមមាន មិត្តសំអុន កងកម្មាភិបាល ៨០១ កែវសារឿន កងពល៨០១ សារ៉ន, មិត្ត ផល វរសេនាធំ៥១ កងពល៥០២ គួនីម នៅកងវរជក្រោះ ហឿង កម្មាភិបាល៥១១ បាង ប្រធានមន្ទីរពេទ្យ៩៨ ហេង កម្មាភិបាល វរសេនាតូច៥០៣និង៥០២ និងម៉ៅ។ ផែនការប្រជុំនោះគឺសម្រាប់ឆ្នាំ៧៧ សោម បានលើកឡើងជាចំណុចៗថា «១)ពិនិត្យផែនការធ្វើសកម្មភាពប្រឆាំងផែនការរបស់បក្សបានយ៉ាងណា? ធ្វើមិនបានឬយ៉ាងណា? ២)ពិនិត្យអំពីការផ្សារកម្លាំងក្បត់បានប៉ុន្មានមួយឆ្នាំកន្លងទៅ ផែនការសម្រាប់ឆ្នាំ១៩៧៧ៈ ផែនការធ្វើសកម្មភាពប្រឆាំងនឹងបក្សនិងការកសាងកម្លាំងក្បត់បន្តទៅទៀត»។ បន្ទាប់មកសមាជិកអង្គប្រជុំបានរាយការណ៍អំពីការផ្សារចាស់ដែលបានអនុវត្តមួយឆ្នាំកន្លងទៅ។ សោម បានបន្ថែមទៀត «យើងមានផែនការឆ្នាំ១៩៧៧នេះ គឺយើងត្រូវធ្វើផែនការរបស់យើងវាយយកឲ្យបានសម្រេចផែនការក្បត់របស់យើងដោយធ្វើរដ្ឋប្រហារក្នុងពេលអង្គការមានកម្មវិធីដូចជាបុណ្យរំឭកខួបរបស់បក្ស បុណ្យរំឭកខួបថ្ងៃជ័យជម្នះ១៧ មេសា ៧៥នេះ ដែលយើងត្រៀមកម្លាំងសម្រាប់ធ្វើក្នុងពេលហ្នឹង ពីព្រោះពេលបុណ្យកម្មាភិបាលកងពលមកអង្គការគ្រប់ក្រសួងទាំងអស់មក ពេលមកគ្មានអាវុធទេ មានតែពួកអានៅពីក្រៅ ពេលនេះយើងយកកម្លាំងកងពិសេសមកចាប់ពួកដែលយាមតាមរបងអស់កម្លាំងធំមួយចំនួនចូលលេង និងមួយចំនួនទៅហ៊ុមព័ទ្ធវេទិកា... ពេលបានសម្រេចហើយ នោកន្លែងផ្សេងវាយតែមួយប៉ព្រិចភ្នែកអស់ ហើយយើងប្រកាសតាមវិទ្យុហៅកម្មាភិបាលភាគតំបន់មកដល់ក្រញ៉ឹបមួយព្រឹបឲ្យបានតែម្តង»។ ជាផែនការសរុបប្រជុំនៅទួលទំពូងនេះមានតែពីរទេគឺត្រៀមធ្វើរដ្ឋប្រហារនិងត្រៀមកម្លាំង។ មួយខែក្រោយ ម៉ៅ បានហៅកម្មាភិបាលដែលមានឈ្មោះទាំងប៉ុន្មានមកប្រជុំម្តងទៀតតាមផែនការរបស់មិត្តសោម។ រហូតដល់ថ្ងៃទី១៣ ខែឧសភា ម៉ៅ ក៏ត្រូវអង្គការចាប់ខ្លួន។

នៅក្នុងចម្លើយរបស់ សូរ ទួន ហៅ ម៉ៅ នេះមានបញ្ជីឈ្មោះអ្នកក្បត់មួយចំនួនដែល ម៉ៅ បានសារភាពថាមានជាប់ទាក់ទងជាមួយនឹងខ្លួន ក្នុងចំណោមឈ្មោះទាំងនោះមានឈ្មោះ មិត្ត ហ៊ី និង ឡុង ត្រូវបានគូសប្រអប់បួនជ្រុងសម្គាល់។ នៅទំព័រខាងមុខនៃចម្លើយមានចំណារមួយរបស់ **ខៀវ**(សុន សេន) សរសេរថា «**ជូនសមមិត្ត វឿន សុំសមមិត្តអានឯកសារ អាម៉ៅ ហើយស្រង់ឈ្មោះដែលទាក់ទងនឹងកង៨០១ ស្អែកខ្ញុំជួបសមមិត្តធ្វើការ។ ល្ងាចនេះខ្ញុំជាប់រវល់នៅឡើយ។ សុំរក្សាសម្ងាត់សិន។ ២-៦-៧៧ ខៀវ**»។

**លី សុផល**

## ប្រវត្តិរូប សុន សេន ហៅ ខៀវ ឬបង៨៩


សុន សេន

សុន សេន កើតនៅឆ្នាំ១៩៣០ នៅខេត្តត្រាវិញ ប្រទេសវៀតណាម ។ ប្រពន្ធឈ្មោះ យុន យ៉ាត មានតួនាទីរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងសិក្សាធិការអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្នាំ១៩៤៦ សុន សេន បានចូលរៀននៅសាលាគរុកោសល្យភ្នំពេញ ហើយនៅឆ្នាំ១៩៥០ ទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ។ ចាប់ពីពេលនោះមក សុន សេន ក៏បានក្លាយជាសម្ព័ន្ធមិត្តនិងជាអ្នកយុទ្ធសាស្ត្រយោធារបស់ ប៉ុល ពត ។ ឆ្នាំ១៩៥៦ សុន សេន វិលត្រឡប់ពីប្រទេសបារាំងវិញ ហើយធ្វើជានាយកគ្រប់គ្រងនៅសាលាគរុកោសល្យនិងវិក្រឹតការ ។ បន្ទាប់មកត្រឡប់ទៅបង្រៀននៅសាលាកំពង់កន្ទួត ។ សុន សេន បានទៅទស្សនកិច្ចនៅប្រទេសឆេកូស្លូវ៉ាគីនៅឆ្នាំ១៩៥៩ ។ ឆ្នាំ១៩៦០ បានចូលរួមជាមួយគណៈកម្មាធិការបក្សក្រុង ។ សុន សេន ត្រូវបានផ្លាស់ឲ្យទៅធ្វើជានាយកវិទ្យាល័យរដ្ឋមួយនៅខេត្តតាកែវ ដោយត្រូវបានចោទប្រកាន់ថាប្រឆាំងនឹងរបបរាជានិយម ។ សុន សេន ជាផ្នែកមួយនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងមហាសន្និបាតបក្សលើកទី៣ ។ ឆ្នាំ១៩៦៤ សុន សេន ចូលបង្កប់ខ្លួននៅទីក្រុងភ្នំពេញ ដល់ឆ្នាំ១៩៦៨ បានក្លាយទៅជាប្រធានគណៈកម្មាធិការនយោបាយភូមិភាគនិរតី ។ នៅឆ្នាំ១៩៦៩ សុន សេន គឺជាអ្នកគ្រប់គ្រងមន្ទីរភូមិភាគឦសាន និងបានចូលរួមប្រជុំមហាសន្និបាតបក្សកុម្មុយនិស្តកម្ពុជានៅឆ្នាំ១៩៧១ ។ ឆ្នាំ១៩៧២ សុន សេន មានតួនាទីជាប្រធានអគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ ។ ឆ្នាំ១៩៧៦ សុន សេន មានតំណែងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ កងទ័ពរបស់ សុន សេន បានសម្លាប់ជនស៊ីវិលអស់៣០០នាក់ក្នុងពេលតែមួយក្នុងអំឡុងពេលវាយលុកតាមព្រំដែន ។ ឆ្នាំ១៩៧៨ សុន សេន មានចំណែកនៅក្នុងការបញ្ជាឲ្យមានការសម្លាប់រង្គាលប្រជាជនខ្មែរអស់ជាង១សែននាក់នៅភូមិភាគបូព៌ាក្នុងរយៈពេល៦ខែ ។ នៅក្រោមបញ្ជារបស់ សុន សេន មន្ទីរសន្តិសុខ ស-២១ បានធ្វើទារុណកម្មនិងសម្លាប់មនុស្សអស់ជាង១ម៉ឺននាក់ ។ **ឆាំង យុ**



# តើសុន សេន ជាខ្មាំងបង្កប់ដូចដែល ប៉ុល ពត

សុន សេន ហៅ ខៀវ ឬ បង៨៩ អតីតសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការបក្សកុម្មុយនិស្តកម្ពុជានិងគណៈកម្មាធិការអចិន្ត្រៃយ៍និងជារដ្ឋមន្ត្រីសន្តិសុខជាតិ រួមជាមួយប្រពន្ធឈ្មោះ យុន យ៉ាត ហៅ អាត អតីតរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងព័ត៌មានក្នុងរបបខ្មែរក្រហម និងសមាជិកក្រុមគ្រួសារ ត្រូវបាន ប៉ុល ពត បញ្ជាឲ្យទាហានសម្លាប់ចោលនៅតំបន់ចុងក្រោយបង្អស់របស់ពួកខុទ្ទាមខ្មែរក្រហមអន្លង់វែងក្នុងខែមិថុនា ឆ្នាំ១៩៩៧ ។

មូលហេតុនៃការសម្លាប់ក្រុមគ្រួសារ សុន សេនគឺដោយសារ ប៉ុល ពត ចោទប្រកាន់ថា សុន សេន គឺជាខ្មាំងបង្កប់នៃរបបក្រុងភ្នំពេញ ។ ប៉ុល ពត បានផ្តល់បទសម្ភាសន៍ដល់អ្នកយកព័ត៌មាន នេត ថេយ័រ ថា «ចាប់តាំងពីមានការផ្តាច់ខ្លួន...មានពួកខ្ញុំបានចាប់បានឯកសារប្អូនថ្លៃ សុន សេន បញ្ចេញផ្ញើមកពីកំពង់ធំ បីឯកសារ បីសំបុត្រ ហើយកំពង់ធំនេះនៅក្នុងក្របខ័ណ្ឌ ហ៊ុន សែន» ។ តើការចោទប្រកាន់នេះពិតឬទេ? តើ សុន សេន ក្បត់នឹងរបបខ្មែរក្រហមតាំងពីពេលណា? តើ សុន សេន យ៉ុន យ៉ាត ពិតជាក្បត់នឹង ប៉ុល ពត ប្រាកដមែនដែរឬទេ?

ចម្លើយសារភាពរបស់ ស៊ុន ទី ហៅ ទាញ គួនាទីជាភ័ស្តុភារសេនាធិកា រដែលត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៨ ហើយបញ្ជូនមកទួលស្លែងដើម្បីសួរចម្លើយបាននិយាយអំពីផែនការក្បត់បដិវត្តន៍ ដែលមានការចូលរួមរបស់ សុន សេន ។ ចម្លើយសារភាពនេះចែកជាពីរផ្នែក ផែនការទី១ សម្លាប់បងលេខាបក្សទីមួយ សមមិត្ត ប៉ុល ពត លេខាទីពីរ សមមិត្ត អៀង សារី



# ចានប្រកាន់មែនឬទេ?

ហៅ វ៉ាន់ គណៈប្រតិភូចិន គឹង យុង គុយ និងផែនការទី២ គឺការវាយបក្សនៅរដូវប្រាំងខែមករា ឆ្នាំ១៩៧៩ ។ ខាងក្រោមនេះ ជាសេចក្តីរាយការណ៍អំពីផែនការធ្វើឃាតបងៗកម្មាភិបាលដឹកនាំ÷

**សូមរាយការណ៍អំពីផែនការធ្វើឃាតបងៗ និងធ្វើទៅលើភ្ញៀវបក្សនិងរដ្ឋដែលមានទស្សនកិច្ចនៅកម្ពុជា (ខ្ញុំដឹងតាម កន ប្រាប់)**

***អំពីផែនការសម្លាប់បងទី១*** (ដកស្រង់ពីឯកសារ D០៧៣៧៧)

ខ្ញុំស្គាល់ កន ត្រូវជាប្អូន ខៀវ តាមរយៈ ខៀវ កាលបើខ្ញុំចេញពីភ័ស្តុភារ ។ ខ្ញុំទៅដល់ក្រសួងការពារប្រទេសដំបូងបានតែប៉ុន្មានថ្ងៃខ្ញុំត្រូវចេញទៅក្រៅជាមួយ បង វ៉ាន់។ ប្រហែលពាក់កណ្តាលខែ៨-៧៨ ខ្ញុំមកវិញ ក្នុងរយៈពេលទៅក្រសួងការបរទេសមុនថ្ងៃ៩-៩-៧៨ ខ្ញុំត្រូវចេញពីញូវយ៉កក៏មិនទាន់មានការទាក់ទងដែរ ។ ខ្ញុំមកដល់ភ្នំពេញវិញដើមខែ១១-៧៨ ។ ពេលល្ងាចក្នុងពេលក្រោយបាយ ខ្ញុំមកលេងបន្ទប់មិត្ត កន មិត្តកន បាននិយាយប្រាប់ខ្ញុំថា ផែនការរបស់យើងធ្វើតទៅចេះតែខុយ ។ ខ្ញុំសួរថាផែនការយ៉ាងណា? ផែនការអី ។ ដំបូងនិយាយអំពីផែនការសម្លាប់បងទី១ដោយប្រើថ្នាំពុល ។ ប្រើតាមរយៈបង អាត កន និយាយនៅមន្ទីរអគ្គការ បង អាត អាចចេញចូលបាន ហើយពេលខ្លះមានពេលម្តងមួយ ហាម នៅហូបបាយទីនោះដែរ ឆ្លៀតពេលនោះដាក់ថ្នាំបំពុល ។ ក្នុងការជជែកគ្នា កន និយាយថា ថ្នាំពុលនេះបានកាលជំនាន់នារី ណាន ប្រពន្ធ ឆយ (ឆយ នៅខាងឃោសនាការអប់រំ) កន ប្រាប់ថាថ្នាំនេះ បានតាមខ្សែហុងកុងតាមរយៈប្រពន្ធសុខ ។ កន និយាយថាការដែលដាក់មិនបានមកពីអ្វីដែលបងទី១ហូបត្រូវកងការពារបងយកដោយខ្លួនឯងធ្វើដោយខ្លួនឯង ធ្វើបានក្លាមយកជូនបងក្លាមគឺតាំងពីបងមិនទាន់ហូប រហូតបងហូបហើយទើបកងការពារដើរចេញនិងយកចេញ ។

***អំពីផែនការសម្លាប់ភ្ញៀវចិន (គឹង យុង គុយ)***

ក្នុងផែនការសម្លាប់ គឹង យុង គុយ ផែនការនេះ កន និយាយថា បងខៀវ បានចាត់តាំងឲ្យគាត់សម្លាប់ភ្ញៀវមានវិធីពីរយ៉ាង ម្យ៉ាងដាក់ថ្នាំបំពុល និងម្យ៉ាងទៀតលបបាញ់សម្លាត់ ។

ការប្រើថ្នាំបំពុល គឺ កន ជាអ្នកទទួល ឯការបាញ់ប្រើនារី ។ កន និយាយថា ហេតុដែលខ្លួនគេទទួលខាងថ្នាំបំពុលពីព្រោះខ្លួនគេជាអ្នកទទួលពិធីការផ្ទះភ្ញៀវនៅពេលគេចេញចូលបាន ដូច្នេះលទ្ធភាពមានច្រើន ពីព្រោះបំពុលមិនប្រើទូទៅទេ ប្រើតែលើបុគ្គលម្នាក់ ហើយប្រើក្នុងទឹកហូបឬពេលបាយ ។ កន និយាយថាគាត់ពិនិត្យថ្ងៃដំបូងចង់ដាក់ក្នុងដបទឹក តែឃើញកងការពារគាត់ពិនិត្យណាស់ដបទឹកហូប បើគាស់ធូរតែបន្តិចមិនចាក់ឲ្យហូបទេ ។ ឯដបដែលថាល្អ ហើយ ក៏គេហូបបន្តិចសិន ប្រហែល២-៣នាទីទើបចាក់ឲ្យហូប ។ ឃើញដូច្នេះ គេអស់លទ្ធភាពធ្វើ ។ ឯខាងផ្នែកបាយវិញធ្វើអត់បានទេ ដោយអ្នកធ្វើបាយធ្វើរួចហើយប្រគល់ឲ្យអ្នករៀបអ្នករៀប គេទទួល គេឈរចាំនៅទីនោះ អ្នកគ្មានការកិច្ចគេអត់ឲ្យទៅជិតទេ ឯតុហូបមានអ្នកនៅយាមជាប់ ពេលហូបគឺ



សុន សេន



អៀង សារី

ភ្ញៀវមកអន្ទុយ ទើបលើកទៅភ្នាមៗ កន និយាយថា គាត់ទៅជិតកន្លែងរៀបបាយ ដែរតែគេតាមមើលជាប់ ។ ការបាញ់ កន ថាប្រគល់ភារកិច្ចឲ្យនារី ស៊ិន ត្រូវជាប្អូនថ្លៃ កន ហើយនិងនារីបីនាក់ទៀត ។ ពីព្រោះនារីទាំងបួនរូបនេះនៅប្រចាំការជាប់ក្នុងរយៈកាលទស្សនកិច្ចរបស់ភ្ញៀវនៅភ្នំពេញ ។ កន និយាយថានារី ស៊ិន ជាអ្នកទី១ ហើយមាននារីម្នាក់ទៀតជាអ្នកទី២ បន្ទាប់ពីនារី ស៊ិន នារីពីរនាក់នេះជាអ្នកបាញ់ ឯនារី២នាក់ទៀតនាំស៊ើបការណ៍ បើឃើញភ្ញៀវដើរចេញក្រៅខុសការប្រុងប្រយ័ត្ន ។

កន និយាយថា នារីទី២បន្ទាប់ពី ស៊ិន ជាអ្នករៀបចំបន្ទប់ មាឌក្រអាញទាប គាត់ជាមនុស្សរួសរាយបន្តិច ។ ឯនារី២នាក់ទៀតជាអ្នករៀបបន្ទប់ដែរ ។ សូមជម្រាបសមមិត្តដោយត្រង់ថានារីបីនាក់នេះ កន អត់បាននិយាយឈ្មោះទេ បើខ្ញុំដឹងខ្ញុំរាយការណ៍ជូនអត់លាក់ទេ ។ កន និយាយថា ការបាញ់ក៏ធ្វើមិនបាន គាតឹង យុង គុយ អត់ដើរចេញផ្តេសផ្តាសទេ អ្នកដទៃចេញមកយ៉ខាងក្រៅផ្ទះខ្លះតែមួយភ្លែតគេចូលវិញ ។ កន និយាយថាផែនការសម្រាប់តែធ្វើនៅភ្នំពេញ ឯចេញក្រៅអត់មានផែនការអីទេ ។ កាំភ្លើង កន ថាមានតែមួយដើមទេ(កាំភ្លើងតូច) កាំភ្លើងនេះបានមកពីបង ខៀវ ។

**អំពីការចាត់តាំងបាញ់បង វ៉ន់** (អៀង សារី)

កន និយាយថា មានម្តងនោះបង ខៀវ ខឹងនឹងបង វ៉ន់ ខ្លាំងណាស់ បានចាត់តាំងឲ្យនិរសាគាត់ឈ្មោះ ឡឿន បាញ់បង វ៉ន់ ម្តង តែបាញ់មិនបាន ។ បញ្ហានេះគឺខឹងថាបង វ៉ន់ និង វន ត្រូវគ្នារកពេលតែជួលបង ខៀវ ។ ថ្ងៃ២៥-១២-៧៨ ទាញ

**សូមរាយការណ៍អំពីសកម្មភាពរបស់ខ្ញុំជាមួយ វន**

ការទាក់ទងរបស់ខ្ញុំជាមួយ វន ញឹកញាប់តាំងពីអង្គការបានចាត់តាំងឲ្យ វន គ្រប់គ្រងផ្នែកគ្រាប់រំសេវមក ក្នុងពេលជួបម្តងៗ វន អប់រំខ្ញុំ ពង្រឹងខ្ញុំឲ្យខំធ្វើការតាមផែនការកសាងសេ.អ៊ី.អា ពិសេសឲ្យកសាងយកកម្មាភិបាលមុនគេ ឲ្យខ្ញុំខំធ្វើការកុំឲ្យព្រួយបារម្ភដោយមានវានិងសមមិត្ត ខៀវ រ៉ាប់រងដោះស្រាយ ។

ប្រហែលពាក់កណ្តាលខែ៦-១៩៧៨ វន ហៅខ្ញុំឲ្យទៅមន្ទីរសេដ្ឋកិច្ចប្រញាប់បំផុត ។ នៅមន្ទីរសេដ្ឋកិច្ចដំបូង វន ឲ្យលិខិតមួយសន្លឹកគឺជាប័ណ្ណចេញគ្រាប់គ្រប់ធុន ពិសេសគ្រាប់របស់ចិន លិខិតនេះមានបោះត្រាគណៈកម្មាធិការ៨៧០ ពីចំហៀងត្រាស៊ីញ៉េ វន ។ ចំនួនគ្រាប់រំសេវដឹកពេលនោះចេញពីរលើកទើបអស់ គិតជាឡានជាង១០០ឡាន គ្រាប់នេះដឹកឲ្យសមមិត្ត ខៀវ នៅស្វាយរៀង ។ ក្រោយពីខ្ញុំទទួលប័ណ្ណនេះហើយ វន បានអប់រំរំលឹកសាចុះសាឡើង និងពង្រឹងជំហរឲ្យជឿជាក់លើវានិងលើសមមិត្ត ខៀវ ។ វានិយាយយូរណាស់ប្រហែលជាង១ម៉ោងទើបវានិយាយថាខ្ញុំសុំប្រគល់ការងារថ្មីមួយទៀតក្រៅពីការងារដឹកគ្រាប់រំសេវ ។ សមមិត្ត ខៀវ គាត់នៅឆ្ងាយគាត់ឲ្យប្រាប់សមមិត្តថែម ដើម្បីសមមិត្តកក់ក្តៅ ឯទូរស័ព្ទសម្ងាត់និយាយក៏មិនស្រួលដែរ ការងារនោះគឺជាការងាររបស់ខ្ញុំ(វន) នឹងគាត់ ខៀវ វន និយាយទៀតថា ខ្ញុំនិងសមមិត្ត ខៀវ មានផែនការវាយបក្សរដូវប្រាំងនេះ ។ ការងាររបស់សមមិត្ត នៅ តួនាទីសំខាន់ទី២គឺការងារផ្តល់គ្រាប់រំសេវ បើសមមិត្តសម្រេចបានជាជ័យជម្នះមួយ ។ គ្រាប់កាំភ្លើងមានអស់ហើយវានៅតែបញ្ហាដឹក គិតគូរបញ្ហានេះអស់លទ្ធភាពរបស់ភ័ស្តុភារ ទាំងខាងជើងគោក ទាំងខាងជើងទឹក ។ ដឹកវាស្រួលនៅសភាពធម្មតាតែពេលមានឧបសគ្គបើដោះស្រាយរួចទើបបានជ័យជម្នះ ។ មតិទី១ គឺគ្រាប់រំសេវគ្រប់ប្រភេទដាក់តាមប្រភេទតាមឃ្លាំងនីមួយៗដាក់ផ្លាកឲ្យច្បាស់លាស់ត្រូវមានបញ្ជីឃ្លាំង តើឃ្លាំងណាដាក់គ្រាប់អីកុំយកការចាំពីព្រោះដល់ពេលប្រញាប់ច្បាស់ជាមានការច្រឡំតែកន្លះម៉ោងក៏ខាតពេលដែរ ។ ធ្វើការត្រូវវិទ្យាសាស្ត្រ ។ សមមិត្តទៅវិញប្រជុំគ្នាគិតគូរតាមមតិនេះ ជាមួយសមមិត្ត ម៉ុត ធឹម ដុន ទៀតឲ្យល្អិត ។ មតិទី២គឺ មធ្យោបាយដឹកចេញឡានអត់ខ្វះខាតទេ ឯកាណូតក៏មានមួយចំនួនហើយ នៅតែយើងរៀបចំវា ។ មតិទី៣ ត្រូវរៀបចំតាមប្រភេទ ដូចជាគ្រាប់និងកាំភ្លើង ពិសេសបញ្ហាគ្រាប់ ឯកាំភ្លើងបញ្ហារួមផ្សំត្រូវរៀបចំឲ្យហើយតាមមតិណែនាំខាងលើមុនខែ១-១៩៧៩យ៉ាងយូរបំផុតពាក់កណ្តាលខែ១២-១៩៧៨ ហើយស្រេចបាច់ទាំងអស់ ។ មតិទី៤ បញ្ហាកម្លាំងមិនចោទទេ ពេលត្រូវការយើងប្រមូលវាពេលនោះអស់គិតលក្ខការណ៍អីទៀតទេ ។ តែត្រូវគិតកម្លាំង



វន វ៉េត

ការពារបរិវេណឃ្លាំងគឺថ្ងៃណាពេលណាក៏នៅជាឃ្លាំងរបស់យើង ។ មតិទី៥ ចាំដល់ពាក់កណ្ដាលខែ១២-៧៨ ចាំខ្ញុំឲ្យប័ណ្ណសម្រាប់ដឹកសម្ភារចេញរបស់មន្ទីរ៧៨០មួយក្បាលសម្រាប់ប្រើការពីព្រោះប្រើបានទូទាំងប្រទេស ។ ប្រហែលម៉ោងជាង១០ ខ្ញុំចេញមកមន្ទីរវិញដើម្បីចាត់តាំងដឹកគ្រាប់ចេញ ។ ប្រហែល៣ថ្ងៃក្រោយមកទើបខ្ញុំអញ្ជើញសមមិត្ត ម៉ូត សមមិត្ត ផុន សមមិត្ត ធឹម មកប្រជុំ ។ ខ្ញុំយកមតិណែនាំរបស់ វន ដែលខ្ញុំធ្លាប់បានខទ្មេសនាមជូនអង្គប្រជុំ ។ ទាំងអស់គ្នាពិគ្រោះគ្នាហើយឯកភាពធ្វើតាមមតិណែនាំរបស់ វន លើកទាំងអស់ ។ ក្នុងរយៈពេលបីថ្ងៃនេះខ្ញុំមិនទៅប្រជុំ ខ្ញុំមិនបានគិតច្រើនឥឡូវដល់វេលាក្បត់បក្សច្បាស់លាស់ហើយ តើត្រូវរាយការណ៍ជូនបក្សឬមិនរាយការណ៍ ខ្ញុំគិតឃើញថាបើរាយការណ៍ជូនបក្សខ្លាចបក្សមិនជឿពីព្រោះ វន ជាគណៈអចិន្ត្រៃយ៍ ហើយសមមិត្ត ខៀវ គណៈមជ្ឈិមទទួលកងទ័ពទាំងមូលទៀតឃើញយ៉ាងដូច្នេះហើយបានជាខ្ញុំមិនហ៊ានរាយការណ៍ជូនបក្សទេ សុខចិត្តធ្វើតាម វន នឹង ខៀវ ។ ក្រោយពីខ្ញុំបានប្រជុំប្រហែលពីរថ្ងៃ វន បានទូរស័ព្ទហៅឲ្យខ្ញុំទៅជួបនៅមន្ទីរសេដ្ឋកិច្ច ។ នៅមន្ទីរសេដ្ឋកិច្ចវាឲ្យខ្ញុំរាយការណ៍អំពីលទ្ធផលការងាររៀបចំគ្រាប់រំសេវកាំភ្លើងតាមផែនការវា ។ ខ្ញុំបានរាយការណ៍តាមលទ្ធផលដែលខ្ញុំបានប្រជុំដូចបានរាយការណ៍ខាងលើតែខ្ញុំបានរាយការណ៍ថែមអំពីសភាពទុកដាក់គ្រាប់រំសេវកាំភ្លើងដែលបានរៀបចំកន្លងមកនៅតាមឃ្លាំងធំៗគឺមិនទាន់ស្រួលធានា១០០ភាគរយទេ បើប្រញាប់ច្បាស់ជាមានការច្រឡំមិនខាន ។ ឥឡូវសមមិត្ត ម៉ូត សមមិត្ត ធឹម ចុះទៅកែសម្រួលថែមទៀត បើដល់ខែ១២-៧៨ អាចរៀបចំឲ្យហើយបាន ។ វន និយាយថា យ៉ាងម៉េចក៏ត្រូវខំធ្វើឲ្យបាន ។ ខ្ញុំជួប វន ពេលណាក៏ពង្រឹងសតិអារម្មណ៍ខ្ញុំជាប់ ។ មុនខ្ញុំចេញមកមន្ទីរវិញវាផ្ដាំខ្ញុំថាឲ្យទៅមន្ទីរសេដ្ឋកិច្ចឲ្យសមមិត្ត ម៉ូត ទៅជាមួយផងខ្ញុំចាំថ្ងៃមិនច្បាស់ ប្រហែលថ្ងៃ២៦ ឬ២៧ ខែ៦-៧៨ ។ ខ្ញុំនិង ម៉ូត ទៅរក វន តាមការកំណត់ ។ ពេលជួប វន វាសួរសុខទុក្ខធម្មតា មានមិត្តកងការពារនៅជិតនោះវាដេញឲ្យចុះក្រោម ។ បន្ទាប់ វន ឲ្យរាយការណ៍ថែមទៀត តើសភាពការណ៍រៀបចំគ្រាប់រំសេវកាំភ្លើងតើដល់ណា? លើកនេះខ្ញុំឲ្យសមមិត្ត ម៉ូត រាយការណ៍ ។ រាយការណ៍លើកនេះអត់មានអីលើសមុនៗទេ ។ វន និយាយថា បើសមមិត្ត ទាញ មិនទៅ តើសមមិត្ត ម៉ូត ទៅរួចទេ? ខ្ញុំ ទាញ ឆ្លើយថាអត់អីទេ មានសមមិត្តច្រើនទៀតគេធ្វើជាមួយ ។ វន និយាយទៀតថាសមមិត្ត ទាញ អត់នៅភ័ស្ដុភារទៀតទេ ដូចនេះសមមិត្ត ម៉ូត រ៉ាប់រងការងារដែលសមមិត្តបានប្រជុំគ្នាពីថ្ងៃមុន តែនៅក្នុងនោះក៏មានសមមិត្ត ផុន សមមិត្ត ធឹម ទៀត ។ ខ្ញុំនិង ម៉ូត ជួប វន ព្រឹកនោះប្រហែល២ ម៉ោង ។ ពេលវេលាចុះមកវិញ វន ឲ្យ ម៉ូត ចេញមកមុនហើយ វន និយាយថា សមមិត្តទៅក្រសួងការបរទេស ថ្ងៃ២៩-៦-១៩៧៨ នេះ ល្ងាចម៉ោង១កន្លះមកដល់នេះដើម្បីជួបបងខាងលើ ។ នៅថ្ងៃ២៩-៦-៧៨ តាមពេលកំណត់ខ្ញុំទៅដល់ឃើញសមមិត្ត ណាត និងសមមិត្ត ហុក នៅទីនោះដែរ ។ ប្រហែលម៉ោងជិត២ វន ទៅដល់ហើយហៅឡើងលើ ។ ម៉ោង២លើសបន្តិចបងទី២ក៏ទៅដល់ ។ ពេលប្រជុំបងទី២មានមតិណែនាំប្រហែល១ម៉ោងបន្ទាប់មក វន មានមតិដូចបងដែរ ក្រោយមកបងទី២ឲ្យម្នាក់ៗចាប់អារម្មណ៍ម្នាក់ៗគ្មានមតិអីច្រើនទេគឺឯកភាពនឹងបក្សចាត់តាំង ។ ប្រជុំលើកនេះ



ចប់ប្រហែលម៉ោងជិត៤ទើបបងទី២ត្រឡប់ទៅវិញ ។ ខ្ញុំ វន ឃាត់ឲ្យនៅជួបវាហូតដល់ម៉ោងជាង៥ ។ ក្នុងរយៈពេលជួបគ្នានេះ វន សួរខ្ញុំសាចុះសាឡើងតែពីរឿងគ្រាប់រំសេវ ពីរឿង ម៉ូត ទទួលបានឬមិនបាន។ ពេលនេះ វន ក៏នៅតែធ្វើសតិអារម្មណ៍ខ្ញុំជាប់ដដែល អំពីរក្សាការសម្ងាត់ វន និយាយថាបើខ្ញុំរក្សាការសម្ងាត់បានវានៅតែជួបរហូត តែបើបែកវាជំរុញថែម ។ ថ្ងៃ២៤-១២-៧៨ ទាញ

## បក្សជាទីគោរព

ខ្ញុំជាមួយ វន ខៀវ ស្គាល់យូរមកហើយពុំមែនទើបតែស្គាល់ទេ ពីមុនស្គាល់តែក្នុងលក្ខណៈពាក់កណ្តាល ។ ទើបតែនៅពេលដែលយួនវាយចូលជិតដល់ស្វាយរៀង ប្រហែលខែ១១-៧៧ ពេលដែលសមមិត្ត ខៀវ ត្រូវទៅជាប់សមរភូមិពេលនោះ ហើយដែល វន បានឲ្យដឹងថាខ្លួន វន និងសមមិត្ត ខៀវ ជាខ្សែជាមួយគ្នា ។

ក្រោយពីខ្ញុំបានទទួលភារកិច្ចមួយក្នុងការផ្តល់គ្រាប់តាមផែនការក្បត់វាយបក្សនៅរដូវប្រាំងនេះ ខ្ញុំខ្វល់ខ្វាយណាស់ ដោយយកចលនារបស់បក្សឆ្លុះបញ្ចាំង ព្រមទាំងមាគ៌ារបស់បក្សមកប្រៀបធៀបនឹងអំពើក្បត់ឃើញថាធ្វើយ៉ាងម៉េចក៏ពុំអាចឈ្នះបក្សបានទេ ។ ដំបូងខ្ញុំគិតថាត្រូវតែរាយការណ៍ជូនបក្សគិតសាចុះសាឡើងខ្លាចរាយការណ៍ជូនបក្ស បក្សមិនជឿពីព្រោះ វន ជាគណៈអចិន្ត្រៃយ៍ ហើយសមមិត្ត ខៀវ ជាគណៈមជ្ឈិមជាមនុស្សសំខាន់របស់បក្សដែលទទួលយោធារួមទៀត ឃើញធំៗណាស់ ហើយគេសន្យាធានាដល់អាយុជីវិតខ្ញុំទៀត ។

បក្សជាទីគោរព ថ្វីត្បិតតែខ្ញុំបានរស់នៅជិតបងៗរយៈពេលខ្លី ប្រហែល១ឆ្នាំប៉ុណ្ណោះ ហើយនោះខ្ញុំជាបក្ខជនផងជាខ្មែរសេរីផងធាតុពិតរបស់ខ្ញុំពេលនោះការយល់ដឹងចូលជ្រៅក្នុងខ្លឹមសាររបស់ខ្មែរសេរី បើប្រៀបមកបក្សគឺខ្ញុំនៅខាងបក្សខ្លាំងជាងពេលនោះ ។ នៅឮសាន១ឆ្នាំនេះ ខ្ញុំស្គាល់បង វ៉ន់ ច្រើនជាងបងលេខា ពេលនោះខ្ញុំមានមនោសញ្ចេតនាគោរពស្រឡាញ់ទៅលើបង វ៉ន់ ខ្លាំង ។ នៅពេលខ្ញុំបានធ្វើដំណើរចុះមកវាលរាបវិញជាមួយបងៗលេខា ខ្ញុំកាន់តែគោរពស្រឡាញ់បងៗកាន់តែខ្លាំងថែមទៀត ឃើញបងៗទ្រាំទ្រការលំបាកវេទនាដើរទាំងថ្ងៃដើរទាំងយប់កាត់ព្រៃភ្នំក្រមថ្មដើម្បីដឹកនាំប្រជាជនធ្វើបដិវត្តន៍រំដោះខ្លួនរំដោះប្រទេសជាតិ រំដោះវណ្ណៈក្រីក្រ ពេលនោះខ្ញុំតាំងចិត្តថាត្រូវតែបោះបង់អំពើខុសឆ្គងរបស់ខ្ញុំក្រោយពីខ្ញុំបានមកនៅជាមួយឈ្មោះ វន វិញ ការតាំងចិត្ត ការប្តេជ្ញាចិត្តត្រូវរលាយខ្សុលដោយ វន វាបេះអូសទាញខ្ញុំ វន មានឥទ្ធិពលលើខ្ញុំខ្លាំងជាងឪពុកម្តាយខ្ញុំទៀត ពេលជាបន្តបន្ទាប់ខ្ញុំឈានទៅក្បត់បក្សកាន់តែខ្លាំង ក្រោយការគ្រប់គ្រងរបស់ឈ្មោះ វន ហើយចុងក្រោយជាមួយឈ្មោះ ខៀវ នេះទៀត ។ ថ្ងៃ២៤-១២-៧៨ ទាញ

## ខ្ញុំសូមរាយការណ៍អំពីសតិអារម្មណ៍របស់ខ្ញុំនៅពេលបក្សចាប់ខ្លួន

ខ្ញុំត្រូវបក្សចាប់ខ្លួននៅយប់ថ្ងៃ១០-១២-៧៨ ។ ពេលខ្ញុំមកដល់សាលាអប់រំភ្លាមខ្ញុំគិតឃើញថា បើឆ្លើយថានៅខ្សែជាមួយ វន ខ្លាចសមមិត្តមិនជឿដោយគិតថាមកដល់ទើបឆ្លើយ ។ ដំបូងខ្ញុំឆ្លើយថាត្រង់នឹងបក្ស សមមិត្តសួរលើកទី១ ខ្ញុំឆ្លើយដដែលសួរលើកទី២ លើកទី៣ ទើបខ្ញុំសុខចិត្តឆ្លើយ សមមិត្តសួរចម្លើយលើបញ្ហាឲ្យឆ្លើយគឺ÷ ១) អំពីផែនការក្បត់វាយបក្សរដូវប្រាំង ២) ចូលសេ.អ៊ី.អាឆ្នាំណា ៣) អ្នកណាបន្តវេនផែនការក្បត់ពី វន ។ ដំបូងសមមិត្តទទួលខុសត្រូវឲ្យខ្ញុំសរសេរផែនការក្បត់វាយបក្សរដូវប្រាំងសតិអារម្មណ៍ខ្ញុំពេលនោះគិតថាផ្ទាល់ខ្លួន ផែនការរួមវាយបក្សអត់ដឹងសោះដឹងត្រឹមតែវាប្រគល់ភារកិច្ច ផ្តល់គ្រាប់រំសេវ ដូច្នេះខ្ញុំសរសេរលើកទី១ប្រឌិតផងពិតផង ។ សមមិត្តសួរចម្លើយមិនព្រមសួរម្តងទៀតខ្ញុំថាសុខចិត្តសារភាពហើយលើកនេះ គឺប្រឌិតទាំងស្រុង ។ បន្ទាប់មក សមមិត្តសួរចម្លើយឲ្យខ្ញុំសរសេរប្រវត្តិសកម្មភាពក្បត់របស់ខ្ញុំតាំងពីក្បត់រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ខ្ញុំកំពុងសរសេរសមមិត្តសួរចម្លើយ សួរអ្នកបន្តពី វន សួរដំបូងធម្មតា ខ្ញុំឆ្លើយថាអត់ដឹងទេ ខ្ញុំគិតថាបើឆ្លើយខ្លាចសមមិត្តសួរចម្លើយ ចាប់សួរមួយសន្ទុះសួរផងអប់រំផងលើកឧទាហរណ៍ ដូចសមមិត្តមួយចំនួនឆ្លើយជូនបក្សស្មោះត្រង់ ទោះមកដល់ទីនេះក៏បក្សបន្ធូរបាន ។ ពេលនេះខ្ញុំលែងខ្លាចទៀតហើយ ខ្ញុំសារភាពថា ខ្ញុំសូមឆ្លើយជូនបក្សតាមអំពើដែលខ្ញុំបានធ្វើ និងអ្នកដែលត្រូវរាយការណ៍ជូនបក្ស ។ ទោះបីខ្ញុំប្តេជ្ញាចិត្តហើយក៏សតិអារម្មណ៍ខ្ញុំមិនទាន់ជ្រះស្រឡះទេ នៅស្មុគស្មាញច្រើនណាស់នៅតែសង្ស័យថាសន្តោសនៅតែមិនច្បាស់តែដល់ឃើញសមមិត្ត ដាំ ដែលធ្លាប់ស្គាល់កាលពីនៅឮសាន គាត់ត្រូវបានបក្សសន្តោសជូន សមមិត្តសួរចម្លើយគាត់បានអប់រំខ្ញុំ គឺនៅពេលដែលគាត់មកលាងរបួសឲ្យខ្ញុំ ។ តាំងពីពេលនោះមកខ្ញុំប្តេជ្ញាចិត្តថានឹងរាយការណ៍ជូនបក្សទាំងអស់នូវអំពើដែលខ្ញុំបានធ្វើដោយឃើញជាក់ស្តែងនូវមាគ៌ាសន្តោសរបស់បក្ស ខ្ញុំប្តេជ្ញាក្នុងសតិអារម្មណ៍របស់ខ្ញុំខំសរសេរឲ្យបានល្អបានល្អិត ហើយរង់ចាំពេលសមមិត្តសួរចម្លើយមកបញ្ជាក់លើបញ្ហាទៀតខ្ញុំខិតខំឆ្លើយឲ្យច្បាស់ថែមទៀត ។

ថ្ងៃ២៤-១២-១៩៧៨ សុនទី ហៅ ទាញ

**អៀ ម៉េងទ្រី**

# សមមិត្ត គង់ ឬ សួង ស៊ីគឿន

## (កត់ត្រាតាមសំណៅដើមឆាំងស្រុង)


សមមិត្ត គង់ ឬ សួង ស៊ីគៀន

**(តពីលេខមុន)** ដូច្នេះយើងខ្ញុំចង់មានកិត្តិយសជាអ្នកបដិវត្តផង តែចង់រស់នៅស្រណុកស្រួលក្នុងឋានៈជាវណ្ណៈកណ្តាលជិះជាន់កម្លាំងពលកម្ម និងកេងប្រវ័ញ្ចការលះបង់និងឈាមស្រស់របស់កម្មករកសិករក្រីក្រ ។

២) មោទកភាពជាតិ មោទកភាពចំពោះប្រជាជនរបស់ខ្លួនផ្ទាល់ មោទកភាពចំពោះបដិវត្តន៍ខ្លួន ចំពោះបក្សខ្លួន ត្រូវលង់លិចទៅតាមការអប់រំថែបំប៉ន ឃោសនាពន្លក់ខួរក្បាលជាបន្តបន្ទាប់ក្នុងរយៈកាលរាប់សិបឆ្នាំរបស់ពួកចក្រពត្តិអាណានិគមនិយម និងវណ្ណៈជិះជាន់គ្រប់ប្រភេទ ព្រមទាំងរបស់សម្ព័ន្ធសេរីអន្តរជាតិ បារាំង សូវៀត យួន ។

៣) គំនិតនិយម ដោយរស់នៅដាច់ឆ្ងាយពីប្រទេសជាតិ ពីប្រជាជនខ្លួនដ៏យូរលង់ ហើយក្នុងរយៈពេលតស៊ូតឹងតែងស្ទាប់រស់នៅជាមួយខ្មាំងមិនបានចូលរួមផ្ទាល់ ។ ដូច្នេះមិនទាន់មានឱកាសលត់ដំសាកល្បងចុះសាកល្បងឡើង វីវក់ញាំញីក្នុងចលនាប្រយុទ្ធជាក់ស្តែង ។

៤) កម្មសិទ្ធិឯកជននៅធ្ងន់ធ្ងរ គិតគូរពីមុខមាត់ បុណ្យសក្តិពីស្ងួនគ្នួ ។ ត្រង់ចំណុចនេះ សេរីវាអប់រំឲ្យឃើញថាខ្លឹមសារជីវិតគឺសុភមង្គលឯកជន ។ វីរភាពបុគ្គល វីរភាពបុព្វបុរស វាយកកត្តាសម្ភារជាកត្តាមូលដ្ឋានដូចជាក្នុងការបង្កបង្កើនផលជាដើម ។

***រយៈកាលឆ្លងកាត់ពីទស្សនៈនិងគោលជំហរសេរីមកកាន់ទស្សនៈនិងគោលជំហររបស់បក្សកុម្មុយនិស្តកម្ពុជា***

១) រយៈកាលស្នាក់នៅប្រទេសចិនមុនជួបបក្ស

២០ ឧសភា ១៩៧០-១១ កក្កដា ១៩៧១

យើងខ្ញុំប្រកាន់គោលជំហរនិងមានទស្សនៈសេរីជាមូលដ្ឋាន ។ តែយើងខ្ញុំបានប្តេជ្ញាចិត្តមកចូលរួមក្នុងការតស៊ូប្រឆាំងការឈ្លានពានចក្រពត្តិអាមេរិកនៅប៉េកាំងមិនត្រឡប់ទៅប្រទេសបារាំងវិញទេ ។ ម្យ៉ាងទៀត យើងខ្ញុំក៏មានជំហរនិងទស្សនៈថា ក្នុងការធ្វើសង្គ្រាមរំដោះជាតិនេះ ពួកវណ្ណៈកាន់អំណាចមុនរដ្ឋប្រហារដែលមាន សីហនុ និង ប៉ែន នុត ជាតំណាងមិនអាចដឹកនាំបានដាច់ខាត ។ ហើយយើងខ្ញុំក៏បានប្រកែកមិនព្រមធ្វើអនុរដ្ឋលេខាធិការខាងឃោសនាការដែល ប៉ែន នុត និងជួន មុម្ម បានស្នើ ព្រមទាំងប្រកែកមិនព្រមទៅធ្វើទូតនៅស៊ីលីនិងគុយបា ស្នើដោយ សារិន ឆាក់ ។ ពេលនោះយើងខ្ញុំក៏បានសួរមតិបក្ស ។ យើងខ្ញុំបានតស៊ូនឹងរបៀបរបបធ្វើការសង្គមចាស់គ្មានប្រជាធិបតេយ្យ បក្ខពួក ហើយទុករាជរដ្ឋាភិបាលនៅក្រៅប្រទេសជាអ្នកចាត់ចែងការដឹកនាំចលនាតស៊ូក្នុងប្រទេស ។

យើងខ្ញុំបានកំណត់ទស្សនៈនិងគោលជំហរយើងខ្ញុំបានច្បាស់លាស់លើបញ្ហាតស៊ូមិនសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិកនិងពួកអាក្បត់ព្រមទាំងលើបញ្ហាអំណាច គឺក្រោយរំដោះរដ្ឋអំណាចត្រូវស្ថិតនៅក្នុងកណ្តាប់ដៃប្រជាជន កម្មករ កសិករដឹកនាំដោយបក្ស(យើងខ្ញុំនឹងថាមានបក្សដឹកនាំ គ្រាន់តែមិនស្គាល់ឈ្មោះច្បាស់) ។ ម្យ៉ាងទៀត យើងខ្ញុំក៏ចង់ឲ្យប្រទេសជាតិខ្លួនឯករាជ្យពិតប្រាកដ មិនរណបប្រទេសណាទាំងអស់ ។

ដោយមករស់នៅប្រទេសចិនមួយរយៈ ខ្ញុំពិនិត្យឃើញថាចិនជួយការតស៊ូយើងដោយស្មោះមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងយើងទេ ។ ឯពួកសេរីនៅតែបន្តគាំទ្រអាណុល ហើយបន្តបំបែកបំបាក់ផ្ទៃក្នុងរណសិរ្ស និងអូសទាញឲ្យចរចាជាមួយអាលន់ ណុល ។ ដូច្នោះទស្សនៈនិងគោលជំហររបស់ពួកសេរីសហភាពសូវៀតកាន់តែទំនាស់នឹងទស្សនៈនិងគោលជំហររបស់ខ្លួនខ្ញុំផ្ទាល់លើបញ្ហាជាអាយុជីវិតរបស់ប្រទេសជាតិ ។ ព្រមជាមួយនេះនៅសន្និសីទអន្តរជាតិខាងពត៌មានធ្វើនៅគុយបាចុង

ឆ្នាំ១៩៧០ ដែលយើងខ្ញុំបានចូលរួមទស្សនៈនិងគោលជំហររបស់សូវៀតគឺប្រឆាំងខាងខ្លឹមសារវាចង់ឲ្យសម្រុះសម្រួលជាមួយពួកអាក្សត់ ។ ដូច្នេះទំនាស់ជាមួយសេរីរើលើបញ្ហាសំខាន់នេះក៏រេះតែវិវត្តពីមួយថ្ងៃទៅមួយថ្ងៃ ។ ឯគោលជំហរប្រឆាំងចិនក៏ត្រូវវាយប្រហារហើយចុះថយទ្រុឌទ្រោមអស់ច្រើន ។

២) ខែកក្កដា ១៩៧១-ខែកញ្ញា ១៩៧១

បង អៀង សារី តំណាងបក្សបានអញ្ជើញមកដល់ប៉េកាំងហើយបានបើកវគ្គអប់រំសមាជិករណសិរ្សនៅប៉េកាំងក្នុងខែ៩ ឆ្នាំ១៩៧១ ។ ក្នុងវគ្គអប់រំនេះ បក្សបានផ្សព្វផ្សាយនិងបំពាក់នូវទស្សនៈនិងគោលជំហរជាមូលដ្ឋានក្នុងភារកិច្ចធ្វើសង្គ្រាមបដិវត្តន៍រំដោះជាតិ រំដោះប្រជាជន ។ ជាពិសេស បក្សបានអប់រំពីគោលជំហរតស៊ូយូរអង្វែងទ្រាំទ្រការលំបាកវេទនាគ្រប់បែបយ៉ាងមិនសម្រុះសម្រួល មិនរាថយ គោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។ បក្សក៏បានវែកញែកយ៉ាងច្បាស់ពីព្រំដែនរវាងខ្មាំងនិងសត្រូវ ទាំងផ្ទៃក្នុងប្រទេសជាតិ ទាំងលើឆាកអន្តរជាតិ ។ ទស្សនៈនិងគោលជំហរទាំងប៉ុន្មានរបស់បក្សស្តីពីនយោបាយបរទេស គឺប៉ះទង្គិចយ៉ាងខ្លាំងដល់ទស្សនៈនិងគោលជំហរសេរីរើរបស់ខ្ញុំ ជាពិសេសអាកប្បកិរិយាជាយុទ្ធសាស្ត្ររបស់សហភាពសូវៀត ដែលប្រឆាំងជាហូរហែបដិវត្តន៍កម្ពុជាដឹកនាំដោយបក្សកុម្មុយនិស្តកម្ពុជា ។ ជាមួយគ្នានេះ តាមបទខុទ្ទេសនាមរបស់បងតំណាងបក្ស ខ្ញុំក៏ឃើញមហិច្ឆតាលេបទឹកដីរបស់បដិវត្តន៍វៀតណាមទៀត ។ ព័ត៌មានទាំងអម្បាលម៉ានដែលពាំនាំមកឲ្យយើងខ្ញុំជ្រាបដោយតំណាងបក្ស ខ្ញុំកំណត់យ៉ាងច្បាស់លាស់ថាជាព្រឹត្តិការណ៍ជាក់ស្តែងគ្មានប្រកែកបាន ។ ការប្តេជ្ញាចិត្តដើរតាមទស្សនៈនិងគោលជំហររបស់បក្សដាច់ខាតក្នុងពេលនោះវាប៉ះទង្គិចនឹងការយល់ដឹងនិងមនោសញ្ចេតនាជម្រៅរបស់ខ្ញុំដែលទទួលការអប់រំឃោសនាពន្លក់ពន្លឺជាយូរឆ្នាំមកពីពួកសេរីរើគ្រប់ប្រភេទ ។

ដូច្នេះរវាងទស្សនៈគោលជំហរបក្ស និងទស្សនៈគោលជំហរខ្លួនឯងផ្ទាល់ មានការតស៊ូក្តៅស្អុកស្អាញស្អាប់រស់ ។ ដោយបក្សសន្តោស អំណត់អត់ធ្មត់ និងដាច់ខាត រួមផ្សំនឹងឧត្តមគតិរបស់ខ្លួនដែលមានតាំងពីយុវវ័យ លះបង់អ្វីៗទាំងអស់ដើម្បីបម្រើប្រជាជាតិ បម្រើប្រជាជនខ្លួនឯង បម្រើបក្សវណ្ណៈកម្មកររបស់ខ្លួន បានជាខ្ញុំបោះបង់ចោលជាបន្តបន្ទាប់ទស្សនៈនិងគោលជំហររបស់បក្ស ។ ចំពោះមហាជនក្នុងពិធីឆ្លងបដិវត្តន៍ជាសាធារណៈ ខ្ញុំបានធ្វើស្វ័យទិតៀនពីទស្សនៈនិងគោលជំហរសេរីរើនេះ ។ ជាមួយគ្នានេះខ្ញុំបានធ្វើស្វ័យទិតៀនអំពីអាកប្បកិរិយាអមិត្តនឹងប្រឆាំងចិនក្នុងរយៈកាលដែលខ្ញុំមករស់នៅក្នុងប្រទេសចិន ។

បន្ទាប់មកក្រោយពីបានបង អៀង សារី ទទួលជួបពិភាក្សាខ្ញុំក៏បានទទួលសុភមង្គល និងមហាកិត្តិយសចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជាដ៏មហាភ្លឺស្វាង នៅថ្ងៃ៣០ តុលា ឆ្នាំ១៩៧១ ។ ជូន ប្រាសិទ្ធ និង គាត ឈន់ ជាអ្នកខុទ្ទេសនាមបង អៀង សារី ជាប្រធានពិធីបញ្ចូលបក្សជាមួយខ្ញុំដែរ ។

៣) រយៈកាលក្រោយថ្ងៃ៣០ ខែតុលា ឆ្នាំ១៩៧១

ក្រោយពីចូលបក្សខ្ញុំក៏បានចាប់កសាងនិងពង្រឹងទស្សនៈគោលជំហររបស់បក្សជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ ខ្ញុំទទួលភារកិច្ចក្នុងមហាជនជាសមាជិកគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំង ។ ជាមួយគ្នានេះបក្សបានប្រគល់ភារកិច្ចជាតំណាងទីភ្នាក់ងារ អា.កា.ស៊ី ប្រចាំប៉េកាំង ។ នៅរយៈពេលដដែលខ្ញុំបានសុំបក្សចូលមកបម្រើការងារក្នុងប្រទេស ។

ក្រោយពីបានបំពេញភារកិច្ចជាអ្នកជំនួយការក្នុងគណៈប្រតិភូបក្សដឹកនាំដោយសមមិត្ត អៀង សារី និងមានសមមិត្ត ខៀវ សំផន ដែលធ្វើទស្សនកិច្ចនៅប្រទេសអាស៊ីអឺរ៉ុបនិងអាហ្វ្រិកមួយចំនួន ខ្ញុំក៏បានទទួលការអនុញ្ញាតពីបក្សឲ្យចូលមកប្រទេសនៅថ្ងៃទី២៧ ឧសភា ឆ្នាំ១៩៧៤ជាមួយគណៈប្រតិភូ ។

**មូលហេតុដែលនាំឲ្យខ្ញុំសម្រេចចូលមកក្នុងប្រទេស**

១) ចង់លត់ដំកសាងខ្លួនក្នុងចលនាជាក់ស្តែងឲ្យសមស្របជាបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជា ដើម្បីបម្រើបក្សកាន់តែខ្លាំងក្លានិងប្រសិទ្ធភាពទៀត ។

២) ចង់មានកិត្តិយសតួនាទីក្នុងបដិវត្តន៍ដែរ ។

**រយៈកាលស្នាក់នៅតំបន់ទី១ ឧសភា ឆ្នាំ១៩៧៤-ឧសភា ១៩៧៥**

ក្រោយពីបានទៅធ្វើទស្សនកិច្ចក្នុងឋានៈជាអ្នកជំនួយការគណៈប្រតិភូបក្សដឹកនាំដោយបង អៀង សារី នៅតំបន់រំដោះឡាវ និងតំបន់រំដោះវៀតណាមខាងត្បូង(ខែឧសភា និងដើមខែមិថុនា ឆ្នាំ១៩៧៤) ខ្ញុំបានមកបំពេញភារកិច្ចនៅតំបន់ទី១

ក្រោមការគ្រប់គ្រងរបស់បងវ៉ា ។

ក្នុងរយៈដំបូងខ្ញុំមានភារកិច្ចស្រង់ព័ត៌មានជាសង្ខេបប្រចាំថ្ងៃតាមវិទ្យុជាតិនិងវិទ្យុអន្តរជាតិ រាយការណ៍ជូនតំណាងបក្សហើយសរុបសភាពការណ៍ក្នុងមួយអាទិត្យម្តង ។ ក្រោយមកខ្ញុំទទួលភារកិច្ចក្នុងមន្ទីរតំណាងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជានៅបរទេសដែលមានបង វ៉ាន់ ជាប្រធាន ។

ទន្ទឹមនឹងភារកិច្ចខាងលើនេះ ខ្ញុំនៅមានភារកិច្ចតាមដានអត្ថបទបកប្រែជាភាសាបារាំងនៃទីភ្នាក់ងារព័ត៌មាន«អា.កា.អ៊ី» ។ មន្ទីររបស់យើងនៅជាប់រួមជាមួយមន្ទីរវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជាដែលមានបង វ៉ា ជាចាងហ្វាងវិទ្យុ ។ បង វ៉ា ក៏បំពេញនាទីជាតំណាងបង វ៉ាន់ ប្រធានមន្ទីរតំណាងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តនៅបរទេស ។ រយៈកាលដំបូងខ្ញុំរស់នៅបំពេញភារកិច្ចនៅតំបន់ទី១ ដោយជ្រះស្រឡះរីករាយ ។ បក្សបានស៊ិតស៊្រាញបន្តអប់រំកសាងថែបំប៉នខ្លួនខ្ញុំទាំងខាងទស្សនៈទាំងខាងគោលជំហរ ។ ខ្ញុំកាន់តែក្តាប់បានកាន់តែជ្រួតជ្រាបបានមួយកម្រិតថែមទៀតនូវមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្សក្នុងភារកិច្ចសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យព្រមទាំងនូវគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។

ក្នុងរយៈពេលរស់នៅតំបន់ទី១នេះ ខ្ញុំមានការខ្វះខាតធំៗពីរដែលប៉ះពាល់ដល់ភារកិច្ចបដិវត្តន៍របស់ខ្ញុំ ១) ចាប់ពីដើមឆ្នាំ១៩៧៥ ខ្ញុំចាប់មានមនោសញ្ចេតនាជាមួយនារីម្នាក់ជាសមាជិកយុវកកធ្វើការក្នុងក្រុមអាននៅវិទ្យុ«សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា» ។ ខ្ញុំបានរាយការណ៍ពីបញ្ហានេះជម្រាបបង វ៉ា តំណាងបក្សជាចាងហ្វាងវិទ្យុ ស្នើសុំរៀបចំគ្រួសារជាមួយនារីនោះ ហើយលែងគ្រួសារខ្ញុំសព្វថ្ងៃជាបរទេស ។ មូលហេតុនៃសេចក្តីសម្រេចចិត្តនេះ គឺម្យ៉ាងដោយឃើញថាមានគ្រួសារបរទេសខ្ញុំមិនអាចទទួលការទុកចិត្តពីសមមិត្តជងគ្នាឬពីបងប្អូនមូលដ្ឋានបានឡើយ ។ ម្យ៉ាងទៀតខ្ញុំយល់ដោយអត្តនោម័តិថាបក្សជំរុញឲ្យបក្ខជនដែលមានគ្រួសារបរទេសលែងគ្រួសារដើមចោលដើម្បីរៀបចំគ្រួសារជាថ្មីឡើងវិញជាមួយវណ្ណៈមូលដ្ឋាន ។ ខ្ញុំយល់ដោយភាន់ច្រឡំនេះជាការលះបង់ធំមួយរបស់ខ្ញុំដើម្បីបក្ស ។ ប៉ុន្តែការលះបង់នេះក៏មិនបរិសុទ្ធដែរ ព្រោះវាជាមធ្យោបាយមួយដើម្បីឲ្យខ្ញុំមានកត្តាសត្យានុម័តិអនុគ្រោះច្រើនទៀតក្នុងការស្វែងរកនាទីនិងឋានៈក្នុងបដិវត្តន៍ ។

ការខុសឆ្គងក្នុងបញ្ហានេះទៀត គឺខ្ញុំមិនបានស្តាប់មតិណែនាំរបស់បងតំណាងបក្សឲ្យរង់ចាំសេចក្តីសម្រេចរបស់បក្ស ។ ខ្ញុំបានទៅស្នើផ្ទាល់នឹងសាមីខ្លួនដែលជាអំពើផ្ទុយស្រឡះពីប្រពៃណីបដិវត្តន៍យើង ។ បច្ច័យនៃអាកប្បកិរិយាខុសឆ្គងនេះ សាមីខ្លួនខ្វល់ខ្វាយច្រើនក្នុងបញ្ហានេះ ព្រោះគាត់នឹកអាណិតដល់វាសនាអនាគតរបស់កូនស្រីរបស់ខ្ញុំពីរនាក់ ។ ជាមួយគ្នានេះក៏គាត់មិនកក់ក្តៅនឹងសីលធម៌របស់ខ្ញុំទៀត ។ គាត់មានមតិថាបើរត់ចោលគ្រួសារទី១ គឺមុខជារត់ចោលគ្រួសារទី២ទៀតហើយ ។ សតិអារម្មណ៍ខ្វល់ខ្វាយនេះនាំឲ្យគាត់បំពេញភារកិច្ចអានអត្ថបទតាមវិទ្យុមិនបានល្អ ប៉ះពាល់យ៉ាងធ្ងន់ដល់មហាចលនាវាយសម្រុកផ្តាច់ព្រាត់លើខ្មាំងនៅដើមឆ្នាំ១៩៧៥ ក្នុងពេលដែលខ្មាំងធ្លើខបាយកលសន្តិសម្ព័ន្ធយ៉ាងមមាញឹក ។

ក្នុងបញ្ហាខុសឆ្គងខាងផ្នែកសីលធម៌នេះបក្សបានអនុគ្រោះសន្តោសធំណាស់ចំពោះខ្លួនខ្ញុំម្តងទៀត ដោយអំណត់អត់ធ្មត់ស៊ិតស៊្រាញកសាងអប់រំធ្វើឲ្យខ្ញុំជ្រះស្រឡះខាងសតិអារម្មណ៍និងភ្ញាក់រលឹកមួយកម្រិតថែមទៀត ខាងនយោបាយបន្តបំពេញភារកិច្ចទៀតរហូតដល់មហាជ័យជម្នះនៅថ្ងៃ១៧ មេសា ១៩៧៥ ។

២.ការខ្វះខាតមួយទៀតគឺស្មារតីសន្តិភាពនិយមខ្វះការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ។

ពីខែមិថុនា ១៩៧៤ មកដល់ខែវិច្ឆិកា ១៩៧៤ នៅតំបន់ទី១ ខ្ញុំរួមប្រជុំជីវភាពអនុសាខាជាមួយអាក្បត់ ហាក់ ស៊ាងឡាយនី ជាមេភ្នាក់ងារចារកម្មសេរីវើសូវៀត កា.ហ្សេ.បេ នៅកម្ពុជា ។ ពេលនោះតាមចម្លើយសារភាពរបស់វាដែលបក្សបានព័ត៌មានឲ្យយើងខ្ញុំដឹងថាបានធ្វើសកម្មភាពបំផ្លាញបដិវត្តន៍កម្ពុជាយើងដោយបង្វែរមាគ៌ាក្នុងការបក«រ៉ូមុាំង»ពីអត្ថបទដែលផ្ញើមកសម្រាប់ផ្សាយវិទ្យុ ។ ខ្ញុំគ្រាន់តែពិនិត្យឃើញភាពលោភលន់ មហិច្ឆតាបុគ្គលរបស់វា ហើយនិងសមានចិត្តវាចំពោះយួនតែប៉ុណ្ណោះ ។ តែដោយធាតុវណ្ណៈដូចគ្នា លោកទស្សនៈបដិវត្តក៏មិនទាន់ច្បាស់ក៏ខ្ញុំមិនអាចឃើញសកម្មភាពក្បត់របស់វា ។

**(នៅមានត)**

# "ប្រាក់ ខន" និងការងារសួរចម្លើយនៅមន្ទីរស-២១


ប្រាក់ ខន

ចម្លើយសារភាពចំនួន៥៣ឯកសារតម្កល់ទុកនៅបណ្ណសារដ្ឋាននៃមជ្ឈមណ្ឌលឯកសារកម្ពុជា មានចុះហត្ថលេខារបស់ឈ្មោះ «ប្រាក់ ខន»។ ក្នុងចំណោមឯកសារទាំងនេះមានឯកសារចំនួន៥១ ដែល ប្រាក់ ខន សរសេរតួនាទីរបស់ខ្លួនថា «អ្នកសួរចម្លើយ» ហើយឯកសារចំនួន២ទៀត ប្រាក់ ខន បានសរសេរតួនាទីរបស់ខ្លួនថា«អ្នកចម្លងឯកសារ»។ គ្រប់ចម្លើយសារភាពទាំងអស់មានចុះកាលបរិច្ឆេទនៃការសួរចម្លើយយ៉ាងជាក់លាក់ ដែលបង្ហាញឲ្យឃើញថា នៅក្នុងឆ្នាំ១៩៧៦ គាត់ (ប្រាក់ខន) បានសួរអ្នកទោសចំនួន៥នាក់។ ក្នុងឆ្នាំ១៩៧៧ គាត់បានសួរអ្នកទោសចំនួន១០នាក់និងសរសេរចម្លងឯកសាររបស់អ្នកទោសចំនួន១នាក់។ ក្នុងឆ្នាំ១៩៧៨ គាត់បានសួរអ្នកទោសចំនួន៣៥នាក់ និងសរសេរចម្លងឯកសាររបស់អ្នកទោសចំនួន១នាក់។ នៅដើមឆ្នាំ១៩៧៩ មុនពេលបានភៀសខ្លួនទៅព្រំដែនថៃ ប្រាក់ ខន បានសួរចម្លើយអ្នកទោសចំនួន១នាក់ទៀត។

មនុស្សទាំង៥១នាក់ដែលបញ្ជូនមកមន្ទីរស-២១ រួចប្រគល់ឲ្យ ប្រាក់ ខន សាកសួរចម្លើយ ត្រូវបានចាប់ខ្លួននៅតាមទីកន្លែងនិងពេលវេលាផ្សេងៗគ្នា។ ភាគច្រើននៃអ្នកទាំងនេះ ជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងជួរខ្មែរក្រហមដែលធ្វើការនៅតាមអង្គភាពក្រសួង-មន្ទីរចំនួន២៣នាក់ ក្នុងជួរកងទ័ពចំនួន១៥នាក់ សមាជិកនិងលេខាស្រុកតំបន់ចំនួន១១នាក់ និងចោទពីបទធ្វើចារកម្មចំនួន២នាក់។ មនុស្សទាំង៥១នាក់នេះមានជាតិសាសន៍ខុសគ្នាៗ ដូចជាៈខ្មែរ៤២នាក់ ញួន៥នាក់ ចិន២នាក់ ចាម១នាក់ និងវៀតណាម១នាក់។

ក្នុងចំណោមឯកសារទាំង៥៣មានតែឯកសារចម្លើយសារភាពចំនួនពីរប៉ុណ្ណោះដែលអាចបង្ហាញថា ប្រាក់ ខន បានចាប់ផ្តើមកិច្ចការសួរចម្លើយនៅមន្ទីរស-២១ ជាលើកដំបូងបង្អស់នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦ និងបញ្ចប់ភារកិច្ចរបស់ខ្លួននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩។ កាលបរិច្ឆេទនេះបើយកមកផ្ទៀងផ្ទាត់ជាមួយនឹងប្រវត្តិរូបរបស់ ប្រាក់ ខន ដែលមានចំនួនពីរទំព័រក៏បានបង្ហាញពីពេលវេលាប្រហាក់ប្រហែលគ្នាដែរ។ ក្នុងប្រវត្តិរូបសរសេរថា «នៅខែ៧ ឆ្នាំ៧៦ ខ្ញុំចូលមកនៅក្នុងអង្គភាព ស-២១»។ ក្រៅពីនេះមានឯកសារចំនួន

បីទៀតដែលត្រូវបានចាត់ទុកជាឯកសារដែលមានសារៈសំខាន់បំផុតព្រោះឯកសារនេះបានពិនិត្យដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ រួចមានចំណារបញ្ជូនទៅថ្នាក់ដឹកនាំនៅស្ថាប័នពាក់ព័ន្ធជាបន្ត ដើម្បីតាមចាប់ខ្លួនក្រុមមនុស្សមានចំនួន ១៣៥នាក់ដែលមានឈ្មោះនៅក្នុងចម្លើយសារភាពទាំងបីនេះ ។ ឯកសារទាំងបីនេះគឺ៖ ១)ឯកសាររបស់អ្នកទោសឈ្មោះ ធូ ហៃ កម្មកររោងចក្រអារឈើ អ-៥ ខស្សរាហកម្មរដ្ឋ មានចំណារ «ផ្ញើជូនស.ម ម៉ុក» លេខាភូមិភាគនិរតីនិងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាទទួលបន្ទុកជាមេបញ្ជាការនៃអគ្គសេនាធិការ ។ ២) ឯកសាររបស់អ្នកទោសឈ្មោះ អែម ម៉ឺន សមាជិកស្រុកបារាយណ៍តំបន់៤២ (ខេត្តកំពង់ធំ) មានចំណារ«ផ្ញើជូនស.ម ពក» លេខាភូមិភាគឧត្តរនិងជាសមាជិកមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជានិងជាគណៈកម្មាធិការអចិន្ត្រៃយ៍ ។ ៣)ឯកសាររបស់អ្នកទោសឈ្មោះ អេង ម៉េងហ៊ាង ហៅ ឆុន ប្រធានគណៈកម្មាធិការថាមពល ជ-២៨ ត្រូវបានចារថា «**សំខាន់ ស្នើក្រសួងពិនិត្យប្រញាប់ ដើម្បីដកវាឲ្យអស់ទើបចូលទៅក្តាប់ក្រសួងពាណិជ្ជកម្ម**» ។

នៅពីលើចម្លើយសារភាពនីមួយៗ ប្រាក់ ខន បានសរសេរសង្ខេបអំពីសកម្មភាពក្បត់របស់អ្នកសារភាពនិងធ្វើសេចក្តីសន្និដ្ឋានផ្សេងៗជូនប្រធានអង្គភាពរបស់គាត់ ដូចជា៖«សកម្មភាពរបស់វានិងបក្ខពួកនៅមានលាក់ពួកមានបណ្តាសក្តិមួយចំនួនទៀត» «ចម្លើយនេះតាំងពីដើមរហូតដល់ចប់ ច្បាស់មធ្យមជាខ្សែសង្វាក់បញ្ហាមិនច្បាស់ដូចមានឈ្មោះខាងលើដែនការនិយាយកម្រិតទាប» ។ ឯកសារចម្លើយសារភាពចំនួន៤ត្រូវបាន ប្រាក់ ខន សរសេរខ្លួនឯងទាំងស្រុងជំនួសអ្នកទោសនោះ ។

ប្រាក់ ខន មានការពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មលើអ្នកទោសដើម្បីយកចម្លើយ ព្រោះមានចំណាររបស់គាត់នៅលើឯកសារចម្លើយសារភាពអ្នកទោស៣នាក់ថា «មនុស្សនេះខ្ញុំអនុវត្តតាមគោលការណ៍សួរបានដោយមិនបាច់វ៉ៃទេ តាំងពីដើមរហូតដល់ចប់» ។ ក្នុងសៀវភៅ«បញ្ជីស្ថិតិរបស់សន្តិបាលស-២១» ដែលជាមេរៀនសម្រាប់បំពាក់បំប៉នយោបាយ អ្នកសួរនៅមន្ទីរ ស-២១ ក៏បានបញ្ជាក់ពីចំណុចនៃការធ្វើទារុណកម្មនេះ «ភារកិច្ចសួរចម្លើយគឺជាភារកិច្ចដែលមានការតស៊ូតឹងតែងរវាងយើងដែលជាអ្នកចង់ដឹងអាថ៌កំបាំងខ្មាំងដែលវាខំប្រើឧបាយកលលាក់សកម្មភាពក្បត់ខ្សែសង្វាក់និងមេកើយវា ។ គឺជាភារកិច្ចការពារប្រទេសដែលប្រកបទៅដោយការតស៊ូវណ្ណៈ តឹងតែង និងក្តៅគំជាប់ជានិច្ច ។ ចំពោះទារុណកម្ម គឺត្រូវទុកទារុណកម្មជាវិធានការមួយសម្រាប់គាបខ្មាំងកុំឲ្យវាគេចចេញពីច្រកសារភាព» ។ ប្រហាក់ប្រហែលគ្នានេះដែរ អ្នកសួរចម្លើយម្នាក់ដែលជាជនជាតិចាមនៅក្នុងមន្ទីរស-២១ ឈ្មោះ «ស៊ីម ម៉េល ហៅ ម៉ាន» ក៏ធ្លាប់បានវ៉ៃអ្នកទោសយកចម្លើយ រហូតដល់ស្លាប់ចំនួន៤នាក់ ។

រហូតមកដល់ពេលនេះ ក៏នៅមានអ្នករងគ្រោះដោយសាររបបខ្មែរក្រហមច្រើនរាប់មិនអស់ដែលនៅជាប់ស្លាកស្នាមរបួសនិងការឈឺចាប់ដោយទារុណកម្មក្នុងពេលសួរចម្លើយ ។

អេល ហ៊ឹម សព្វថ្ងៃនៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល បានក្លាយជាមនុស្សថ្លង់ដោយសារអ្នកសួរចម្លើយខ្មែរក្រហមនៅមន្ទីរ១៨បានវាយគាត់នឹងដំបងដើមឫស្សី ។ គាត់រំឭកឡើងវិញថា«អ្នកសួរបានសួរខ្ញុំឲ្យឆ្លើយពីរឿងរ៉ាវក្បត់ ខ្ញុំមិនបានក្បត់អីទេ ខ្ញុំឆ្លើយថាមិនក្បត់ ពេលនោះពួកវាយកព្រនង់ដើមពីងពង់ (ឫស្សីពីងពង់) ប៉ុនកំភួនដៃ វ៉ៃខ្ញុំ រហូតខ្ញុំសន្លប់ ពេលខ្ញុំដឹងខ្លួនខ្ញុំស្តាប់លែងឮអ្វីទាំងអស់ ។ អីចឹងបានជាពួកនោះលែងសួរខ្ញុំទៀត ហើយឲ្យខ្ញុំធ្វើការជាអ្នកយាមមន្ទីរនោះ ។ ចាប់ពីពេលនោះមករហូតដល់សព្វថ្ងៃនេះខ្ញុំស្តាប់អ្វីក៏មិនឮដែរ» ។ វ៉ាន់ ណាត ជាអតីតអ្នកទោសមន្ទីរ ស-២១ដែលមានវាសនារួចខ្លួនពីស្លាប់ដោយសារអាជីពគូរគំនូររបស់គាត់ បានពិពណ៌នាថា «ខ្ញុំត្រូវបានអ្នកសួរចម្លើយសួរខ្ញុំនៅគុកតំបន់៤ មុនបញ្ជូនខ្ញុំមកទួលស្លែង ។ ខ្ញុំមិនបានក្បត់អីទេ អីចឹងខ្ញុំគ្មានអីឆ្លើយពីសកម្មភាពក្បត់ ពេលខ្ញុំមិនឆ្លើយនោះហើយអ្នកសួរបានឆក់ខ្សែភ្លើងខ្ញុំ ។ ដំបូងខ្ញុំនៅលើកៅអី ប៉ុន្តែក្រោយមកខ្ញុំប្រកាច់ធ្លាក់ពីលើកៅអី ខ្ញុំលែងដឹងអ្វីទាំងអស់ ពេលខ្ញុំដឹងខ្លួនពួកវាយកទឹកជះមុខខ្ញុំហើយសួរខ្ញុំបន្តទៀត» ។

នៅពេលដែលសួរ វ៉ាន់ ណាត ថា «តើអ៊ំគិតថាអ្នកសួរចម្លើយខ្មែរក្រហមទាំងអស់ជាមនុស្សសាហាវដែរឬទេ?» គាត់ឆ្លើយថា «ពិបាកនិយាយណាស់ មិនដឹងជាចរិតមនុស្សនោះ

យ៉ាងម៉េចទេ ។ ប៉ុន្តែភាគច្រើនក្មេងៗធ្វើការនៅតាមគុកខ្មែរក្រហមសុទ្ធតែគ្មានការអប់រំ» ។ គាត់បញ្ជាក់ទៀតថា «ខ្ញុំបានឃើញអ្នកទោសស្លាប់នៅក្នុងបន្ទប់ដែលខ្ញុំជាប់ឃុំឃាំងនៅទួលស្លែង ហើយក្មេងតូចៗនោះទាត់ក្បាលសាកសពលេង រួចដេរប្រមាថសាកសពនោះ» ។ នៅលើចម្លើយសារភាពរបស់ សុខ វ៉ា និង នៅ កន្ថា ជាអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ដូច ប្រាក់ ខន ដែរ តែក្រោយមកត្រូវបានចាប់ខ្លួន រួចបានឆ្លើយពីសកម្មភាពអសីលធម៌ផ្សេងៗដែលនឹកស្មានមិនដល់ នៅពេលគាត់បានធ្វើទារុណកម្មទៅលើអ្នកទោសភេទស្រី ។

តាមរយៈប្រវត្តិរូបពីរទំព័ររបស់ ប្រាក់ ខន នៅក្នុងបណ្ណសារដ្ឋាននៃមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញផ្លូវឲ្យខ្ញុំអាចទៅជួប ប្រាក់ ខន ។ ប្រភពជាច្រើនបានអះអាងដូចៗគ្នាអំពីចរិតឃោរឃៅនៃអ្នកសួរចម្លើយខ្មែរក្រហម ។ ខ្ញុំស្ទើរតែមិនជឿខ្លួនឯងនៅពេលដែលខ្ញុំបានជួបអតីតអ្នកសួរចម្លើយខ្មែរក្រហមដែលប្រជាជនទូទៅខ្លាចរអាគួរឲ្យញាក់សាច់គ្រប់ៗគ្នា ។ ខ្ញុំបានឃើញគាត់មានអាកប្បកិរិយាស្លូតបូត ដឹងខុសដឹងត្រូវ និងរួសរាយដូចមនុស្សធម្មតា គ្មានអ្វីគួរឲ្យខ្ញុំខ្លាចគាត់នោះទេ ។


ប្រាក់ ខន

ប្រាក់ ខន ទទួលខ្ញុំយ៉ាងរាក់ទាក់ និងកក់ក្ដៅ ។ គាត់អញ្ជើញខ្ញុំឡើងលើផ្ទះរបស់គាត់ ដោយមានក្រាលកន្ទេលក្រហមយ៉ាងស្អាត ។ បន្ទាប់ពីខ្ញុំណែនាំឲ្យគាត់ស្គាល់រូបខ្ញុំ ខ្ញុំបានយកប្រវត្តិរូបរបស់គាត់បង្ហាញ ហើយអានឲ្យគាត់ស្ដាប់ ។ គាត់ប្រាប់ខ្ញុំថា ត្រូវហើយព្រោះនេះជាប្រវត្តិរូបរបស់គាត់ គាត់បានសរសេរខ្លួនឯងនៅពេលដែលចូលធ្វើការនៅក្នុងមន្ទីរស-២១ ។ គាត់បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំអំពីកិច្ចការសព្វបែបយ៉ាងដែលគាត់បានជួបប្រទះនៅមន្ទីរស-២១ ។ ប៉ុន្តែទោះជានៅលើឯកសារមានឈ្មោះគាត់ និងបញ្ជាក់តួនាទីថា «អ្នកសួរចម្លើយ» ក៏ដោយក៏គាត់នៅតែបដិសេធអំពីតួនាទីទាំងនេះ ។ គាត់បានរៀបរាប់ថា «មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅកងកាំភ្លើងធំ ១៣៨នៃកងពល១២ ដែលមាន តាណាត ជាប្រធាន (ក្រោយមកហៅថាកងពល ៧០៣) ។ ពេលកម្លាំងខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញកម្លាំងយោធាក្នុងកងពល១២គ្មានភារកិច្ចវាយខ្មាំងទៀត កម្លាំងយោធាទាំងអស់ត្រូវចុះធ្វើស្រែ ។ ខ្ញុំដំបូងធ្វើស្រែនៅម្ដុំក្របៅ ក្រអាត់ អាចម៍កុក ប្រហែលជាក្នុងស្រុកកណ្ដាលស្ទឹង ។ ពេលធ្វើនោះ អង្គការដកខ្ញុំឲ្យមករុះរើផ្ទះនៅតាមទំនប់បឹងទំពុន ។ ក្រោយពីនោះមកនៅរដូវវស្សាក្នុងឆ្នាំ១៩៧៥ អង្គការបានយកខ្ញុំទៅធ្វើស្រែនៅព្រៃស (មន្ទីរស-២១យ ឬមន្ទីរ២៤) ។ កាលនោះដូចថាខ្ញុំមិនបានប្រព្រឹត្តអ្វីខុសច្បាប់ទម្លាប់របស់គេ ធ្វើស្រែនៅព្រៃសបានមួយឆ្នាំអង្គការឲ្យខ្ញុំមកនៅមន្ទីរស-២១» ។

តាមការស្រាវជ្រាវស្ដីពីប្រវត្តិកម្មាភិបាលខ្មែរក្រហមនៅមន្ទីរស-២១ អៀ ម៉េងទ្រី បានកត់សម្គាល់ឃើញថាគ្រប់កម្មាភិបាលដែលបានមកធ្វើការនៅមន្ទីរស-២១ សុទ្ធតែឆ្លងកាត់ការអប់រំនយោបាយ និងហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយ៉ាងហ្មត់ចត់នៅតាមមន្ទីរយោធា នៅតាខ្មៅ បឹងទំពុន និងព្រៃស ។ ប៉ុន្តែ ប្រាក់ ខន ពុំបាននិយាយពីការទទួលអប់រំនយោបាយ ឬហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រនៅកន្លែងណាមួយឡើយ ។

ប្រាក់ ខន បន្តទៀតថា «ខ្ញុំមកនៅស-២១ បាន៥-៦ខែ ធ្វើជាអ្នកយាមនៅខាងក្រៅរបងបរិវេណមន្ទីរ ហើយខ្ញុំមានរបួសស៊េរីពីមុនមកដែលខ្ញុំបានច្បាំងជាមួយទាហាន លន់ ណុល ខ្ញុំកើតរោគស្ពឹកមួយចំហៀងខ្លួន ភ្នែកម្ខាងក៏មើលព្រាល ដកដង្ហើមក៏តឹងម្ខាង អង្គការក៏ឲ្យខ្ញុំទៅដេកពេទ្យកេតុមាលានិងពេទ្យមុនីវង្ស ហើយមានគ្រូពេទ្យជនជាតិចិនមើលខ្ញុំផ្ទាល់ ។ ខ្ញុំដេកពេទ្យទាល់តែវៀតណាមចូលមកក្នុងឆ្នាំ១៩៧៩» ។ ប្រាក់ ខន បាននិយាយដដែលៗថា «ខ្ញុំនៅការពារមន្ទីរស-២១ បានតែ

៥-៦ខែទេ រួចខ្ញុំចេញមកដេកពេទ្យប្រហែលជាក្នុងឆ្នាំ១៩៧៧» ។ នៅពេលដែលបង្ហាញឯកសារចម្លើយសារភាពរបស់អ្នកទោសម្នាក់ដែលគាត់បានសួរចម្លើយ គាត់បានឆ្លើយថា «អូ! ខ្ញុំនឹកឃើញហើយអ្នកទោសខ្លះអក្សរស្អាត អ្នកខ្លះអក្សរមិនសូវស្អាត ហើយគេឲ្យខ្ញុំកត់ចម្លង អាខ្លះកត់ចម្លងដោយដៃ អាខ្លះកត់ចម្លងអង្គុលីលេខ ហើយដល់ខ្ញុំចម្លងឯកសារនេះ ខ្ញុំដាក់ថាអ្នកសួរតែម្តងទៅ ហើយបញ្ជូនឲ្យគេទៅ មានតែអ៊ីចឹង» ។ ប៉ុន្តែជាមួយគ្នាក៏បានលាន់មាត់ថា «ខ្ញុំមិនដឹងថាគាត់ (ប្រាក់ ខន) ធ្វើអ្វីទេនៅក្នុងជំនាន់អាពត ព្រោះខ្ញុំរៀបការក្រោយបែក៧៩ នេះ គាត់មិនដែលនិយាយប្រាប់ខ្ញុំសោះ» ។

ប្រាក់ ខន មិនបានសារភាពពីកំហុសរបស់គាត់ដោយផ្ទាល់មែន ប៉ុន្តែគាត់សម្តែងនូវការសោកស្តាយយ៉ាងខ្លាំង ។ គាត់បាននិយាយថា «ប្រវត្តិខ្ញុំជូរចត់ណាស់ ខ្ញុំកែប្រែ ខ្ញុំតូចចិត្តខ្លួនឯងណាស់ ប៉ុន្តែក្រោយពីហ្នឹងមកខ្ញុំមិនដែលធ្វើអំពើអាក្រក់




**រូបថតខាងលើនេះគឺជាអ្នកទោសដែល ប្រាក់ ខន បានសួរចម្លើយ ហើយក្រោយមកត្រូវបានយកទៅសម្លាប់ចោលទាំងអស់**

អក្សរនៅលើចម្លើយសារភាពនេះជាអក្សរសរសេរដៃទាំងអស់ដែលមិនដូចគ្នាទៅនឹងអក្សររបស់គាត់ ។

នៅពេលដែលខ្ញុំសួរថា មានអ្នកធ្វើការនៅទួលស្លែងជាជនជាតិចាមទេ? គាត់បានឆ្លើយថា «ខ្ញុំស្គាល់អាម៉ាន (ស៊ីម ម៉េល ហៅ ម៉ាន) ជាជនជាតិចាម អាហ្នឹងវ៉ៃគេ(អ្នកទោស) ផាប់ដាច់ចម្លើយហើយក្រោយមកគេចាប់វា រួចយកទៅសម្លាប់វិញ» ។ តាមបញ្ជីកម្ទេច ម៉ាន ត្រូវបានកម្ទេចនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ។ ហើយ ប្រាក់ ខន និយាយថា «ខ្ញុំចេញពីមន្ទីរ ស-២១ នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំលែងដឹងអ្វីទៀតហើយ» ។ ប៉ុន្តែប្រាក់ ខន បានដឹងរឿងរ៉ាវ នៃការសម្លាប់ ម៉ាន នៅថ្ងៃ៣០ ខែមេសា ឆ្នាំ១៩៧៨ ។ «ពេលពួថាសម្លាប់ម៉ាន ខ្ញុំនៅក្នុងមន្ទីរនោះដែរ» គាត់និយាយ ។ ជាងនេះទៅទៀតលើចម្លើយសារភាពចំនួន៩១៦ឯកសារ គឺមានឈ្មោះ ហត្ថលេខារបស់ ប្រាក់ ខន ដោយមានតួនាទីបញ្ជាក់ថា «អ្នកសួរចម្លើយ» តាំងពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩ ។ ប្រពន្ធរបស់ ប្រាក់ ខន ដែលកំពុងអង្គុយទៀតទេ ខ្ញុំរកស៊ីដោយសុចរិត កាលហ្នឹងច្បាប់របស់គេវាអ៊ីចឹង បើខ្ញុំមិនធ្វើអ៊ីចឹងគេសម្លាប់ខ្ញុំ ។ ពេលនេះខ្ញុំដឹងខ្លួនខ្ញុំខុសខ្ញុំមិនអនុវត្តទៀតទេ ខ្ញុំដឹងថារឿងនោះវាធំណាស់ ខ្ញុំមិនអាចនិយាយកើតទេ ។ ឥឡូវនេះខ្ញុំស្អប់ណាស់កាំភ្លើង បើអ្នកណាឲ្យខ្ញុំក៏ខ្ញុំមិនហ៊ានយកដែរ» ។

សព្វថ្ងៃនេះ ប្រាក់ ខន មានអាយុ៤៨ឆ្នាំ ។ គាត់ជាមេគ្រួសារដ៏ធំមួយដែលមានកូនចំនួន៩នាក់ក្នុងបន្ទុក ។ គ្រួសារនេះរស់នៅក្នុងភូមិដាច់ស្រយាលមួយក្នុងទឹកដីខេត្តតាកែវ ។ គាត់ប្រកបមុខរបរដូចញាតិដូរផលដំណាំកសិកម្មនិងធ្វើស្រែ ។ ជីវភាពរបស់គាត់មានលក្ខណៈបង្គួរ ។ គាត់និងប្រពន្ធរបស់គាត់មានសភាពរួសរាយរាក់ទាក់ ហើយអ្នកភូមិជិតខាងស្រឡាញ់រាប់អានគាត់ គ្មានអ្នកណាម្នាក់បានដឹងប្រវត្តិជូរចត់របស់គាត់ក្នុងអតីតកាលនោះឡើយ ។ ចុងក្រោយគាត់បាននិយាយថា «បើថ្ងៃណាមួយមានតុលាការរកយុត្តិធម៌ឲ្យប្រជាជានក្នុងជំនាន់ ប៉ុល ពត ខ្ញុំហ៊ានធ្វើជាសាក្សី ខ្ញុំខ្លាចអីនឹងនិយាយបើខ្ញុំឃើញអ៊ីចឹងមែន» ។ តើអ្វីទៅជាយុត្តិធម៌សម្រាប់ ប្រាក់ ខន?

**អ៊ីសា ឧស្មាន**

# រណ្តៅសាកសពប្រល័យពូជសាសន៍ នៅខេត្តបន្ទាយមានជ័យ

ស្រុកថ្មពួកជាទីតាំងមួយក្នុងចំណោមស្រុកនានាក្នុងខេត្តបន្ទាយមានជ័យ ជាកន្លែងដែលពួកខ្មែរក្រហមអនុវត្តនយោបាយកាប់សម្លាប់ប្រជាជនយ៉ាងសាហាវក្នុងរយៈកាលនៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យបន្សល់ទុករណ្តៅសាកសពជាច្រើននៅក្នុងស្រុកថ្មពួកនេះ ។ ស្រុកនេះមានចម្ងាយ ៤៣គីឡូម៉ែត្រ ពីទីរួមខេត្តបន្ទាយមានជ័យ បើគិតពីរយៈពេលនៃការធ្វើដំណើរដោយរថយន្តគឺត្រូវចំណាយពេលអស់រយៈពេល ៤ម៉ោងទើបទៅដល់ ព្រោះផ្លូវមានការលំបាកបន្តិចក៏ប៉ុន្តែសន្តិសុខតាមផ្លូវក៏មានលក្ខណៈល្អប្រសើរ ។

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៩ ម៉ោង១២ៈ៣០ រសៀល ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់ស្រុកថ្មពួកផ្ទាល់ដើម្បីសាកសួរនិងថតបញ្ចូលទីតាំងទាំងនោះទៅក្នុងប្រព័ន្ធទិន្នន័យ ។

ការចុះយកទិន្នន័យនៃទីតាំងប្រល័យពូជសាសន៍នេះត្រូវបានថតទុកនៅក្នុងប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកក្នុងឯកសារលេខR០៦២២០៨A សម្រាប់ធ្វើការបំប្លែងទៅជាចំណុចទីតាំងលើផែនទីប្រទេសកម្ពុជាទាំងមូល តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងនៅសាកលវិទ្យាល័យញូវសៅវែលទីក្រុងស៊ីដនីប្រទេសអូស្ត្រាលី និងសាកលវិទ្យាល័យយែលនៅសហរដ្ឋអាមេរិក ។

ទីតាំងភូមិសាស្ត្រស្រុកថ្មពួកស្ថិតនៅភាគឦសានឆៀងខាងជើងពីទីរួមខេត្តបន្ទាយមានជ័យចម្ងាយ៤៣គីឡូម៉ែត្រ ព្រំប្រទល់ខាងលិចជាប់នឹងប្រទេសថៃ ខាងកើតជាប់ស្រុកភ្នំស្រុក ខាងត្បូងជាប់ស្រុកស្វាយចេក ខាងជើងជាប់ស្រុកបន្ទាយអំពិល ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទីតាំងនេះស្ថិតនៅតំបន់៥ ភូមិភាគពាយ័ព្យ ។ នៅក្នុងស្រុកថ្មពួកនេះមានទីតាំងរណ្តៅសាកសពបីកន្លែងធំៗ៖

**១) បន្ទាយទាហាន**

បន្ទាយនេះមានទីតាំងស្ថិតនៅខាងជើងសាលាស្រុកចម្ងាយ៧០០ម៉ែត្រ ឋិតក្នុងចំណុចប្រសព្វរវាងខ្សែបណ្តោយ ១០៣°០២'៥៩០២" និងខ្សែស្រប១៣°៥៦'៥៣០៥" ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកសព្វថ្ងៃនេះ បន្ទាយនេះគឺជាទីតាំងកងពលធំលេខ៧ប្រចាំស្រុកថ្មពួក ក្បែរបន្ទាយនោះមានចំនួន៤រណ្តៅ ។ រណ្តៅនីមួយៗមានទំហំ៨ម៉ែត្រ ទទឹង៣ ម៉ែត្រ ជម្រៅ២ម៉ែត្រ ក្នុងចំណោមរណ្តៅទាំងបួននោះមានរណ្តៅតែមួយទេដែលបានគាស់រណ្តៅមួយចំនួនទៀតនៅមានអដ្ឋិធាតុជនរងគ្រោះនៅឡើយ ។


ឯក សន្ធាត

លោក ឯក សន្ធាត អាយុ ៤៧ឆ្នាំ មានស្រុកកំណើតនៅភូមិអណ្តូងថ្ម ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបាត់ដំបង (បច្ចុប្បន្នបន្ទាយមានជ័យ) លោកមានតួនាទីជាប្រធានមន្ទីរស្រុកថ្មពួកខេត្តបន្ទាយមានជ័យ លោកក៏ជាជនរងគ្រោះម្នាក់ដែលបានរួចជីវិតពីរបបខ្មែរក្រហម ។ លោក សន្ធាត បានប្រាប់ថា ខ្ញុំបានដឹងរឿងខ្លះៗអំពីសកម្មភាពសម្លាប់របស់ពួកខ្មែរក្រហមនៅមន្ទីរសន្តិសុខស្រុកថ្មពួកនេះមានបីដំណាក់កាល៖ ដំណាក់កាលទី១ គឺពួកខ្មែរក្រហមបានចាប់ប៉ូលិសទាហាន អ្នកដែលមាននិន្នាការសម័យ លន់ ណុល ឬក៏ពួកនិស្សិត ពួកអ្នកមាន សក្តិភូមិ នាយទុន យកទៅដាក់នៅមន្ទីរសន្តិសុខ អ្នកដែលជាប់នៅទីនេះទាំងប៉ុន្មានគឺសម្លាប់ចោលទាំងអស់គ្មាននរណាម្នាក់មានភ័ព្វសំណាងរួចផុតពីការសម្លាប់នេះទេ ។ ដំណាក់កាលទី២ គឺពួកខ្មែរក្រហមបានចាប់យកប្រជាជននៅតាមមូលដ្ឋានទៅដាក់នៅមន្ទីរសន្តិសុខនេះដែរ ដោយសារ



លោកអ៊ឹ ហាប់ ស្វាង និង លោក ឯក សង្វាត កំពុងបង្ហាញពីរណ្តៅសាកសពនៅបន្ទាយ

កំហុសបន្តិចបន្តួច ដូចជាដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយក៏មានរបបលើសដោយមានត្រីប្តកាមខ្យង លើសអ្នកដទៃបន្តិចពួកខ្មែរក្រហមចាប់ដាក់មន្ទីរសន្តិសុខយកទៅសម្លាប់ចោល ប៉ុន្តែជនរងគ្រោះទាំងនោះត្រូវបានយកទៅសម្លាប់ចោលនៅកន្លែងផ្សេងៗ ដំណាក់កាលទី៣ គឺពួកខ្មែរក្រហមប្រើល្បិចកលជម្លៀសប្រជាជនចេញពីមូលដ្ឋានតាមសាខានីមួយៗមានចំនួនពី៥គ្រួសារទៅ១០ គ្រួសារ គឺឲ្យទៅដាំក្រចៅ កប្បាស នៅតាមមាត់ទន្លេ ជាកន្លែងសម្បូរហូបគ្រប់គ្រាន់ៗ តាមពិតប្រជាជនទាំងនោះត្រូវបានយកទៅសម្លាប់ចោលនៅបន្ទាយទាហានថ្មពួកដែលជាកន្លែងសន្តិសុខជិតវិទ្យាល័យថ្មពួកសព្វថ្ងៃនេះ(ប្រាំថ្ងៃបន្ទាប់ពីបាត់ខ្លួនទើបដឹងថាប្រជាជនដែលគេយកទៅត្រូវបានសម្លាប់នៅបន្ទាយទាំងអស់)ៗ នៅដើមឆ្នាំ១៩៧៧ ពួកនិរតីបានចូលមក ហើយចោទថាពួកពាយ័ព្យសុទ្ធតែជាពួកក្បត់ចាប់គណៈស្រុកចាស់យកទៅសម្លាប់ចោលរួចបញ្ចូលគណៈស្រុកថ្មីវិញៗ ពួកនិរតីនេះក៏បានប្រើនយោបាយមួយ គឺហៅកម្មាភិបាលតូចធំរបស់ពួកពាយ័ព្យមកប្រជុំ អ្នកតូចជម្លៀសចេញ តែធាតុពិតយកទៅសម្លាប់ចោលទាំងអស់ៗ ក្រោយពីកម្ចាត់ពួកកម្មាភិបាលពាយ័ព្យចេញអស់ពួកនិរតីបានបន្តនយោបាយចាប់ផ្តើមសម្លាប់ប្រជាជនមូលដ្ឋានម្តងៗ

លោក សង្វាត បន្ថែមទៀតថាៈ កាលពីឆ្នាំ១៩៨២ រដ្ឋាភិបាលមានគោលការណ៍ប្រមូលឆ្អឹងទុក ហើយខ្លួនខ្ញុំបានចូលរួមគាស់យកឆ្អឹងទាំងនោះដោយផ្ទាល់ដៃជាមួយលោក ហាប់ ស្វាង ដោយប្រមូលយកអដ្ឋិធាតុដែលគាស់បានទៅដាក់ស្តូបមួយតម្កល់នៅវត្តពោធិវាល ស្រុកថ្មពួក សង់ជាខ្ទមមួយប្រក់ស្បូវ មានទំហំ ២ម៉ែត្របួនជ្រុងៗ ពេលដែលគាស់នោះសាកសពពុំទាន់រលួយអស់ទេ ខ្ញុំឃើញមានកន្សែងរុំមុខ ចំណងដៃនៅជាប់នឹងរាងកាយជនរងគ្រោះនៅឡើយៗ ប៉ុន្តែឆ្អឹងដែលគាស់បានទាំងនោះត្រូវបំផ្លាញអស់ មូលហេតុថានៅឆ្នាំ១៩៨៥ ពួកខ្មែរក្រហមបានចូលមកដុតផ្ទះសម្បែងប្រជាជន ហើយដុតស្តូបដែលតម្កល់អដ្ឋិធាតុចោលទៀតដើម្បីបំបាត់ភស្តុតាងៗ តាមការប៉ាន់ស្មាន អដ្ឋិធាតុតម្កល់នៅស្តូបដែលត្រូវ ពួកខ្មែរក្រហមដុតចោលនោះមានចំនួនប្រហែល៧០០នាក់ដែល៤០០នាក់គាស់មកពីបន្ទាយ និង៣០០នាក់ទៀតគាស់មកពីអណ្តូងសេបដេងៗ


ហាប់ ស្វាង

លោកអ៊ឹ ហាប់ ស្វាង អាយុ៦៩ ឆ្នាំ មានស្រុកកំណើតនៅវត្តចាស់ ស្រុកថ្មពួក ឃុំថ្មពួក ខេត្តបាត់ដំបង បច្ចុប្បន្ន (ខេត្តបន្ទាយមានជ័យ) ។ នៅសម័យ ប៉ុល ពត លោកអ៊ឹ រស់នៅស្រុកកំណើតដដែល ជាគ្រូសង្គមកិច្ចនៅស្រុកថ្មពួក និងជាអ្នកមើលជំងឺឲ្យប្រជាជនដូចជា ជំងឺហើម រាគរូស គ្រុនក្តៅ និងជាគ្រូផ្សំថ្នាំខ្មែរប្រចាំការនៅក្នុងមន្ទីរពេទ្យនេះមាននារជាអ្នកមើលជំងឺហើម រាគរូស ក្តៅ ឬស្រ្តីរាំងរដូវ ។ លោកអ៊ឹក៏ជាអ្នកចូលរួមគាស់យកអដ្ឋិធាតុជាមួយលោក ឯក សន្ធាត ដែរ ។ ទាក់ទិននឹងរណ្តៅសាកសពនេះ លោកអ៊ឹ ស្វាង បាននិយាយថាៈ ខ្មែរក្រហមបានយកលេសថាជម្លៀសប្រជាជនចេញទៅដាំកប្បាស ក្រចៅ តាមពិតពួកខ្មែរក្រហមចាប់ទាំងគ្រួសារៗ ទៅដាក់បញ្ចូលក្នុងរោងមួយដ៏ធំបិទជិតឈើង រោងនេះពួកខ្មែរក្រហមហៅថា «សាលមហោស្រព» ដែលអាចដាក់មនុស្សបានចំនួនប្រហែល៥០០០នាក់ ដល់ពេលយប់ពួកវាយកឡានមកដឹកបើកចុះបើកឡើង ថាដឹកប្រជាជនដែលត្រូវជម្លៀសចេញទៅរកកន្លែងណាដែលសម្បូរហូបចុក ការពិតប្រជាជនទាំងនោះត្រូវចាប់យកទៅសម្លាប់នៅបន្ទាយទាហានទាំងអស់(បន្ទាយកងពលធំលេខ៧ប្រចាំស្រុកថ្មពួក) ។

## ២) អណ្តូងសែបផេង

អណ្តូងនេះមានទីតាំងស្ថិតនៅក្នុងចំណុចប្រសព្វរវាងខ្សែបណ្តោយ ១០៣°០២'៤៥២៥ និងខ្សែស្រប ១៣°៥៥'០២២” តាមការកត់ត្រាដោយប្រព័ន្ធកំណត់ទីតាំងភូមិសាស្រ្តពិភពលោក ស្ថិតនៅក្នុងភូមិពក្វាក់ ឃុំគំរូ ស្រុកថ្មពួក ចម្ងាយប្រហែល១,៥គីឡូម៉ែត្រពីសាលាស្រុកថ្មពួក អណ្តូងនេះមានជម្រៅ១០ម៉ែត្រ ទំហំ៨ម៉ែត្របួនជ្រុង ។

តាមប្រសាសន៍របស់លោក សន្ធាត ថា អណ្តូងសែបផេង ពួកខ្មែរក្រហមក៏បានយកប្រជាជនដែលជាប់នៅមន្ទីរសន្តិសុខមកទម្លាក់ក្នុងអណ្តូងសែបផេងនេះដែរ ។ ហើយខ្លួនគាត់ក៏បានចូលរួមគាស់អដ្ឋិធាតុរបស់ជនរងគ្រោះនៅអណ្តូងនេះបានចំនួនជាង៣០០យកទៅដាក់នៅវត្តពោធិវាលថ្មពួក ប៉ុន្តែអដ្ឋិធាតុទាំងនោះត្រូវបានដុតបំផ្លាញព្រមជាមួយនឹងអដ្ឋិធាតុនៅបន្ទាយទាហានដែរ ។

លោកអ៊ឹ ហាប់ ស្វាង បានបញ្ជាក់បន្ថែមថា អណ្តូងនេះជ្រៅណាស់ ពេលពួកខ្មែរក្រហមយកប្រជាជនទៅសម្លាប់ម្តង ពួកវាយកស្លឹកដូងគ្របពីលើមួយជាន់ ពេលសម្លាប់លើកក្រោយគ្របមួយជាន់ទៀត ។ ការគ្របស្លឹកនេះមានកម្រាស់ប្រហែលជា៧ជាន់ លោកអ៊ឹអាចដឹងបានដោយសារលោកអ៊ឹជាអ្នកគាស់អដ្ឋិធាតុជាមួយលោក ឯក សន្ធាត ដោយផ្ទាល់កាលពីឆ្នាំ១៩៨២ ។

## ៣) ត្រពាំងស្នួលៈ

មានរណ្តៅសាកសពពីរកន្លែងនៅក្នុងទីតាំងត្រពាំងស្នួល ។ ត្រពាំងស្នួលជាទីតាំងសម្លាប់ស្ថិតនៅក្នុងភូមិដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក មានចម្ងាយប្រហែល៧៥០០ម៉ែត្រ ពីទីរួមស្រុក ចុះពីផ្លូវលេខ៦៩Aប្រហែលជា២៥០ម៉ែត្រតាមបន្ទាយទាហានទីតាំង«ត្រពាំងស្នួល»នេះស្ថិតក្នុងចំណុចប្រសព្វរវាងខ្សែបណ្តោយ១០៣°០៤'០៥៥៩”និងខ្សែស្រប១៤០°'៤៤៥១” កត់ត្រាដោយប្រព័ន្ធកំណត់ទីតាំងភូមិសាស្រ្តពិភពលោក ។ លោក ឯក សន្ធាត ប្រាប់ថា រណ្តៅទាំងពីរនេះដំបូងលោកមិនស្គាល់ទេ លោកបានពឹងឲ្យលោក គី គាវ អនុសេនីយ៍ឯក មេបញ្ជាការខាងវិស្វកម្មF7 ជូនទៅ ពីព្រោះគាត់បានដឹងនិងស្គាល់រណ្តៅនៅទីតាំង«ត្រពាំងស្នួល»នេះច្បាស់ ។ រណ្តៅពីរនេះដំបូងត្រូវបានពួកអ្នកស្រុកគាស់រកមាសស្រាប់តែប្រទះឃើញសុទ្ធតែអដ្ឋិធាតុជនរងគ្រោះដែលខ្មែរក្រហមបានសម្លាប់ ដោយមានបន្សល់ទុកនូវឆ្អឹងតូចៗ ក្រណាត់ខោអាវខ្វះជាសម្គាល់ ។ ហើយក៏នៅមានរណ្តៅសម្លាប់ច្រើនទៀតដែលរូបលោកពុំបានដឹងតួយ៉ាងដូចជារណ្តៅទាំងពីរខាងលើ ។ ខ្មែរក្រហមយកប្រជាជនទៅសម្លាប់សុទ្ធតែលាក់ការណ៍ពុំឲ្យប្រជាជនដឹង ហេតុដូច្នេះហើយ បានជាលោកមានការលំបាកក្នុងការស្វែងរករណ្តៅសាកសពទាំងនោះ ។

មកដល់ឆ្នាំ២០០០នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញភស្តុតាងប្រល័យពូជសាសន៍នៅក្នុងខេត្តបន្ទាយមានជ័យចំនួន២៥កន្លែងរួចមកហើយ ។

**លី សុផល**

# ខួបឆ្នាំទី២៥នៃកំណើតបក្ស កុម្មុយនិស្តកម្ពុជា

## ញត្តិរបស់យុវជនយុវនារីជូនពរបក្ស

***(ទស្សនាវដ្ដី "យុវជននិងយុវនារីបដិវត្ត" នៃរបបកម្ពុជាប្រជាធិបតេយ្យ លេខ៩ ខែកញ្ញា ឆ្នាំ១៩៧៦)***

**(តពីលេខមុន)** នេះជាពិសោធន៍ជាក់ស្ដែងដែលចេញពីសាច់ឈាមស្រស់របស់ប្រជាជាតិ ប្រជាជន និងយុវជនយុវនារីកម្ពុជាយើង ហើយក៏ជាមាគ៌ាដ៏ត្រឹមត្រូវភ្លឺស្វាងនិងល្បីខ្ទរខ្ទារទាំងនៅក្នុងប្រទេស ទាំងនៅលើសកលលោករបស់បក្សកុម្មុយនិស្តកម្ពុជាយើងដែរ ។

ដូច្នេះ ក្នុងឱកាសបុណ្យខួបកំណើតបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងនាថ្ងៃ៣០ កញ្ញា ១៩៧៦ នេះ ដែលជាខួបកំណើតឆ្នាំទី២៥ ដែលបក្សឈានចូលដំណាក់កាលថ្មីនៃបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសជាខ្សែសង្វាក់តាមផែនការត្រឹមត្រូវហ្មត់ចត់របស់បក្ស យុវជន-យុវនារីបដិវត្តយើងនៅតាមគ្រប់មូលដ្ឋានសហករណ៍ ភូមិ-ឃុំ នៅតាមគ្រប់អង្គភាពយោធា នៅតាមគ្រប់ក្រសួង-មន្ទីរបដិវត្តន៍នានា និងនៅតាមគ្រប់រោងចក្រឧស្សាហកម្មនិងរោងសិប្បកម្មនានាទូទាំងប្រទេស ប្ដេជ្ញារៀនសូត្រនូវប្រវត្តិតស៊ូដ៏អង់អាចរបស់បក្សក្នុងរយៈពេល២៥ឆ្នាំកន្លងទៅនេះ ធ្វើជាគំរូជាក់ស្ដែងរស់រវើកដើម្បីកសាងខ្លួនឲ្យបានរឹងប៉ឹងឡើងជាលំដាប់ ។ ព្រមជាមួយនេះ យុវជន-យុវនារីបដិវត្តយើងក៏ប្ដេជ្ញារៀនសូត្រនិងក្ដាប់ឲ្យជាប់នូវមាគ៌ាគ្រប់ផ្នែក និងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សឲ្យបានជ្រួតជ្រាបទៅតាមគោលជំហរ ពិសេសគឺមាគ៌ាឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនរបស់បក្ស ដើម្បីពង្រឹងពង្រីកគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់ជោគវាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងឲ្យកាន់តែរឹងប៉ឹងឡើងជាប់ជានិច្ច ដើម្បីវាយសំរុកកសាងសង្គមនិយម នៅកម្ពុជា និងការពារកម្ពុជាប្រជាធិបតេយ្យយើង ឲ្យបានរឹងប៉ឹង ខ្លាំងក្លា និងចំរើនលោតផ្លោះលើគ្រប់វិស័យទាំងវិស័យកសិកម្មឧស្សាហកម្ម គមនាគមន៍ វប្បធម៌ សង្គមកិច្ច សុខាភិបាលទាំងវិស័យលើកតម្កើងជីវភាពប្រជាជន ។ល ។

យុវជនយុវនារីបដិវត្តយើងជឿជាក់លើការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងរបស់បក្សកុម្មុយនិស្តកម្ពុជាយើង ដែលធ្លាប់ដឹកនាំប្រជាជន យុវជន-យុវនារីកម្ពុជា ធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យដណ្ដើមបានជ័យជំនះទាំងស្រុងនិងស្ថាពរក្នុងរយៈពេលដ៏ឆាប់បំផុតកន្លងមកនេះ ថាប្រាកដជាបក្សនឹងដឹកនាំប្រជាជាតិប្រជាជន យុវជន យុវនារីកម្ពុជាយើងធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសដណ្ដើមបានមហាជ័យជំនះធំៗថ្មីទៀតជាបន្តបន្ទាប់រហូតដល់សម្រេចបដិវត្តសង្គមនិយមនៅកម្ពុជាក្នុងរយៈពេលខ្លីខាងមុខនេះទៀត ដើម្បីឈានទៅធ្វើបដិវត្តន៍កុម្មុយនិស្តនិយមជាបន្តទៀត ។

ក្នុងឱកាសបុណ្យខួបកំណើតឆ្នាំទី២៥ នៃបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងនៃយើងទាំងអស់គ្នានាថ្ងៃ៣០ កញ្ញា ឆ្នាំ១៩៧៦ នេះ យុវជន-យុវនារីបដិវត្តយើងខ្ញុំសូមប្រសិទ្ធិពរជ័យមហាប្រសើរដោយមនោសញ្ចេតនាគោរពដឹងគុណនិងស្នេហាបក្សយ៉ាងជ្រាលជ្រៅនិងស្មោះសរបំផុត សូមឲ្យបក្សមានឋាមពលក្លៀវក្លាជានិច្ច មានកម្លាំងកាយកម្លាំងចិត្ត និងគោលជំហរនយោបាយសតិអារម្មណ៍ចាត់តាំងនៃវណ្ណៈអធនកាន់តែរឹងប៉ឹង ខ្លាំងក្លា ស្រួចស្រាល់ មោះមុត និងល្អបរិសុទ្ធឡើងជានិច្ច ដើម្បីបន្តដឹកនាំប្រជាជាតិ ប្រជាជនកម្ពុជាទាំងមូល ដឹកនាំយុវជន-យុវនារីកម្ពុជាយើងខ្ញុំរាល់គ្នាធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស ដណ្ដើមបានជ័យជំនះកាន់តែធំដុំថ្មីទៀតជាបន្តបន្ទាប់រហូតដល់សម្រេចជ័យជំនះទាំងស្រុងនិងជាស្ថាពរ ។

ព្រមជាមួយនេះ យុវជនយុវនារីបដិវត្តន៍យើងខ្ញុំសូមប្ដេជ្ញាចំពោះបក្សថានឹងខិតខំរៀនសូត្រអំពីបក្សនូវគំរូវីរភាព គំរូលះបង់ គំរូប្រយុទ្ធស្រួចស្រាល់ដាច់ខាតជានិច្ច រៀនសូត្រនូវគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង និងជំហរវាបសាររបស់បដិវត្តន៍ របស់បក្សជាប់ជានិច្ច ខិតខំរៀនសូត្រនិងក្ដាប់មាគ៌ានយោបាយសតិអារម្មណ៍ និងលក្ខការណ៍ចាត់តាំងផ្សេងៗរបស់បក្សឲ្យជ្រួតជ្រាបទៅជាសរសៃសរស្នូង ជាគោលជំហររឹងប៉ឹង ខ្ជាប់ខ្ជួនជានិច្ច ដើម្បីការពារបក្ស ការពារបដិវត្តន៍ ការពារប្រទេសជាតិ និងប្រជាជនឲ្យបានកាន់តែប្រសើរឡើងជារៀងរហូតទៅ ។ ព្រមជាមួយនេះ យុវជនយុវនារីយើងខ្ញុំដ៏សូមប្ដេជ្ញានឹងបក្សថា នឹងគោរពដើរតាមបក្សធ្វើតាមការណែនាំអប់រំរបស់បក្សដោយស្មោះត្រង់និងហ្មត់ចត់ ម៉ឺងម៉ាត់ ឥតរវាតបង្វាករេជារៀងរហូត ។

# លក្ខណៈសម្បត្តិ១០ "ខ" របស់បក្ស

(ឯកសារទង់បដិវត្តលេខ៨ ខែកក្កដា ឆ្នាំ១៩៧៨)



## ១) កសាងគោលជំហររឹងប៉ឹងខាងមាគ៌ានយោបាយរបស់បក្ស

មាគ៌ានយោបាយរបស់បក្សមានសារៈសំខាន់ណាស់ ។ មានតម្លៃស្មើអាយុជីវិតរបស់ប្រទេសជាតិ ។ បើមាគ៌ានយោបាយរបស់បក្សត្រឹមត្រូវគឺដឹកនាំធ្វើបដិវត្តន៍បានជ័យជំនះ ប្រទេសជាតិបានរំដោះ ប្រជាជនបានរំដោះ ។ បើមាគ៌ានយោបាយរបស់បក្សខុស គឺដឹកនាំធ្វើបដិវត្តន៍មិនឈ្នះ ប្រទេសជាតិនៅខ្ញុំគេ ប្រជាជនត្រូវគេជិះជាន់ ។

ឧទាហរណ៍ ដូចជាមាគ៌ានយោបាយរបស់បក្សយើង ។ ដោយមកពីបក្សកុម្មុយនិស្តកម្ពុជាយើងមានមាគ៌ានយោបាយត្រឹមត្រូវបានជាដឹកនាំប្រជាជនធ្វើបដិវត្តន៍ រំដោះជាតិ រំដោះប្រជាជន រហ័សបានជ័យជំនះ ។ ដោយមកពីបក្សកុម្មុយនិស្តកម្ពុជាយើងមានមាគ៌ានយោបាយឯករាជ្យម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនត្រឹមត្រូវរឹងប៉ឹង បានជាខ្មាំងយួនឈ្លានពានវាតទីលេបទឹកដីបំបាត់ពូជសាសន៍វាយកប្រទេសកម្ពុជាយើងមិនបាន រំលំរដ្ឋអំណាច កម្មករ កសិករយើងមិនបាន រំលំបក្សកុម្មុយនិស្តកម្ពុជាយើងមិនបាន ។ ដោយមកពីបក្សកុម្មុយនិស្តកម្ពុជាយើងមានមាគ៌ានយោបាយត្រឹមត្រូវវៃឈ្លាសបានជាបក្សយើងដឹកនាំប្រជាជនការពារប្រទេសបានទាំងស្រុង ធ្វើបដិវត្តន៍សង្គមនិយមបានលឿន កសាងសង្គមនិយម កែប្រែជីវភាពប្រជាជនបានខ្លាំងក្លា ។ល ។

បក្ខជនគ្រប់រូបត្រូវមានជំហរខាងមាគ៌ានយោបាយត្រឹមត្រូវនិងរឹងប៉ឹងជានិច្ច ។ មិនស្ពាំ មិន«រេរ៉ង» ក្នុងការបំពេញភារកិច្ចនយោបាយជាក់ស្តែងរបស់បក្សដែលខ្លួនអនុវត្តជាបន្តបន្ទាប់ ហើយជាពិសេសក្នុងកិច្ចការពារប្រទេសធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនាបច្ចុប្បន្ននេះ ។

មាគ៌ានយោបាយរបស់បក្សយើងគិតតាំងពីបក្សកកើតឡើងកាលណាមកត្រូវប្រយុទ្ធឆ្លងកាត់នូវឧបសគ្គធំៗសំខាន់ៗជាប់ជានិច្ច ។ រហូតឆ្លងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ

មកដល់បដិវត្តន៍សង្គមនិយម ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាភ្នាក់ងារ សេ.អ៊ី.អា ជាភ្នាក់ងារក្អែបម្រើយួន ជាភ្នាក់ងារកា.ហ្សេ.បេ វាបំភ្លៃ វាបំផ្លាញមាគ៌ានយោបាយរបស់បក្ស ដោយអនុវត្ត ស្តាំ អនុវត្ត«ឆ្វេង» ប៉ះពាល់ដល់ផលប្រយោជន៍បដិវត្តន៍ ផលប្រយោជន៍ប្រជាជនយើង ។ បំណងរបស់ពួកវាគឺបំផ្លាញមាគ៌ានយោបាយរបស់បក្ស ដើម្បីនាំប្រទេសជាតិទៅធ្វើខ្ញុំចក្រពត្តិអាមេរិក ឬខ្ញុំកញ្ជះខ្មាំងយួន ។ ពិសេសទៀតខ្មាំងយួនដែលវាពាក់ផ្លាកជាបដិវត្តន៍ វាបំផ្លាញ វារារាំង វាបង្វែមាគ៌ានយោបាយរបស់បក្សយើងតាមរបៀបទន់ភ្លន់ តាមវិធីគំរាមកំហែង តាមប្រយោល តាមត្រង់ ដោយផ្ទាល់ ។ល ។ ខ្មាំងយួនវាក្តៅក្រហាយណាស់ ដែលបក្សកុម្មុយនិស្តយើងមានមាគ៌ានយោបាយឯករាជ្យរបស់ខ្លួន ។ ខ្មាំងយួនវាយល់ថា ចង់លេបយកកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិនបានទាល់តែបំផ្លាញមាគ៌ានយោបាយឯករាជ្យរបស់បក្សកុម្មុយនិស្តកម្ពុជា ។ តែរហូតដល់ឥឡូវវាបំផ្លាញមិនបាន វាត្រូវបរាជ័យយ៉ាងទម្ងន់ជាបន្តបន្ទាប់ ។ នៅលើសកលលោកក៏ដូចនេះដែលបក្សពួកសេរីនិយមវាតទីនិយម ក៏វាមានផែនការបំផ្លាញមាគ៌ានយោបាយរបស់បក្សដឹកនាំបដិវត្តន៍ដែលត្រឹមត្រូវ ដើម្បីវាក្តាប់យកបក្សទាំងនោះនៅក្រោមការគ្រប់គ្រងរបស់វា គាបសង្កត់យកបក្សទាំងនោះធ្វើជាឧបករណ៍បម្រើផលប្រយោជន៍របស់បក្សពួកវា ។



ប៉ុល ពត

បក្ខជនគ្រប់រូបមានភារកិច្ចបំពាក់បំប៉នឲ្យខ្លួនខាងមាគ៌ានយោបាយរបស់បក្សឲ្យបានរឹងប៉ឹងដើម្បី÷

◆អនុវត្តមាគ៌ានយោបាយរបស់បក្សឲ្យបានត្រឹមត្រូវ

◆ការពារមាគ៌ានយោបាយរបស់បក្សមិនឲ្យខ្មាំងសត្រូវចំហក្តី សម្ងាត់ក្តី បំផ្លាញមាគ៌ានយោបាយរបស់បក្សបាន ។

◆ដើម្បីច្នៃប្រឌិតធ្វើឲ្យមាគ៌ានយោបាយរបស់បក្សកាន់តែមានប្រសិទ្ធភាពខ្លាំងក្លាក្នុងការអនុវត្តជាក់ស្តែង យើងបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជាទាំងអស់ប្តេជ្ញាអនុវត្ត ប្តេជ្ញាការពារមាគ៌ានយោបាយរបស់បក្សលើសពីអាយុជីវិតរបស់ខ្លួនទៅទៀត ។

## ២) កសាងជំហរបដិវត្តរឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្ស

មានគោលជំហរបដិវត្តរឹងប៉ឹងខាងមាគ៌ានយោបាយរបស់បក្ស ហើយត្រូវមានគោលជំហររឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្សទៀត ។ មាគ៌ានយោបាយជាមូលដ្ឋាន ។ សតិអារម្មណ៍ជាកត្តាសម្រាប់បញ្ជាការអនុវត្តមាគ៌ានយោបាយ ។ សតិអារម្មណ៍បដិវត្តវាធ្វើឲ្យការអនុវត្តមាគ៌ានយោបាយរបស់បក្សបានត្រឹមត្រូវ ។ សតិអារម្មណ៍មិនបដិវត្ត វារារាំងដល់ការ

អនុវត្តមាគ៌ានយោបាយរបស់បក្ស ។

ខ្មាំងគ្រប់ប្រភេទទាំងចំហ ទាំងសម្ងាត់ វាយកចិត្តទុកដាក់វាយបក្ស វាយបដិវត្តន៍ខាងសតិអារម្មណ៍ខ្លាំងណាស់ដែរ ។ បើវាវាយសតិអារម្មណ៍បដិវត្តដួល ហើយបំពាក់ឲ្យវិញនូវសតិអារម្មណ៍ មិនបដិវត្តបានគឺវាសម្រេចបានគោលបំណងរបស់វាក្នុងការគ្រប់គ្រងបក្ស ។

ឧទាហរណ៍ជាក់ស្តែងដូចជាខ្មាំងយួនដែលវាមានបំណងគ្រប់គ្រងត្រួតត្រាវាយរំលំបក្សកុម្មុយនិស្តកម្ពុជាយើង វាតែងវាយសតិអារម្មណ៍របស់បក្សយើង ដូចជាវាយសតិអារម្មណ៍ហិង្សាបដិវត្ត÷

ខ្មាំងយួនវាផ្សាយថាសភាពការណ៍នៅកម្ពុជាមិនត្រូវតស៊ូដោយហិង្សាបដិវត្តទេ ត្រូវតស៊ូតាមសភា ។ វាវាយសតិអារម្មណ៍ឯករាជ្យម្ចាស់ការ ខ្លួនទុកដាក់ខ្លួន ដោយផ្សាយថាប្រទេសតូចឯករាជ្យម្ចាស់ការមិនបានទេ ត្រូវពឹងពាក់ប្រទេសធំៗល ។ ខ្មាំងយួនវាធ្វើយ៉ាងណាឲ្យតែសតិអារម្មណ៍របស់បក្សយើងរណបវា ខ្លាចវា ពឹងពាក់លើវា ទុកវាជាអ្នកដឹកនាំនៅ «ឥណ្ឌូចិន» ។ តែសកម្មភាពលាមករបស់ខ្មាំងយួននេះត្រូវបក្សកុម្មុយនិស្តកម្ពុជាវាយកម្ទេចបកអាក្រាតមុខមាត់ក្បត់បដិវត្តរបស់វាឲ្យអ្នកផងឃើញយ៉ាងច្បាស់ក្រឡែត ។ កសាងគោលជំហរបដិវត្តរឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្សគឺកសាងអ្វី ។

◆ត្រូវកសាងគោលជំហរសតិអារម្មណ៍វណ្ណៈអធនត្រឹមត្រូវនិងរឹងប៉ឹង លើគ្រប់ផ្នែកសម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

◆ ត្រូវកសាងគោលជំហរកម្មសិទ្ធិសមូហភាពត្រឹមត្រូវ និងរឹងប៉ឹងគ្រប់ផ្នែកៈ សម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ហើយរស់នៅតាមរបបចាត់តាំងសមូហភាព ។ ត្រូវកសាងគោលជំហរលះបង់កម្មសិទ្ធិសួនតួខ្ពស់ និងដាច់ខាតគ្រប់ផ្នែកៈ សម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

◆ត្រូវកសាងគោលជំហរប្រយុទ្ធមោះមុតសកម្ម ទ្រាំទ្រលំបាកវេទនាគ្រប់កាលៈទេសៈ ក្នុងការតស៊ូវណ្ណៈដាច់ខាតក្នុងកិច្ចការពារប្រទេស និងកសាងកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម ។

◆ត្រូវប្រុងប្រយ័ត្នបំផុត ចំពោះជំហរកម្មសិទ្ធិបុគ្គលសួនតួឯកជនក្រាស់ ខាងសម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

បក្ខជនគ្រប់រូបត្រូវប្រយុទ្ធកម្ចាត់នូវសតិអារម្មណ៍មិនអធន ហើយប្រយុទ្ធកសាងដាច់ខាតនូវសតិអារម្មណ៍អធនរបស់បក្សដើម្បីធ្វើខ្លួនជាអ្នកបដិវត្ត ជាបក្ខជននៃបក្សកុម្មុយនិស្តកម្ពុជាល្អរៀងរហូត ។

## ៣) កសាងគោលជំហរបដិវត្តន៍រឹងប៉ឹងខាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស

បក្សកុម្មុយនិស្តកម្ពុជាជាស្នូលដ៏រឹងប៉ឹង និងជានិមិត្តរូបនៃសាមគ្គីភាពឯកភាពជាតិនិងប្រជាជនកម្ពុជាទាំងមូល ។ បក្សកុម្មុយនិស្តកម្ពុជាធ្លាប់មានប្រពៃណីយ៉ាងល្អប្រសើរក្នុងកសាងសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងធ្លាប់ឆ្លងកាត់ការប្រយុទ្ធតឹងតែងស៊ិតស្វាញ ស្មុគស្មាញ ដើម្បីរក្សាការពារសាមគ្គីភាពឯកភាពផ្ទៃក្នុងបក្ស ។ ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដីបំបាត់ពូជសាសន៍ និងភ្នាក់ងារឆ្អែបម្រើវា ដែលបង្កប់ស៊ីរូងផ្ទៃក្នុងបក្សកុម្មុយនិស្តកម្ពុជា វាធ្វើសកម្មភាពទាំងចំហទាំងសម្ងាត់វាយបំបាក់បំបែកសាមគ្គីភាពឯកភាពផ្ទៃក្នុងរបស់បក្សយើង ។ ពួកវាវាយបំបែកមាគ៌ានយោបាយ វាយបំបែកសតិអារម្មណ៍ វាយបំបែកការចាត់តាំងរបស់បក្សយើងជារៀងរហូតមក ។ វាបំបែកប្រជាជនយុទ្ធជនពីបក្សកុម្មុយនិស្តកម្ពុជា ។ តែបក្សកុម្មុយនិស្តកម្ពុជា បក្ខជន ប្រជាជន យុទ្ធជនយើងបានប្រកាន់ខ្ជាប់ខ្ជួនគោលជំហរបដិវត្តរឹងប៉ឹងខាងសាមគ្គីភាពឯកភាពផ្ទៃក្នុងរបស់បក្ស បានវាយប្រហារតបទៅខ្មាំងយួនឈ្លានពាននិងឆ្អែបម្រើវាវិញ រក្សាការពារបានបរិសុទ្ធភាពនៃគោលជំហរសាមគ្គីភាពឯកភាពរបស់បក្ស ។ មកពីបក្សកុម្មុយនិស្តកម្ពុជារក្សាការពារពង្រឹងនិងពង្រីកបានគោលជំហរសាមគ្គីភាពឯកភាពផ្ទៃក្នុងរបស់បក្សនេះហើយ បានជាខ្មាំងយួនមិនអាចបំផ្លាញបក្សបាន មិនអាចលេបទឹកដីកម្ពុជាជាទីស្នេហារបស់យើងបាន ។ ឲ្យតែបក្ខជនទាំងអស់ពង្រឹងឲ្យខ្លាំងក្លាមោះមុតនូវគោលជំហរសាមគ្គីភាពឯកភាពផ្ទៃក្នុងបក្សយ៉ាងខ្ជាប់ខ្ជួន ពេលនេះក៏ដូចជាពេលតៗទៅមុខទៀត ខ្មាំងយួនក្តីខ្មាំងផ្សេងទៀតក្តី មិនអាចមកឈ្លានពានវាតទីលេបទឹកដីបំបាត់ពូជសាសន៍កម្ពុជាបានជាដាច់ខាត ។ **(នៅមានត)**

**(តពីលេខមុន)** ចាប់ពីពាក់កណ្តាលខែកុម្ភៈដល់ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៧ មានប្រជាជនទាំងស្រីទាំងប្រុសចំនួន ១២៤៩នាក់ត្រូវបានបញ្ជូនចូលគុកក្នុងអំឡុងពេលនៃចលនាវិសុទ្ធកម្មនៅភូមិភាគឧត្តរនិងពាយ័ព្យ ។

ក្នុងឆ្នាំ១៩៧៨ នៅលើរូបថតរបស់អ្នកទោសមានផ្លាកឈ្មោះលេខរៀងសម្គាល់តាមខែចូលរបស់អ្នកទោស ។ តាមឯកសារនៃការនាំអ្នកទោសចូល ទោះបីជាមិនសូវពេញលេញក្តីតែបង្ហាញថាយ៉ាងហោចណាស់មានអ្នកទោសចំនួន៤៣៥២នាក់បានចូលមកមន្ទីរសន្តិសុខស-២១ក្នុងឆ្នាំ១៩៧៨ ។ មានតែអ្នកទោសចំនួន ៥៩នាក់ប៉ុណ្ណោះដែលត្រូវបានកត់ក្នុងបញ្ជីខែឧសភា ទោះជាលេខរៀងរូបថតពាក់កណ្តាលខ្លួនរបស់អ្នកទោសទាំងនោះឡើងដល់៧៩១ក៏ដោយ ។ ថ្វីដ្បិតតែមានចន្លោះជាច្រើននៅក្នុងឯកសាររូបថតឆ្នាំ១៩៧៨ក៏ដោយ ប៉ុន្តែបើផ្ទៀងផ្ទាត់ជាមួយរបាយការណ៍នាំមនុស្សចូលប្រចាំខែលើកលែងតែខែឧសភា និងខែសីហា ដែលនៅសល់រូបថត ឃើញថាមានតួលេខខ្ពស់ណាស់ដែលមានភាពប្រហាក់ប្រហែលគ្នា ។ ខ្ញុំបានបន្ថែមតួលេខ៧៣២នាក់ទៀតទៅក្នុងបញ្ជីស្នាមនាំចូលខែឧសភា ដើម្បីឲ្យចំនួននេះឡើងដល់ ៥០៨៤នាក់ តាមចំនួនសរុបប៉ាន់ស្មានក្នុងឆ្នាំ១៩៧៨ ។ ចំនួននាំចូលពីខែមេសាដល់ខែមិថុនា បង្ហាញអំពីវិសុទ្ធកម្មនៅភាគនិរតីនៃប្រទេសកម្ពុជា ។ នៅត្រឹមចុងឆ្នាំ១៩៧៨ ចំនួនអ្នកទោសបានធ្លាក់ចុះយ៉ាងខ្លាំង ។ នៅខែធ្នូឆ្នាំ១៩៧៨ បើតាមចំណាររបស់ហ៊ុយ ម្ជើទៅ ឌុច បានបង្ហាញថា មានអ្នកទោសចំនួន១៧៩នាក់នៅក្នុងគុកធំ (ប្រហែលអគារធំនៅផ្នែកខាងលិច) និង៤៥នាក់ទៀតដែលច្បាស់ជាឈ្លើយសឹកជនជាតិវៀតណាម ហើយមាន ៣៣នាក់ទៀតនៅក្នុង«គុកពិសេស» ។ ហើយនៅពេលជាមួយគ្នានោះដែរ មានអ្នកទោស «កំពុងធ្វើការ» ចំនួន១៨នាក់ទៀតផង ដែលចំនួននេះមានបុរស៧នាក់បានរត់ចេញរួចពីការឃុំឃាំងនៅមន្ទីរ ស-២១ ។ ទោះជាចំនួនអ្នកទោសដែលរាយក្នុងបញ្ជីនៅទីនេះមានតែ១៣២០៦នាក់ក៏ដោយ ប៉ុន្តែផ្អែកទៅលើចន្លោះប្រហោងនៅក្នុងទិន្នន័យបញ្ជាក់ថា ចំនួនអ្នកទោសប៉ាន់ស្មានរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ អាចមានប្រហាក់ប្រហែល១៤០០០នាក់ ។

ភាគច្រើននៃអ្នកទោសនៅមន្ទីរស-២១គឺសុទ្ធតែជាក្មេងប្រុសជនជាតិភាគតិចមកពីជនបទដាច់ស្រយាល ។ ពួកក្មេងទាំងនោះមានតម្លៃសង្គមនិងសញ្ញាតិមិនខុសពីអ្នកដែលឃុំខ្លួនឡើយ ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី២ ស្ថាប័នស្វយ័ត**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

តែមានករណីខ្លះប្រជាជនដែលត្រូវបានចាត់ទុកជា«ខ្មាំងវណ្ណៈ» ឬក៏«ប្រជាជនថ្មី» និងអ្នកដែលសង្ស័យថាបានប្រព្រឹត្តកំហុសតូចតាចត្រូវបានចាប់ឃុំឃាំងក្នុងគុកនានានៅតាមខេត្ត ។ ក្នុងចំណោមអ្នកទោសទាំងអស់មានតែ២៣៨នាក់ ឬ៦,៤ភាគរយប៉ុណ្ណោះជាស្ត្រីភេទ ដែលបន្សល់ទុកចម្លើយសារភាពមកដល់សព្វថ្ងៃនេះ ។ ភាពខុសប្លែកគ្នាអាចពន្យល់បញ្ជាក់បានតាមរយៈការពិតជាក់ស្តែងដែលថាមានស្ត្រីតិចជាងបុរសដែលបម្រើក្នុងផ្នែកយោធាតាមអង្គភាពសន្តិបាល ហើយមានភាគតិចណាស់ដែលមានតួនាទីក្នុងរបបកម្ពុជាធិបតេយ្យ ។ ដូច្នេះមានពេលខ្លះស្ត្រីទាំងនោះត្រូវបានចោទថាប្រឆាំងបដិវត្តន៍ ហើយក៏ត្រូវជាប់ទោសតែម្តង ។ ប៉ុន្តែច្បាស់ណាស់ថា ស្ត្រីនៅក្នុងគុកមានចំនួនច្រើនជាងចំនួននៃចម្លើយសារភាពរបស់ខ្លួន ។ យើងដឹងថាប្រពន្ធរាប់សិបនាក់របស់អ្នកទោសដែលមានឋានៈខ្ពស់ៗ ព្រមទាំងម្តាយរបស់អ្នកទាំងនោះត្រូវបានឃុំឃាំងនិងសម្លាប់ចោលនៅក្នុងមន្ទីរសន្តិសុខស-២១ដោយគ្មានការសួរចម្លើយ ។ ម្យ៉ាងវិញទៀត ស្ត្រីអ្នកទោសទាំងនោះរួមមានអ្នកកាន់តំណែងខ្ពស់ៗដូចជា ប្រធានស្រុក ប្រធានរោងចក្រ អ្នកកាន់តំណែងផ្នែករដ្ឋបាលមន្ទីរពេទ្យ កម្មាភិបាលយោធា ព្រមទាំងឧបដ្ឋាកយិកា និងអ្នកជាំបាយដែលជាតំណែងប្រពៃណី



កូនកម្មាភិបាលស-២១



អ្នកទោសមន្ទីរស-២១

របស់ស្ត្រីខ្មែរ ។

អ្នកទោសប្រហែល៥០០នាក់ឬ១០ភាគរយនៃចំនួនអ្នកទោសសរុបដែលចម្លើយសារភាពរបស់ខ្លួននៅមកដល់សព្វថ្ងៃនេះ មានការន់មុខតំណែងទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងនេះ ខ្ញុំរួមបញ្ចូលទាំងលេខានយោបាយតាមផ្នែក និងជំនួយការមេបញ្ជាការយោធាវរសេនាធំនិងកងពល កម្មាភិបាលកាន់កាប់សហគ្រាសរដ្ឋដូចជាក្រសួងការបរទេស ក្រសួងពត៌មាន ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ។ ៣០នាក់នៃអ្នកដែលត្រូវបានបោសសម្អាតម្តងៗ គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ។ ទោះបីអ្នកទោសទាំងអស់ទទួលវាសនាដូចៗគ្នាក៏ដោយ ក៏ប៉ុន្តែអ្នកទោសដែលមានមុខតំណែងផ្សេងៗនៅមន្ទីរសន្តិសុខស-២១ ច្រើនតែទទួលរបបពិសេសមួយជាញឹកញយ ។ គក ស្រស់ បានរំឭកថា កម្មាភិបាលដែលស្ថិតក្នុងការឃុំឃាំងនៅក្នុងគុកដែលហៅថា "គុកពិសេស" គ្មានធ្វើអ្វីទេ ដេកចាំតែទទួលរបបដូចបុគ្គលិកទូទៅដែរ ។ គក ស្រស់ បន្ថែមថា ក្រោយពេលទទួលការសួរចម្លើយ និងទារុណកម្មរួចហើយ អ្នកទោសត្រូវបានផ្តូតទឹកនិងបិទរបួសឲ្យដោយបុគ្គលិកពេទ្យនៅមន្ទីរ ស-២១ ហើយទុកពេលឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនឲ្យបានកាន់តែ"សុក្រឹត" ។ ដោយសង្ឃឹមថានឹងបានផ្អាកឬបន្ថយការធ្វើទារុណកម្ម និងទទួលការដោះលែង មានកម្មាភិបាលជាន់ខ្ពស់ជាច្រើនបានសម្រេចចិត្តសហការនិងខំសរសេរចម្លើយសារភាពរាប់រយទំព័រ ។ គក ស្រស់ និយាយថា សន្តិសុខដែលត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវអ្នកទោសជាកម្មាភិបាលជាន់ខ្ពស់ សុទ្ធតែត្រូវបានជ្រើសរើសជាពិសេសមកពីអង្គភាព ។ ការយកចិត្តទុកដាក់ជាពិសេសដែលកម្មាភិបាលបានទទួលអាចស្តែងឲ្យឃើញផ្នែកខ្លះតាមរយៈការសម្តែងនូវការគោរពចំពោះកម្មាភិបាលដែលមានឋានៈខ្ពស់ៗ ប៉ុន្តែវាប្រហែលជាមានទាក់ទងជាមួយនឹងតម្រូវការរបស់មជ្ឈិមបក្សបានជាអ្នកទោសកម្មាភិបាលទាំងនោះត្រូវបានថែទាំឲ្យមានសុខភាពល្អសម្រាប់សរសេរចម្លើយសារភាពឲ្យសមហេតុផល ។

គ្មានចម្លើយសារភាពណាមួយនិយាយអំពីជីវិតប្រចាំ

ថ្ងៃនៅក្នុងគុក ឬការទាក់ទងរបស់អ្នកទោសឡើយ ។ ដូច្នេះ ហើយបានជាប្រភពមកពីមន្ទីរសន្តិសុខស-២១ខ្សត់ជាងប្រភព ដែលយើងអាចពិគ្រោះសិក្សាអំពីហាយនភាពឬ «សង្គ្រាមកខ្វក់» នៅអាហ្សង់ទីន ឬក៏ជំរំកសាងខ្លួននៅចិន និង សូវៀត មិនត្រឹមតែ ដោយសារអ្នកនៅរស់រានមានជីវិតនៅទីនោះមានចំនួនច្រើនទេ ប៉ុន្តែដោយសារភាពសម្ងាត់និង«វិន័យ» របស់មន្ទីរសន្តិសុខស-២១ ដែលបានបិទការទាក់ទងរវាង អ្នកទោសនិងអ្នកទោសព្រមទាំង រារាំងយើងមិនឲ្យដឹងពីអ្វីដែលត្រូវបានផលិតឡើងនៅក្នុង បរិវេណនោះ លើកលែងតែចម្លើយសារភាព អនុស្សរណៈនិង ប្រវត្តិរូបស៊ុយទិតៀន ។ លើសពីនេះទៀត មន្ទីរសន្តិសុខស-២១ មិនដូចជាជំរំរបស់ណាហ្ស៊ីឡើយ ។ មន្ទីរនេះមាន«ភាពគួរឲ្យទុកចិត្តណាស់» ។ ការធ្វើល្អចំពោះអ្នកទោសមានឋានៈខ្ពស់ៗមិនរាប់បញ្ចូលការអនុញ្ញាតឲ្យទៅជិតដិតជាមួយអ្នកទោសឡើយ ។ ផ្ទុយទៅវិញ បើតាមឃ្លាមួយរបស់ ហុល វ៉ែហ្គង សហ្វស្គី អ្នកទោសទាំងនោះ «ស្ថិតនៅក្នុងភពបាតសង្គមមួយពោលគឺ ពិភពនៃទុក្ខសោកវេទនា និងភាពគ្មានឈ្មោះ» ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ពេលដែលមន្ទីរសន្តិសុខស-២១ពង្រីកខ្លួន អ្នកទោសដែលទទួលការសួរចម្លើយយ៉ាងខ្លាំងក្លា ប៉ុន្តែមិនរហូតដល់ឃុំឃាំងនៅក្នុង«គុកពិសេស»នោះ ត្រូវបានដាក់នៅក្នុងបន្ទប់ ដែលមានបណ្តោយប្រវែង២ម៉ែត្រ និងទទឹង៨០សង់ទីម៉ែត្រ ស្ថិតនៅក្នុងថ្មុករដើកភ្លើងព័ទ្ធជុំវិញ ហើយនៅក្នុងបន្ទប់នោះ អ្នកទោសត្រូវបានដាក់ខ្នោះជើងជាប់ទៅនឹងកម្រាលឥដ្ឋ ។ អ្នកទោសមិនសូវសំខាន់ ដូចជា វ៉ាន់ ណាត ត្រូវបានដាក់នៅក្នុងបន្ទប់ធំនៅជាន់ទីពីរនៃបរិវេណនោះ«តម្រង់ជាជួរនិងដាក់ខ្នោះកងជើងភ្ជាប់ទៅនឹងចុងបន្ទប់» ។

អ្នកទោសស្ត្រីនិងបុរសត្រូវបានបំបែកពីគ្នា ។ ស្ត្រីដែលមានកូនតូចអាចនៅជាមួយកូន ចំណែកប្តីរបស់ខ្លួនត្រូវបានយកទៅសួរចម្លើយ ហើយសមាជិកគ្រួសារត្រូវបាននាំយកទៅសម្លាប់ចោល ។ មានឯកសារមួយបានបញ្ជាក់ថានៅដើមខែកក្កដា ឆ្នាំ១៩៧៧ មានអ្នកទោស៧៥នាក់ដែលត្រូវជាកូនរបស់អ្នកទោសដែលត្រូវបានយកទៅសម្លាប់នោះ ត្រូវបានយកមកកម្ទេចនៅឯព្រៃស ។ តាមចម្លើយសារភាពរបស់បុគ្គលិកធ្វើការនៅក្នុងគុកបានឲ្យដឹងថា អ្នកទោសភេទស្រីត្រូវបានទទួលរងទុក្ខបុកម្នេញនិងរំលោភយ៉ាងបំពាន ។ ជាពិសេសអ្នកទោសភេទស្រីជនជាតិវៀតណាមងាយទទួលរងនូវការវាយប្រហារណាស់ ។

ភាពឯកោ កង្វះអាហារ និងភាពស្ងប់ស្ងាត់ គឺជាការសំខាន់ក្នុងការបំបាក់អ្នកទោសដើម្បីសួរចម្លើយ ដូចដែលលោក ហ៊ុខល បាននិយាយថា «ភាពឯកោគឺជាលក្ខណៈចម្បងសម្រាប់ឲ្យអ្នកទោសសារភាព» ។ អ្នកទោសក្រោកតាំងពីម៉ោង៥ព្រឹក ។ ក្រោយពីភ្ញាក់ពីមពតើមភ្លាមមក អ្នកទោសត្រូវបានបញ្ជាឲ្យហាត់ប្រាណធ្វើកាយសម្ព័ន្ធទាំងជាប់ខ្នោះច្រវាក់ ។ ២០ឆ្នាំក្រោយមក វ៉ាន់ ណាត រំឭកអំពីការធ្វើកាយសម្ព័ន្ធកាលនៅពេលនោះថា យើងឮសំឡេងបញ្ជា «ពួកឯងទាំងអស់គ្នាក្រោកឡើង!» ។ ពេលខ្ញុំក្រោកអង្គុយខ្ញុំឃើញក្មេងប្រុសម្នាក់អាយុប្រហែល១៣ឆ្នាំឈរនៅលើខ្សែភ្លើងដែលរុំធ្វើជាផ្លូវដែលមានប្រវែងប្រហែល១ម៉ែត្រ ។ ក្មេងនោះក៏សួរថា «ហេតុអីក៏អ្នកឯងដេកអីចឹង? ជិតភ្លឺហើយណា៎! កុំខ្ជិលពេក ហាត់ប្រាណខ្លះទៅ» ។ មានអ្នកទោសម្នាក់សួរទៅវិញថា «តើឲ្យខ្ញុំហាត់ប្រាណយ៉ាងម៉េចបង?» ក្មេងនោះតបវិញថា«កុំល្ងង់ពេកអាកញ្ចាស់ឆ្កួត ។ ម៉េចមិនទៅយកធុងកើបអាចម៍ដាក់ក្រោមដែករនុកហើយលោតទាំងអស់គ្នាទៅ» ។ ពេលនោះអ្នកទោសទាំងអស់ក៏ធ្វើតាមការណែនាំ ហើយសំឡេងខ្នោះនិងធុងឮសូរទ្រហឹងពេញបន្ទប់ ។ ខ្ញុំបានសាកលោតពីរដងជាមួយនឹងគេឯងដែរ ។ តើធ្វើម៉េចនឹងលោតទៅកើត បើជើងម្ខាងជាប់ខ្នោះហើយជើងម្ខាងទៀតលោតនោះ?

អ្នកដែលត្រូវសួរចម្លើយត្រូវបានយកទៅរៀនបីវគ្គក្នុងមួយថ្ងៃចាប់ពីម៉ោង៧ព្រឹកទៅដល់ថ្ងៃត្រង់ពីម៉ោង១ថ្ងៃទៅដល់ម៉ោង៦ល្ងាចនិងពីម៉ោង៨យប់ដល់ពាក់កណ្តាលអាធ្រាត ។ អ្នកដែលនៅពីក្រោយមិនអនុញ្ញាតឲ្យជជែកគ្នាឡើយ បើចង់សម្រួលឥរិយាបថទាល់តែប្រាប់សន្តិសុខសិនទើបបាន ។ អ្នកទោសទាំងហ្វូងៗនៅបន្ទប់ធំត្រូវបានទទួលការ«ងូតទឹកឲ្យ»ក្នុងរវាង៣ឬ៤ថ្ងៃម្តង ដោយបាញ់ទឹកនឹងទុយោតាមបង្អួច ។ រីឯចំណីអាហារវិញគឺមានតែបបររាវកក្កុក២-៣ស្លាបព្រាលាយជាមួយត្រកួននិងស្លឹកចេក ។ អ្នកទោសត្រូវបានអនុញ្ញាតឲ្យហូបពីរពេល គឺពេលព្រឹកនៅម៉ោង៨ម្តង និងពេលយប់នៅម៉ោង៨

ម្តងទៀត ។ មិនយូរប៉ុន្មានអ្នកទោសក៏ចាប់ផ្តើមស្រកទម្ងន់និងកើតជំងឺរាគរូស ស្ពឹក ហើមជើង និងកើតរោគសើស្បែកជាច្រើនប្រភេទទៀត ។ នៅពេលដែលកម្លាំងចុះខ្សោយ ជំងឺក៏ឆ្លងរាលដាលពីអ្នកទោសម្នាក់ទៅម្នាក់ទៀត ។ មានអ្នកទោសជាច្រើននាក់ត្រូវស្លាប់មុនពេលយកទៅសួរចម្លើយ ហើយអ្នកខ្លះទៀតស្លាប់ក្រោយពីការសួរចម្លើយដែលមិនទាន់ត្រូវបានយកទៅសម្លាប់នៅឡើយ ។ ប្រសិនបើស្លាប់នៅពេលយប់សាកសពនឹងទុកដល់ពេលព្រឹក ពួកខ្មែរក្រហមមិនយកសាកសពទៅណាភ្លាមទេ ។ ភាពផ្ទុយគ្នារវាងការធ្វើបាបអ្នកទោសដូចជាសត្វធាតុ និងសេចក្តីសង្ឃឹមថានឹងបានទទួលចម្លើយសារភាពលម្អិត នោះជាវប្បធម៌របស់មន្ទីរសន្តិសុខស-២១ ហើយបញ្ហានេះមិនទាន់ត្រូវបានដោះស្រាយឡើយ ។ តើការយកចិត្តទុកដាក់ប្រកបដោយមនុស្សធម៌នឹងនាំទៅដល់ «ចម្លើយសារភាពមានលក្ខណៈពិតជាងនេះដែរឬទេ? គ្មានពេលដឹងអំពីបញ្ហានេះទេ ប៉ុន្តែការយកចិត្តទុកដាក់ប្រកបដោយមនុស្សធម៌មិនដែលកើតមានឡើយ ។ ចំពោះគំនិតរបស់អ្នករដ្ឋបាល គឺមិនមែនជាការចាំបាច់ឡើយក្នុងការធ្វើឲ្យអ្នកទោសមានសុខភាពរឹងប៉ឹង ។

ក្រោយពេលមួយខែនៃការឃុំឃាំង វ៉ាន់ ណាត និយាយថា «ក្រោយពីពេលដែលវាបន្ថត់អាហារជាយូរថ្ងៃយើងមិនអាចដើររួចឡើយ សូម្បីតែក្រោកឈរក៏មិនរួចផង ពេលនោះយើងមិនអាចប្រឆាំងនឹងពួកវាបានទេ នៅក្នុងចិត្តយើងគ្មានកម្លាំងណានឹងប្រឆាំងឡើយ ។ អ្វីៗបាត់បង់អស់ទៅហើយ ។ យើងដេកចាំតែថ្ងៃស្លាប់តែប៉ុណ្ណោះ ។»

ជារៀងរហូតមក លក្ខខណ្ឌសម្រាប់អ្នកទោសប្រែប្រួលរហូតទៅតាមចំនួននិងកម្រិតនៃការភ័យខ្លាចរបស់មជ្ឈិមបក្ស ។ នៅក្នុងឆ្នាំ១៩៧៥ មុនពេលដែលសន្តិបាលផ្លាស់មកទួលស្លែង និងមុនពេលដែលប្រតិបត្តិការចាប់ផ្តើមមានការសម្លាត់អ្នកទោសជាច្រើនត្រូវបានដោះលែងហើយបញ្ជូនទៅមន្ទីរកសិកម្មនៅព្រៃស ឬអ្នកខ្លះទៀតក៏ត្រឡប់ទៅអង្គភាពចាស់របស់ខ្លួន ។ ក្រោយមកទៀត មានអ្នកទោសមួយចំនួនដូចជា អ៊ឹង ប៉ិច និង រុយ នាគង់ ត្រូវបានដោះលែងពីខ្នោះហើយឲ្យទៅធ្វើការដូចធម្មតានៅតាមជាយគុក ។

នាដើមឆ្នាំ១៩៧៨ មានអ្នកទោសភេទប្រុសរាប់សិបនាក់ ក្នុងនោះរួមមានទាំង វ៉ាន់ ណាត និងអ្នកផ្សេងៗដែលបានរស់រានមានជីវិត ត្រូវបាន ឌុច ឈ្លេចសួរនិងចាត់តាំងឲ្យគូររូបនិងឆ្លាក់ធ្វើរូបសំណាក ប៉ុល ពត ។ នៅខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅពេលដែលសភាពការណ៍វាយប្រយុទ្ធគ្នាជាមួយនឹងវៀតណាមកាន់តែធ្ងន់ធ្ងរទៅ ប៉ុល ពត បែរជាមានគំនិតចង់បង្កើតរូបសំណាករបស់ខ្លួនឲ្យដូចជាមគ្គុទ្ទេសក៍នៅជុំវិញខ្លួនដែលមាន ម៉ៅ សេទុង និង គីម អ៊ីលស៊ុង ។ «ការជឿទុកចិត្ត»នៅមន្ទីរស-២១ត្រូវបានប្រមូលផ្តុំដើម្បីបង្កើតជាវិមានសមរម្យមួយ ។ និយាយជាមួយលោក ដេវីដ អាសលី នៅក្នុងឆ្នាំ១៩៩៥ វ៉ាន់ ណាត បានរំឭកថា «នៅទីបញ្ចប់យើងត្រូវតែរៀបចំគូសប្លង់វិមានបដិវត្តន៍មួយ ។ គំរូប្លង់ត្រូវបានយកទៅឲ្យ នួន ជា ហើយ នួន ជា ក៏យល់ស្រប បន្ទាប់មករូបនេះនឹងត្រូវបញ្ជូនទៅ ប៉ុល ពត មួយថ្នាក់ទៀត ។ វិមាននោះដូចជាវិមាននៅប្រទេសចិននិងប្រទេសកូរ៉េ មានរូប ប៉ុល ពត នៅពីមុខ លើកដៃស្តាំទៅលើ ដៃឆ្វេងកាន់សៀវភៅក្រហមមួយក្បាលដែលសរសេរពីកិច្ចការបដិវត្តន៍ ។ នៅក្នុងប្លង់នោះ ប៉ុល ពត គឺជាឥស្សរជនដែលត្រូវបានពិពណ៌នាថាជាមនុស្សពិសេសម្នាក់ ហើយនៅពីក្រោយ ប៉ុល ពត មានប្រជាជនជាច្រើននាក់លើកដៃបង្ហាញពីការរីកចម្រើនរបស់បដិវត្ត ដោយមានកាន់ពូថៅ កាំបិត កាំភ្លើង និងរ៉ុក្កែត បេ-៤០» ។ ឌុច និយាយថា គម្រោងគឺចង់វាយកម្ទេចវិហារនៅវត្តភ្នំ និងជំនួសដោយវិមាននេះ ។ ប្រសិនបើជាវៀតណាមមិនបានចូលមកឈ្លានពានទេនោះ ខ្ញុំគិតថាប្រហែលជានឹងកើតឡើងមែន ។

ចំពោះអ្នកទោសជាង១៤០០០នាក់ទាំងប្រុសទាំងស្រី និងក្មេងតូចៗដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខស-២១ គ្មានការតស៊ូបដិវត្តន៍ដែល«មានកាន់ពូថៅនិងកាំបិត»អ្វីឡើយ ។ រាល់ថ្ងៃរាល់ខែ អ្នកទោសទាំងនោះរស់នៅក្នុងបន្ទប់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ ។ ការតស៊ូរបស់អ្នកទោសទាំងនោះមិនបានបញ្ចប់ដោយភាពរុងរឿងឡើយ ប៉ុន្តែបញ្ចប់ដោយលលាដ៍ក្បាលរបស់ខ្លួនត្រូវបានកម្ទេចទាំងរទេះៗនៅឯវាលពិឃាតជើងឯក ។ ***(នៅមានត)***

# គំរូមួយនៃភស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

***(តពីលេខមុន)*** *សារនោះបានរាយការណ៍ទាំងការប្រយុទ្ធតាមព្រំដែននិងការបោសសម្អាតផ្ទៃក្នុង ។ សាររបស់បក្សកុម្មុយនិស្តទាំងនេះបានផ្តល់គម្រោងការធំៗនៃការចោទប្រកាន់របស់វៀតណាម ។ ឧទាហរណ៍ទូរលេខចុះថ្ងៃទី១៩ ខែមករា និយាយថាក្នុងការវាយប្រហារចូលទៅក្នុងទឹកដីវៀតណាមចំនួន២គីឡូម៉ែត្រ កម្លាំងដែលធ្វើប្រតិបត្តិការនៅតំបន់២៥មិនត្រឹមតែបាន «កម្ទេចកន្លែងស្នាក់នៅរបស់ខ្មាំងប៉ុណ្ណោះទេ» តែថែមទាំងបាន «ដុតផ្ទះប្រជាជនជាច្រើនខ្នងទៀតផង» ។ លើសពីនេះទៅទៀត ទាហានទាំងនោះបាន«កម្ទេចកាណូតខ្មាំងដែលដឹកប្រជាជនអស់ចំនួន២គ្រឿង ហើយមនុស្សដែលជិះនៅក្នុងកាណូតនោះត្រូវបានកម្ទេចគ្មានសល់ ។ ដូច្នេះជាលទ្ធផល យើងបានកម្ទេចខ្មាំងចំនួន៣០ក្បាលនៅថ្ងៃទី១៨ ខែមេសានោះ» ។ ចំពោះការខូចខាតបណ្តាលមកពី«ការបន្តបាញ់ផ្លោង»គ្រាប់រ៉ុក្កែត១០៧មីលីម៉ែត្រទៅលើផ្សារទីរួមខេត្តវៀតណាមនៃតំបន់ ហុកងឺ មិនទាន់ដឹងនៅឡើយទេ ចំណែកនៅសមរភូមិក្រោយវិញប្រជាជនកម្ពុជាដែលថាត្រូវបានប្រមូលយកទៅដោយកងទ័ពវៀតណាម ហើយឥឡូវនេះយើង«បានប្រមូលមកវិញ» នោះ «កំពុងតែទទួលការអប់រំកសាងខ្លួនចែកចេញជាមុខសញ្ញាផ្សេងៗនិងសម្អាតជាបណ្តើរៗ» ។ សារមួយទៀតដែលផ្ញើមកតាមក្រោយមកពីប៉ូពាំបានពន្យល់ហេតុផលថា ប្រជាជនធម្មតាដែលរស់នៅជិតព្រំដែនត្រូវបានប្រមូលមកសមរភូមិក្រោយវិញ ហើយកំពុងត្រូវបានប្រជុំអប់រំឥតឈប់ឈរ ។ លើសពីនេះទៀត ខ្សែរយៈខ្មាំងយួនកំពុងតែត្រូវបានបោសសម្អាតដើម្បីកុំឲ្យពួកវាបន្តបញ្ឆោតប្រឡូកប្រឡំជាមួយប្រជាជន ហើយពួកវាទាំងនោះកំពុងតែស្ថិតនៅក្នុងការប្រុងប្រយ័ត្នរបស់យើង និងទទួលការអប់រំដោយឡែកៗពីគ្នា ។*

*សារមួយទៀតចុះថ្ងៃទី២០ ខែមីនា បានរាយការណ៍ថាការវាយប្រហាររបស់វៀតណាមហាក់ដូចជាផ្តោតតែទៅលើកម្លាំងតំបន់មួយចំនួននៅភូមិភាគប៉ូពាំដែល«អា»កម្មាភិបាលនៅតំបន់នោះបានផ្តល់ព័ត៌មានសម្ងាត់ទៅឲ្យវៀតណាម ហើយថា «វិធានការ»កំពុងតែត្រូវបាន«ប្រើប្រាស់ជាមួយការផ្តើមគំនិតប្រឆាំងនឹងសមាសភាពមិនល្អ»នៅក្នុងជួរកម្លាំងតំបន់ ។ ព្រមជាមួយគ្នានេះ មានសារមួយចំនួនតូចទៀតត្រូវបានចម្លងជូន នួន ប៉ុន្តែមិនជូន វ៉ាន់ ទេ ។ ជាទូរលេខមួយចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ មកពី សុន សេន ដែលរាយការណ៍អំពីការចាប់ខ្លួនជនជាតិវៀតណាមពីរនាក់ដោយគណៈកងពលមជ្ឈិមលេខ១៨០ ។ លេខាកងពលឈ្មោះ សម ហួយ ហៅ មាស តាល់ (ក្រោយមកត្រូវបានបោសសម្អាត) ត្រូវបានទទួលការណែនាំឲ្យបញ្ជូនអ្នកទោសទៅកាន់មន្ទីរសន្តិសុខ ស-២១ ។ ទូរលេខមួយទៀតចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ មកពីលេខាភូមិភាគកណ្តាលឈ្មោះ ពក រាយការណ៍ថា ទាហានតំបន់៤១ បានចាប់មនុស្សបាន២នាក់ដែលអះអាងថាខ្លួនជាយុទ្ធជននៅគណៈកងពល៥០២ ។ នៅក្នុងសារនេះដែលត្រូវផ្ញើជូនចំពោះ «គណៈ៨៧០» ពក បានស្នើឲ្យអង្គការពិនិត្យប្រវត្តិអ្នកទោសជាមួយនឹងលេខាកងពលធំលេខ៥០២ឈ្មោះ ម៉េត រួចហើយសុំផ្តល់ទៅខ្លួនវិញ ។*

*ប៉ុន្តែផ្ទុយទៅវិញ មានឯកសារខ្លះត្រូវបានចម្លងជូន អៀង សារី ប៉ុន្តែមិនបានជូន នួន ទៅវិញ ។ ដូចជាទូរលេខមួយច្បាប់ចុះថ្ងៃទី៨ ខែមេសា របស់ សុន សេន បានរាយការណ៍ថាគណៈកងពលមជ្ឈិមលេខ៧០៣ ឈ្មោះ ភិន (ក្រោយមកត្រូវបានបោសសម្អាត) ត្រូវទទួលរងរបួសពេលដែលរថយន្តរបស់ខ្លួនបានជាន់មីនប្រឆាំងរថក្រោះ ហើយឧបទ្ទវហេតុនេះត្រូវបានទម្លាក់កំហុសទៅលើ«ខ្មាំងផ្ទៃក្នុង» ។ ជាលទ្ធផលឃើញថាមានការប្រឹងប្រែងក្នុងការ«វាយតម្លៃនិងស៊ើបអង្កេតរកខ្មាំងផ្ទៃក្នុងដើម្បីនឹងចាត់វិធានការទាន់ពេល» ។ សារមួយទៀតនៅថ្ងៃដដែលនោះដែរបានរាយការណ៍ថា កងកម្លាំងបានចូលទៅទី*

ប្រជុំជន«ដុងថាប» និងផ្សារភាគខាងត្បូងត្រពាំងពាមនិងតឹងចូវ ។ តំបន់ទាំងនេះសុទ្ធតែស្ថិតនៅក្នុងទឹកដីវៀតណាម ។ ហើយកងទ័ពទាំងនោះក៏បាន«បង្កឲ្យមានមនុស្សស្លាប់និងរបួសជាច្រើននាក់ព្រមទាំងដុតផ្ទះឆេះអស់ជាច្រើនរយខ្នង» ។ ទូរលេខនេះក៏បានរាយការណ៍បន្ថែមថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យកំពុងតែបន្តបាញ់ផ្លោងកាំភ្លើង១០៧មីលីម៉ែត្រ និងដេកា៧៥ ជាច្រើនគ្រាប់ចូល«តឹងចូវ»ឥតដាច់ ។ សារនេះដែលត្រូវបានចម្លងជូនចំពោះ វ៉ាន់ បានបន្ថែមថា «សភាពការណ៍នៅតាមមូលដ្ឋាន» នៅក្នុងប្រទេសកម្ពុជា«គឺថាយើងកំពុងតែបន្តការបោសសម្អាតម្តងមួយៗ» ។

### ខៀវ សំផន

គ្មានរបាយការណ៍ពីមូលដ្ឋានណាមួយត្រូវបានចម្លងជូន ខៀវ សំផន ឡើយ ។ ប្រការនេះប្រហែលជាអាចមានការភ្ញាក់ផ្អើលបើតាមសម្តីរបស់ អៀង សារី ដែលថា ក្នុងនាមជាគណៈមន្ទីរមជ្ឈិម៨៧០ ខៀវ សំផន អាចបានទទួលនិងមើលឯកសារជាច្រើនទាក់ទងនឹងសភាពការណ៍ទូទៅ ។ ប៉ុន្តែអាចថា ខៀវ សំផន បានទទួលឯកសារទាំងអស់ ពីព្រោះតាមការបញ្ជាក់ខាងលើ ក្រៅពីចម្លងជូនសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានការិយាល័យនៅភ្នំពេញនៅមានចំណារផ្ញើជូន«មន្ទីរ»និង«ផ្នែកឯកសារ» ឬ«បណ្ណសារ» ។

មន្ទីរនេះអាចមានមួយណាស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ខៀវ សំផន ឬអាចថាមន្ទីររបស់ ខៀវ សំផន ទទួលបន្ទុកបណ្ណសារគណៈកម្មាធិការមជ្ឈិមបក្ស ឬក៏អាចពិតទាំងពីរ ។ ប្រសិនបើដូច្នេះមែននោះ ទោសកំហុសអំពីការដឹងឮ ហើយមិនព្រមចាត់វិធានការទប់ទល់ជាករណីគួរពិចារណា ។

### ឯកសាររបស់សេនាធិការ ស៊ូ ម៉េត និង មាស មុត

ឯកសារកំណត់ហេតុប្រជុំរបស់យោធាគណៈកម្មាធិការមជ្ឈិមព្រមទាំងសារផ្សេងៗទៀតរបស់ សុន សេន និងអង្គភាពទាំងនោះមានការពាក់ព័ន្ធកម្មាភិបាលបក្សកុម្មុយនិស្តពីរនាក់ដែលនៅថ្នាក់ក្រោមកម្មាភិបាលជាន់ខ្ពស់មួយកម្រិតគឺមានឈ្មោះ ស៊ូ ម៉េត អតីតលេខាគណៈកងពលមជ្ឈិមលេខ៥០២ ដែលស្ថិតក្នុងក្របខ័ណ្ឌទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យ និងឈ្មោះ មាស មុត អតីតលេខាកងពលមជ្ឈិមលេខ១៦៤ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌទ័ពជើងទឹក ។ ម៉េត បានចូលរួមប្រជុំអគ្គសេនាធិការយ៉ាងទៀតទាត់ ចំណែកឯ មុត ចូលរួមម្តងម្កាល ។ ម៉េត និង មុត បាននិយាយជាមួយសមមិត្តដែលធ្វើការជាមួយគ្នាស្តាប់របាយការណ៍ និងសេចក្តីប្រកាសរបស់ សុន សេន ។

ឯកសារប្រជុំអគ្គសេនាធិការទាំងនេះផ្តល់នូវព័ត៌មានស្តីពីការពាក់ព័ន្ធរបស់អង្គភាពនិងលេខារបស់ខ្លួន ក្នុងការចាប់ខ្លួនទាំងប្រជាជនសាមញ្ញ កម្មាភិបាល និងយុទ្ធជន ការដឹងឮអំពីការចាប់ខ្លួនដូចជាបង្ហាញប្រាប់របស់ សុន សេន និងកម្មាភិបាលកងពលនិងវរសេនាធំដែលបានចូលរួមចាប់ (ភាគច្រើនស្ទើរតែទាំងអស់នៃអ្នកទាំងអស់នោះបានស្លាប់អស់ហើយ) ព្រមទាំងការដឹងឮពីការ «កម្ទេច» និង «ការបោសសម្អាត» រួមទាំងការបោសសម្អាតជនរងគ្រោះដែលត្រូវបានដាក់ឈ្មោះថា «មេក្លោងជនក្បត់» ។ ទីត តែម័រ ធ្វើសេចក្តីសន្និដ្ឋានថា ឯកសារទាំងនេះ «អាចប្រើជាប្រភពបណ្តោះអាសន្ន



បង្កើតជាធាតុផ្សំផ្សេងៗស្តីពីការទទួលខុសត្រូវក្នុងការសមគំនិតរបស់ ស៊ូ ម៉េត និង មាស មុត» ប្រព្រឹត្តបទឧក្រិដ្ឋកម្មអន្តរជាតិ ហើយជាពិសេស«អាចធ្វើជាភ័ស្តុតាងផ្ទាល់ឬភ័ស្តុតាងជាក់ច្បាស់» បង្ហាញថា«មានការពាក់ព័ន្ធ ក្នុងការធ្វើផែនការ ជំរុញ ឬបញ្ជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយខ្លួនបានដឹងថាពីការចូលរួមនិងការសម្រេចចិត្តយ៉ាងច្បាស់ក្នុងការចូលរួមប្រព្រឹត្ត» ។

ជាពិសេសជាងនេះទៀត ឯកសារ«ក៏អាចធ្វើជាភ័ស្តុតាងបង្ហាញថាជនសង្ស័យ...ទាំងនោះបានដឹងឮនិងជំរុញបញ្ចុះបញ្ចូល ឬក៏បញ្ជាឲ្យប្រព្រឹត្តអំពើឃោរឃៅក្នុងនាមជាអ្នកឧបត្ថម្ភនិងជ្រោមជ្រែងឲ្យមានអំពើឃោរឃៅ ។

នៅក្នុងសារជូនចំពោះ សុន សេន នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ មុត បានរាយការណ៍អំពីការចាប់ខ្លួនមនុស្ស៨នាក់ ដោយកងពលធំលេខ១៦៤ និងការសួរចម្លើយជនម្នាក់ក្នុងចំណោមជនទាំង៨នាក់ ។ ចម្លើយសារភាពរបស់ជននោះបានបញ្ជាក់ថា អ្នកដែលត្រូវបានចាប់ខ្លួនត្រូវបានឃុំឃាំងជាសមាជិក...«ក្រុមចោរព្រៃដែលកំពុងលាក់ខ្លួននៅម្តុំខាងលិចនិងខាងជើងវាលរេញ»ស្រុកព្រៃនប់ និងកំពុងធ្វើការប្រឆាំងផ្នែកនយោបាយ«ក្នុងចំណោមមហាជនតាមមូលដ្ឋាន» ។

ម៉េត បានចូលរួមកិច្ចប្រជុំកម្មាភិបាលដឹកនាំកងពលគណៈកងពលមជ្ឈិមនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦ ដែលនៅពេលនោះលេខានានាបានរាយការណ៍អំពីការចាប់ខ្លួនធ្វើឡើងដោយអង្គភាពនីមួយៗ ។ ពីន លេខាកងពល៧០៣ (ក្រោយមកត្រូវបានបោសសម្អាត) បានប្រាប់ដល់អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំអំពីការចាប់ខ្លួន«ជនពីរនាក់ដែលមានរូបរាងស្គមស្គាំង សក់វែង»...នៅផ្សារថ្មីភ្នំពេញ ក្នុងខណៈដែល សំ ហួយ ហៅ មាស តាល់ (ក្រោយមកត្រូវបោសសម្អាត) ដែលជាលេខាកងពល១៨០(២៩០)រាយការណ៍ថាកងពលបានចាប់ខ្លួន«ខ្មាំង៤នាក់» «ពួកសេ.អ៊ី.អា២នាក់និងទាហាន២នាក់» ។




របាយការណ៍ស្ដីពីសភាពការណ៍សេនាធិការក្នុងអំឡុងពេលពីពាក់កណ្ដាលខែកក្កដារហូតដល់ខែសីហា ឆ្នាំ១៩៧៦ កត់សម្គាល់ថាកងពលលេខ១៦៤បានចាប់ខ្លួន«កម្មករ»៤នាក់ដែលបាន«កាត់ខ្សែលួសចូលឃ្លាំងរំសេវ»នៅចុងខែកក្កដា ។ ជនទាំង៤នាក់ត្រូវបានចាប់ខ្លួនបញ្ជូនទៅ«នគរបាល»រួចហើយ ។

**(នៅមានត)**

**ស៊្វីច ហេង៉េរ**

# វិធីបួនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្មប្រព្រឹត្តឡើងនៅក្នុងសម័យខ្មែរក្រហម

**(តពីលេខមុន)** ចំណុចចាប់ផ្តើមដែលជាផ្នែកមួយនៃនិយមន័យផ្សេងៗស្តីអំពីឧក្រិដ្ឋកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងមិនអាចអនុវត្តបានឡើយ ។

សេចក្តីសន្និដ្ឋានរបស់ក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិចំពោះប្រធានបទនេះគឺថា ទោះបីជាតុលាការ(អាចនឹង) ត្រូវត្រួតពិនិត្យយ៉ាងដិតដល់ថាតើកម្រិតឧក្រិដ្ឋកម្មនៃអំពើទារុណកម្មដែលមានត្រឹមឆ្នាំ១៩៧៥បានចូលទៅក្នុងបទដ្ឋាននៃច្បាប់(Millum Crimen Lege)ក៏ដោយ ប៉ុន្តែការបញ្ចូលអំពើទារុណកម្មនៅក្នុងលក្ខន្តិកៈនៃតុលាការមួយហាក់ដូចជាបង្ហាញនូវភាពសមហេតុសមផល(របាយការណ៍ទំព័រទី២៣) ។









រ៉ាតន័រ និង អាប្រាម (ការទទួលខុសត្រូវចំពោះមុខច្បាប់ ទំព័រទី២៥៥ដល់ ២៥៦) សម្តែងនូវចម្ងល់របស់ខ្លួនថា តើអំពើទារុណកម្មអាចត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មដោយឡែកក្រោមច្បាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ដែរឬទេ? ។ ប៉ុន្តែប្រសិនបើតុលាការសម្រេចឲ្យអំពើនេះចូលទៅក្នុងអំពើឧក្រិដ្ឋកម្មយើងនឹងនិយាយថា«ពេលនោះកំណត់ហេតុប្រវត្តិសាស្ត្របន្សល់ទុកតែការងឿងឆ្ងល់បន្តិចបន្តួចប៉ុណ្ណោះទាក់ទងនឹងការទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដូចដែលបណ្ណសារដ្ឋានទួលស្លែងជាភ័ស្តុតាងស្រាប់ កម្ពុជាប្រជាធិបតេយ្យបានធ្វើទារុណកម្មជាលក្ខណៈប្រព័ន្ធទៅលើខ្មាំងរបស់របបដែលខ្លួនកាប់សម្លាប់អស់ជាច្រើនសែននាក់ ។ ភ័ស្តុតាងបញ្ជាក់ពីទោសបុគ្គលមានលក្ខណៈខ្វាំងចំពោះទង្វើទាំងនេះជាងឧក្រិដ្ឋកម្មផ្សេងទៀត» ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីពង្រាងច្បាប់ស្តីពីការបង្កើតការិយាល័យចៅក្រមវិសាមញ្ញនៅក្នុងតុលាការមិនមាន«ខ»ដោយឡែកទាក់ទងនឹងទារុណកម្មដែលជាឧក្រិដ្ឋកម្មដាច់ដោយឡែកក្រោមច្បាប់អន្តរជាតិឡើយ ។

### ៤) ទារុណកម្មជាឧក្រិដ្ឋកម្មសារធាតុក្រោមពង្រាងច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជា

មាត្រាទី៥០០ នៃច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហាមប្រាមការប្រើអំពើទារុណកម្ម ។ និយមន័យរបស់ច្បាប់នេះចំពោះអំពើទារុណកម្មមានលក្ខណៈដូចគ្នាទៅនឹងនិយមន័យដែលទទួលយកបានដោយអន្តរជាតិ ទោះបីជាការអនុវត្តជាផ្លូវការមិនត្រូវបានលើកយកមកនិយាយនៅក្នុងនិយមន័យនោះក៏ដោយ ។ ដោយសន្និដ្ឋានថា ច្បាប់ព្រហ្មទណ្ឌបានចូលជាធរមានក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រហែលជាអ្នកខ្លះមានមន្ទិលសង្ស័យអំពីបញ្ហានេះ ។ ប៉ុន្តែទោះបីជាច្បាប់នេះមិនបានបង្ហាញថាកម្ពុជាប្រជាធិបតេយ្យបានលុបចោលនូវច្បាប់ព្រហ្មទណ្ឌនេះពេលដែលខ្លួនឡើងកាន់អំណាចក៏ដោយ (សូមមើល អាប្រាម និង រ៉ាន័រ «ប្រយុទ្ធដើម្បីយុត្តិធម៌ ការទទួលខុសត្រូវចំពោះមុខច្បាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម» ទំព័រ១៨៩) ប៉ុន្តែការកាត់ទោសអាចមានលក្ខណៈងាយស្រួលជាងក្រោម«ខ»ផ្សេងៗ

នៃច្បាប់នេះ ពីព្រោះធាតុផ្សំបន្ថែមផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ជាប្រព័ន្ធឬជាទ្រង់ទ្រាយធំក្តីដែលអាចទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ) ខុក្រិដ្ឋកម្មសង្គ្រាម(ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ការការពារដោយច្បាប់ចំពោះក្រុមណាមួយ) នឹងមិនត្រូវការចាំបាច់បង្ហាញឡើយ ។ ក៏ប៉ុន្តែចុងចោទអាចសុំឲ្យមានការស្តាប់ពីការការពារក្តីរបស់ខ្លួនមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌដែលអាចនឹងឲ្យចុងចោទទទួលការការពារក្តីដែលខ្លួនមិនអាចមាន ឬក៏អាចទទួលបានតាមក្រោមច្បាប់អន្តរជាតិប៉ុន្តែមានកម្រិតមិនស្មើគ្នា ។ ករណីនេះជាមួយនឹងការការពារក្តីផ្សេងៗអាចទាក់ទងនឹងភាពមិនគ្រប់វ័យ(អាយុ) ការបង្ខិតបង្ខំ ឬបញ្ជាពីថ្នាក់លើ ។

ការគំរាមកំហែងយ៉ាងខ្លាំងក្លាមិនឲ្យមានការកាត់ទោសបានជោគជ័យក្រោមច្បាប់ក្នុងស្រុក គឺប្រហែលជាការចាត់ចែងឬកំណត់នូវដែនអាជ្ញាយុកាល ។ ករណីនេះអាចរារាំងការកាត់ក្តីអំពើទារុណកម្មក្រោមច្បាប់ក្នុងស្រុកឆ្នាំ១៩៨៩ ប្រសិនបើមិនមានការស៊ើបអង្កេតមុនឆ្នាំនោះទេ ដោយសារតែអំឡុងពេលនៃការកាត់ទោសមានរយៈពេលត្រឹមតែ១០ឆ្នាំប៉ុណ្ណោះ ។

រ៉ាតន័រ និង អាប្រាម («ដើម្បីយុត្តិធម៌» ទំព័រ១៩៥,១៩៦) លើកមកពិភាក្សានូវការបកស្រាយបីយ៉ាងនិងជម្រើសផ្សេងៗទៀតដែលព្រះរាជអាជ្ញានិងតុលាការអាចមានដូចដែលធ្វើការសង្ខេបជូនដូចខាងក្រោម÷

ទី១ រ៉ាតន័រ និង អាប្រាម អះអាងថា ការគ្មានប្រព័ន្ធតុលាការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៥ បានផ្អាកនូវដែនសមត្ថកិច្ចតាំងពីពេលនោះមក ។ ការកែលម្អករណីនេះអាចធ្វើឲ្យមានដំណើរឆ្ពោះទៅមុខបានដោយការធានាថាមេដឹកនាំខ្មែរក្រហមនឹងមិនទទួលផលប្រយោជន៍ពីការបំផ្លាញរបស់ខ្លួនចំពោះប្រព័ន្ធច្បាប់កម្ពុជាក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ៧០ឡើយ ។ ទោះបីជាច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនមានការសន្និដ្ឋានច្បាស់លាស់អំពីប្រព័ន្ធតុលាការដែលគ្រប់គ្រងដោយរដ្ឋាភិបាលកាន់កាប់ទឹកដីយ៉ាងណាក៏ដោយ ក៏ការណ៍នេះមិនមានអស្ថិរភាពតាំងពីឆ្នាំ១៩៧៩ ឡើយ ។

តាមគំនិតរបស់ខ្ញុំជាមួយនឹងអំណះអំណាងនេះ ដោយសារការដោះស្រាយបញ្ហាមួយ មនុស្សម្នាក់អាចនឹងបង្កឲ្យមានបញ្ហាមួយទៀតបាន ។ ប្រសិនបើតុលាការមានបំណងសន្និដ្ឋានថា ដែនអាជ្ញាយុកាលត្រូវបានពន្យារដោយមូលហេតុដូចដែលបានរៀបរាប់មកខាងលើ ផ្អែកតាមគោលការណ៍ដែលថាគ្មានជនណាម្នាក់អាចដំឡើងឋានៈខ្លួនតាមការប្រព្រឹត្តខុសនោះ នឹងមានសំណួរចោទឡើងថាតើមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវកាត់ទោសទទួលខុសត្រូវមិនមែនចំពោះតែការខ្វះប្រព័ន្ធតុលាការមានប្រសិទ្ធភាពក្នុងអំឡុងពេលដែលខ្លួនកាន់អំណាច ប៉ុន្តែថែមទាំងចំពោះពេលវេលាក្រោយមកទៀតដែរឬទេ ។ បើធ្វើដូច្នេះមែន មេដឹកនាំទាំងនោះនឹងមិនទាញផលប្រយោជន៍ពីដែនអាជ្ញាយុកាលនោះឡើយ ។ មិនតែប៉ុណ្ណោះទៀតសោត អំណះអំណាងនេះអាចពិតបានប្រសិនបើមានការបង្ហាញថាពិតជាគ្មានប្រព័ន្ធតុលាការមានប្រសិទ្ធភាពក្រោយពីឆ្នាំ១៩៧៩មែន ។ វានឹងមានការងឿងឆ្ងល់ថា តើព្រះរាជអាជ្ញាកម្ពុជានឹងយកការសន្និដ្ឋាននេះជាមូលដ្ឋានរបស់ខ្លួនដែរឬទេ ។

ទី២ តុលាការមួយអាចកំណត់ថាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំបាំងមុខកាលពីឆ្នាំ១៩៧៩ ដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើឡើងដើម្បីពន្យារដែនអាជ្ញាយុកាល និងថាទាំងរដ្ឋាភិបាលមុនទាំងរដ្ឋាភិបាលក្រោយបាននឹងកំពុងធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមកើតឡើងកាលពីសម័យនោះ ។ ជាក់ស្តែងនៅដើមទសវត្សរ៍ឆ្នាំ៨០ មានការស៊ើបអង្កេតដ៏ធំមួយពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប៉ុលពតរៀបចំឡើងដោយគណៈកម្មាធិការស្រាវជ្រាវរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ លទ្ធផលនៃគម្រោងសិក្សាស្រាវជ្រាវដ៏ធំនេះត្រូវបានបោះពុម្ពក្នុងឆ្នាំ១៩៨៣ ។ ការស៊ើបអង្កេតដែលចេញដីកាដោយរដ្ឋអំណាចតុលាការតាមពិតប៉ះពាល់ដល់ដែនអាជ្ញាយុកាលក្រោម«ខ»ផ្សេងៗនៃច្បាប់ព្រហ្មទណ្ឌ ។ តុលាការមួយនឹងត្រូវតែដោះស្រាយបញ្ហាដែលថាតើការស៊ើបអង្កេតរបៀបនេះនឹងត្រូវបានចាត់ទុកថាជាការស៊ើបអង្កេតដែលប៉ះពាល់ដល់ដែនអាជ្ញាយុកាលតាមច្បាប់ព្រហ្មទណ្ឌដែរឬទេ ។

រ៉ាតន័រ និង អាប្រាម និយាយថា កំហុសនៃជម្រើសនេះគឺមានលក្ខណៈច្បាស់ណាស់គឺថា ការជម្រះក្តីឆ្នាំ១៩៧៩

គ្មានតម្លៃខាងផ្លូវច្បាប់ ហើយតាំងពីពេលនោះមករដ្ឋអំណាចកម្ពុជាមិនទាន់បានធ្វើនៅឡើយទេនូវការស៊ើបអង្កេតព្រហ្មទណ្ឌដោយសុទ្ធចិត្ត លើអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ជាក់ស្តែងរដ្ឋអំណាចទាំងនោះមិនបានគិតថាការស៊ើបអង្កេតដែលរៀបរាប់ខាងលើជាការស៊ើបអង្កេតព្រហ្មទណ្ឌដូចដែលចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌឡើយ ។

ទី៣ ច្បាប់ក្នុងស្រុកនឹងអាចត្រូវបានអនុម័តឲ្យមានការពន្យារឬលុបបំបាត់ដែនអាជ្ញាយុកាលក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមទាំងអំពើប្រល័យពូជសាសន៍ ។ គំនិតនេះមានគ្រប់គ្រាន់រួចហើយ ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលជាផ្នែកមួយនៃច្បាប់អន្តរជាតិមិនមានដែនអាជ្ញាយុកាលឡើយ ហើយអនុសញ្ញាឆ្នាំ១៩៨៤ប្រឆាំងនឹងអំពើទារុណកម្មក៏មិនមានដែរ ។ ប្រសិនបើអំពើទារុណកម្មអាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកត្រឹមឆ្នាំ១៩៧៥នោះ អាចមានការជជែកវែកញែកដោយផ្អែកលើហេតុផលទាំងនេះថា ក្រោមកាតព្វកិច្ចនៃច្បាប់អន្តរជាតិ ដែនអាជ្ញាយុកាលក្នុងស្រុកមិនអាចអនុវត្តចំពោះអំពើទារុណកម្មឡើយ ។ ប៉ុន្តែតាមគំនិតខ្ញុំ ចុងចោទមានជំហររឹងមាំដោយឲ្យហេតុផលការពន្យារឬលុបបំបាត់ដែនអាជ្ញាយុកាល ហើយសូម្បីតែក្រោយពេលនៃការកាត់ទោសក៏ដោយ វាផ្ទុយទៅនឹងការការពារដោយច្បាប់ក្នុងស្រុក ។ ប៉ុន្តែពង្រាងច្បាប់ពន្យារដែនអាជ្ញាយុកាល២០ឆ្នាំទៅមុខទៀតចំពោះអំពើមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាដែលឧក្រិដ្ឋកម្មទាំងនេះស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ការិយាល័យចៅក្រមវិសាមញ្ញ(មាត្រា៣) ។


ក្មេងប្រុសនេះត្រូវទាហានខ្មែរក្រហមចោះបំពង់កសម្លាប់ ប៉ុន្តែមិនស្លាប់ ។

## សេចក្តីសន្និដ្ឋាន

មូលដ្ឋានច្បាប់ទាំងឡាយណាក្នុងការបង្កើតការកាត់ក្តីលើអំពើទារុណកម្មសុទ្ធតែមានចំណុចចាប់ផ្តើមនិងបញ្ហាភ័ស្តុតាងរបស់វា ។ ឧក្រិដ្ឋកម្មសង្គ្រាមមិនអាចប្រព្រឹត្តទៅដោយគ្មានជម្លោះប្រដាប់អាវុធឡើយ ហើយក៏មិនអាចមិនប្រឆាំងនឹងជនទាំងឡាយឬទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវដែរ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមសារជាតិមានទ្រង់ទ្រាយធំហើយនិងមានលក្ខណៈជាប្រព័ន្ធដែលប្រហែលជាតម្រូវឲ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ។ អំពើទារុណកម្មគឺជាសារធាតុក្រោមច្បាប់អន្តរជាតិ ប៉ុន្តែថាតើវាពិតដែរឬទេក្នុងករណីសភាពការណ៍អំឡុងឆ្នាំ១៩៧៥-៧៩ ។ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថាអំពើទារុណកម្មគឺជាបទដ្ឋានសារវ័ន្តនិងដាច់ខាតត្រឹមឆ្នាំ១៩៧៥ ។

ចំពោះចំណុចចុងក្រោយ អំពើទារុណកម្មគឺជាបទឧក្រិដ្ឋកម្មក្រោមច្បាប់ក្នុងស្រុក ប៉ុន្តែជាក់ស្តែងរយៈពេលសម្រាប់កាត់ក្តីបានរលប់ផុតបាត់ទៅហើយ ។ នៅមិនទាន់ច្បាស់នៅឡើយថាតើដំណោះស្រាយចំពោះបញ្ហាច្បាប់អាចនាំមកនូវការពន្យារឬការលុបចោលនូវដែនអាជ្ញាយុកាលដែរឬទេ ដរាបណាដំណោះស្រាយនោះចាត់ទុកថាអំពើទារុណកម្មជាបទឧក្រិដ្ឋក្រោមច្បាប់ក្នុងស្រុកក្រោយពេលដែលដែនអាជ្ញាយុកាលផុតកំណត់ ។

**យ៉ន ឆ៉ាន់ គ្រីនធិន**

# ទាសភាព និង ទង្វើដែលទាក់ទងនឹងទាសភាព

អំពើទាសភាពជាប់ទាក់ទងបន្តបន្ទាប់គ្នាចាប់ពីបទល្មើសសីលធម៌រហូតដល់បទល្មើសឧក្រិដ្ឋកម្មអន្តរជាតិ ។ លិខិតូបករណ៍ដែលថ្កោលទោសអំពើទាសភាពគឺសេចក្តីប្រកាស«ថ្លែងការណ៍» លេខ១៨១៥ទាក់ទងទៅនឹងការលុបចោលជាសកលនូវពាណិជ្ជកម្មទាសករ (ការចាប់មនុស្សឲ្យស៊ីឈ្នួល) ចុះហត្ថលេខាទទួលស្គាល់ដោយប្រទេសមហាអំណាចអឺរ៉ុបភាគច្រើនដែលជាផ្នែកមួយនៃមហាសន្និបាតនៅទីក្រុងវីយែន ប្រទេសអូទ្រីស ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះ ប្រទេសមហាអំណាចអឺរ៉ុបបានថ្កោលទោសលើពាណិជ្ជកម្មទាសករថាជាអំពើគួរឲ្យស្អប់ខ្ពើមរំលោភលើគោលការណ៍នានានៃមនុស្សជាតិនិងសីលធម៌ជាសកល ។ សេចក្តីថ្លែងការណ៍នោះបង្កើតឡើងនូវកាតព្វកិច្ចសម្រាប់រដ្ឋហត្ថលេខីក្នុងការវិនិច្ឆ័យទោសនិងដាក់ទណ្ឌកម្មទៅលើការរំលោភបំពាននានា ។

ការហាមឃាត់ប្រឆាំងនឹងពាណិជ្ជកម្មទាសភាពបានពង្រីកខ្លួនកាន់តែធំឡើងនៅក្នុងអំឡុងសតវត្សរ៍ទី១៩ ។ សហគមន៍អន្តរជាតិទទួលស្គាល់មិនត្រឹមតែពីភាពមិនស្របច្បាប់នៃពាណិជ្ជកម្មទាសករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការអនុវត្តអំពើទាសភាពផ្ទាល់តែម្តង ។ ការទទួលស្គាល់របស់សហគមន៍អន្តរជាតិនូវភាពមិនគួរឲ្យទទួលយកបាននៃទាសភាព បានផុសចេញពីគោលការណ៍នៃច្បាប់ធម្មជាតិ ហើយទីបញ្ចប់ត្រូវបានចងក្រងឡើងនៅក្នុងលិខិតូបករណ៍អន្តរជាតិជាច្រើនទៀតផង ។ ការទទួលស្គាល់នូវភាពមិនស្របច្បាប់នៃអំពើទាសភាពនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកមួយចំនួនធំដែលមានកន្លងមក ជួយដល់ការបង្កើតឲ្យមានបទដ្ឋានច្បាប់អន្តរជាតិច្បាស់លាស់ជាច្រើនស្តីពីប្រធានបទនេះ ។ ការកើនឡើងនូវចំនួនប្រទេសដែលប្រឆាំងនឹងអំពើទាសភាពនៅក្នុងច្បាប់ក្នុងស្រុករបស់ប្រទេសខ្លួន រួមជាមួយនិងការកើនឡើងនៃកិច្ចព្រមព្រៀងអន្តរជាតិដែលថ្កោលទោសអំពើទាសភាពនិងពាណិជ្ជកម្មទាសភាព បាននាំដល់ការកើនឡើងនូវបទដ្ឋានច្បាប់ទម្លាប់នៅចុងសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០ ដែលហាមប្រាមដល់អំពើជួញដូរទាសករ ជាពិសេសអំពើទាសភាពនេះតែម្តង ។ និយាយម្យ៉ាងទៀត បទដ្ឋានច្បាប់អន្តរជាតិទាំងនេះគឺចេញមកពីការមូលមតិគ្នាទូទាំងសកលលោកប្រឆាំងនឹងអំពើទាសភាព ។

ឯកសារនិងលិខិតូបករណ៍ច្បាប់អន្តរជាតិផ្សេងៗគ្នាចំនួន៧៩ច្បាប់ សង្កត់ធ្ងន់ទៅលើពាណិជ្ជកម្មទាសករ អំពើទាសភាព ការបង្ខំឲ្យធ្វើការជាទម្ងន់ និងទង្វើដែលទាក់ទងទៅនឹងទាសភាពដទៃៗទៀត ។ ឧបករណ៍ទាំងនេះឆ្លុះបញ្ចាំងនិងផ្តល់សារៈសំខាន់ដល់គោលការណ៍ទូទៅនៃច្បាប់ដែលហាមប្រាមមិនឲ្យប្រព្រឹត្តអំពើទាសភាព ។ យោងទៅតាមសេចក្តីថ្លែងការណ៍ជាលើកទី៣នៃច្បាប់ទំនាក់ទំនងការបរទេសរបស់សហរដ្ឋអាមេរិក ផ្នែកទី៧០២ សេចក្តីថ្លែងការណ៍បានបញ្ជាក់ច្បាស់ថា ក្នុងច្បាប់អន្តរជាតិដែលកើតដោយទំនៀមទម្លាប់ ប្រសិនបើរដ្ឋមួយអនុវត្តគោលនយោបាយរបស់ខ្លួនដរុញបុក៏បណ្តាលឲ្យកើតឡើងនូវអំពើទាសភាព ឬពាណិជ្ជកម្មទាសករ អនុវត្តការធ្វើទារុណកម្មនិងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬជាអំពើដែលនាំបាត់បង់តម្លៃជាមនុស្សនោះមានន័យថា រដ្ឋដែលលើកមកនិយាយនេះរំលោភទៅលើច្បាប់អន្តរជាតិ ។ ជាការប្រាកដណាស់ថា អំពើទាសភាពនៅក្នុងទ្រង់ទ្រាយគ្រឹះរបស់វា គឺជាការទិញនិងលក់បុគ្គលទាំងឡាយ និងទង្វើចាត់ទុកបុគ្គលទាំងនោះជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ អំពើនេះត្រូវបានទទួលស្គាល់ថាជាអំពើប្រព្រឹត្តផ្ទុយទាំងស្រុងទៅនឹងច្បាប់អន្តរជាតិកើតដោយទំនៀមទម្លាប់ ។ លើសពីនេះទៀត ទង្វើដូចជាអំពើទាសភាពនិងការបង្ខំឲ្យធ្វើការជាទម្ងន់អាចរាប់បញ្ចូលថាជាការធ្វើទារុណកម្មនិងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬជាអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស (មើលផ្នែកខាងក្រោម) គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ព្រោះការហាម

ឃាត់ទង្វើទាំងអស់នេះត្រូវតាំទ្រដោយការគោរពតម្លៃមនុស្សជាសារវ័ន្ត ។

ច្បាស់ជាងនេះទៅទៀត សំណួរថាតើទង្វើបែបនេះណាមួយនៅក្នុងការហាមឃាត់ប្រឆាំងនឹងអំពើទាសភាពនោះ ពុំសូវមានលក្ខណៈច្បាស់លាស់ឡើយ ។ ក្រៅពីប្រភេទទាសភាពដែលកំណត់ពីបុរាណ អំពើខុសច្បាប់ផ្សេងទៀតត្រូវបានកំណត់ឡើងដោយផ្អែកទៅលើកម្រិតនៃភាពឃោរឃៅអមនុស្សធម៌នៃអំពើទាំងនោះជាជាងផ្អែកទៅលើប្រភេទនៃអំពើទាំងនោះ ។ ដូចនេះទង្វើទាក់ទងនឹងអំពើទាសភាពដូចជាបង្ខំឲ្យធ្វើការជាទម្ងន់ អាចរាប់បញ្ចូលថាជាការធ្វើទារុណកម្ម ការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ ឬជាអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ។

ដូចបានជជែកខាងលើរួចមកហើយ តាំងពីដើមសតវត្សរ៍ទី១៩មក មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនធំទៅលើកិច្ចព្រមព្រៀងថ្កោលទោសនិងដាក់ឲ្យនៅក្រៅច្បាប់នូវអំពើទាសភាពនិងពាណិជ្ជកម្មទាសករ ។

អនុសញ្ញាស្តីពីអំពើទាសភាពឆ្នាំ១៩២៦ ដែលមានរដ្ឋមួយចំនួនធំជាភាគីហត្ថលេខី បានកំណត់អំពើទាសភាពនៅក្នុងមាត្រា១ ថាជា«ស្ថានភាពឬជាលក្ខខណ្ឌនៃមនុស្សម្នាក់ដែលត្រូវបានយកមកធ្វើជាកម្មសិទ្ធិ ឬប្រើអំណាចគ្រប់គ្រងដោយផ្នែកឬទាំងស្រុង» ។ និយមន័យនេះបង្ហាញថា អំពើជាច្រើនទៀតមិនត្រឹមតែអំពើទាសភាពដែលកំណត់ជាប្រពៃណីនោះទេ ត្រូវបានហាមឃាត់ដោយច្បាប់ទាបច្ចុប្បន្ន ។ នេះបង្ហាញថា ទំហំនៃការថ្កោលទោសរបស់សហគមន៍អន្តរជាតិចំពោះអំពើទាសភាពគឺមានទំហំប៉ុនគ្នាទៅនឹងការប្រឆាំងចំពោះទង្វើប្រើប្រាស់កម្លាំងមនុស្សបែបអមនុស្សធម៌ដទៃទៀតដែរ ។ រដ្ឋជាហត្ថលេខីទាំងឡាយនៅក្នុងអនុសញ្ញាឆ្នាំ១៩២៦ សន្យាយ៉ាងច្បាស់ក្នុងមាត្រា៥ថា «ត្រូវចាត់រាល់វិធានការចាំបាច់ទាំងឡាយក្នុងការទប់ស្កាត់កុំឲ្យការបង្ខំធ្វើការរីកធំឈានដល់លក្ខខណ្ឌដែលអាចចាត់ទុកថាជាអំពើទាសភាព» ។ អនុសញ្ញានេះចែងថាការបង្ខំឲ្យធ្វើការ«អាចត្រូវអនុវត្តបានដោយស្របច្បាប់តែសម្រាប់ការងារបម្រើជាសាធារណៈតែប៉ុណ្ណោះ» ។ ហើយនៅទីណាដែលមានការបង្ខំឲ្យធ្វើការ ឬក៏កាតព្វកិច្ចក្រៅគោលបំណងសាធារណៈនោះ ភាគីនៃអនុសញ្ញាត្រូវតែខំប្រឹងប្រែងលុបបំបាត់នូវទង្វើទាំងនោះឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ ឧទាហរណ៍សង្គ្រាមនិងគ្រោះអាសន្ននៅក្នុងប្រទេសនឹងអាចរាប់បញ្ចូលជាគោលបំណងសាធារណៈបាន ។ ការបង្ខំឲ្យធ្វើការបែបនេះគឺត្រូវបានយល់ឃើញថាជាលក្ខណៈលើកលែងពិសេសមួយ ។ អ្នកណាក៏ដោយដែលត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ «ជានិច្ចកាលត្រូវទទួលនូវប្រាក់បំណាច់គ្រប់គ្រាន់» ។ ការបណ្តេញកម្មករចេញពីការងារក៏ត្រូវហាមឃាត់ដែរ ។ សរុបមក ការបង្ខំឲ្យធ្វើការបើត្រូវបានអនុវត្តក្រៅគោលបំណងសាធារណៈនោះ «មានន័យថាមិនចូលទៅក្នុងករណីលើកលែងពិសេស»ឡើយ ហើយមានលក្ខណៈអមនុស្សធម៌«ពាក់ព័ន្ធទៅនឹងការបញ្ជូនទៅកន្លែងផ្សេងដោយបង្ខំ ឬក៏ការឲ្យប្រាក់ខែមិនគ្រប់គ្រាន់» ត្រូវរាប់បញ្ចូលថាជាអំពើទាសភាពដែលជាការរំលោភលើសន្ធិសញ្ញានេះ ។

អនុសញ្ញាឆ្នាំ១៩៣០ដែលទាក់ទងដល់ការបង្ខំឲ្យធ្វើការ ឬកាតព្វកិច្ចពលកម្ម «អនុសញ្ញាស្តីពីការបង្ខំឲ្យធ្វើការ» ពង្រឹងនូវទស្សនៈនេះដោយគូសបញ្ជាក់ថា ការបង្ខំឲ្យធ្វើការជាទម្ងន់គឺជាការរំលោភជាទូទៅលើសិទ្ធិមនុស្ស ។ រដ្ឋជាហត្ថលេខីនៃអនុសញ្ញានេះបានសន្យាជាឧឡារិកថា«នឹងបង្ក្រាបទប់ស្កាត់អំពើបង្ខិតបង្ខំឲ្យធ្វើការជាទម្ងន់ក្នុងគ្រប់រូបភាពឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន» ។ ទោះជាយ៉ាងណាក៏ដោយ ជួនកាលការបង្ខិតបង្ខំឲ្យធ្វើការជាទម្ងន់អាចត្រូវបានប្រើប្រាស់ក្នុងគោលបំណងដូចតទៅៈ ដើម្បីបង្ខិតបង្ខំឲ្យ«ចូលបម្រើយោធា» ដើម្បីការដាក់ទណ្ឌកម្មចំពោះបទល្មើស ឬក៏សេវាពលកម្មដទៃទៀតដែលតម្រូវដោយភាពចាំបាច់ ឬគ្រោះអាសន្ននៅក្នុងប្រទេស ។ អនុសញ្ញានេះបានដាក់កម្រិតជាច្រើនលើការប្រើប្រាស់ការបង្ខំឲ្យធ្វើការដោយទាមទារឲ្យមានការគោរពចំពោះសិទ្ធិកម្មករទាំងអស់ ដូចជាផ្តល់ប្រាក់បំណាច់គ្រប់គ្រាន់ លក្ខខណ្ឌការងារដ៏មានសុវត្ថិភាព ម៉ោងធ្វើការអតិបរមា គោរពដល់សិទ្ធិរបស់បុគ្គលនិងសិទ្ធិរបស់គ្រួសារ និងសិទ្ធិមិនត្រូវបណ្តេញចេញពីកន្លែងធ្វើការ ។ ក្នុងកាលៈទេសៈខ្លះ កម្មករអាចសម្តែងចេញដោយសេរីនិងស្របតាមឆន្ទៈរបស់ខ្លួនចំពោះកិច្ចសន្យាជុំវិញបញ្ហាការងារដោយផ្អែកទៅលើ



«ខ»បន្ទាប់បន្សំផ្សេងៗនៃអនុសញ្ញា ។ ម្យ៉ាងទៀត មាត្រា១៨ បញ្ជាក់យ៉ាងច្បាស់ថា «ការកេណ្ឌឲ្យទៅធ្វើការ អនុវត្តបាន លុះត្រាជននោះជាភេទប្រុសមានរាងកាយមាំមួន ហើយមាន អាយុរវាង១៨ឆ្នាំដល់៤៥ឆ្នាំ» ។ អនុសញ្ញាតម្រូវជាទូទៅថា ការបង្ខំឲ្យធ្វើការគឺត្រូវយកមកអនុវត្តម្តងម្កាលពេលដែលមានការ ចាំបាច់ ហើយត្រូវអនុវត្តក្នុងលក្ខណៈមនុស្សធម៌ ។

ទោះបីជារដ្ឋមួយចំនួនតូចជាភាគីហត្ថលេខីអនុសញ្ញាឆ្នាំ ១៩៣០ ក៏ដោយ ក៏អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់អំពើ ទាសភាព ការធ្វើពាណិជ្ជកម្មទាសករ និងការអនុវត្តនីងទង្វើនានា ដែលមានលក្ខណៈស្រដៀងគ្នាចំពោះអំពើទាសភាពឆ្នាំ១៩៥៦ ប្រកាសនៅក្នុងបុព្វកថារបស់ខ្លួនថា អនុសញ្ញាបន្ថែមនេះគឺត្រូវ បានបង្កើតឡើងដោយគោរពតាមអនុសញ្ញា ឆ្នាំ១៩៣០ ។ រដ្ឋជាច្រើនបានក្លាយជាសមាជិក អនុសញ្ញាបន្ថែមនេះ រួមមានប្រទេសកម្ពុជា ដែលបានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៥៧ ។ អនុសញ្ញា បន្ថែមនេះពង្រីកបន្ថែមនូវប្រភេទនៃការអនុវត្ត ដែលត្រូវបានហាមប្រាមនៅក្រោមអនុសញ្ញា ស្តីពីអំពើទាសភាពឆ្នាំ១៩២៦ ដែលភាព ជាកញ្ជះគេជំពាក់បំណុលតពូជការលក់ស្ត្រី ដើម្បីឲ្យរៀបអាពាហ៍ពិពាហ៍ និងការលក់កុមារ ឲ្យទៅពលកម្ម ជាអំពើខុសច្បាប់ ។ ការលុប បំបាត់ចោលនូវអនុសញ្ញាស្តីពីការបង្ខំឲ្យធ្វើការ ឆ្នាំ១៩៥៧ ដែលមានរដ្ឋជាសមាជិក៥២នាក់ បានពង្រីកបន្ថែមទៅលើការហាមឃាត់មុនៗ ប្រឆាំងនឹងការបង្ខំឲ្យធ្វើការ ។ នៅក្នុងមាត្រា១ រដ្ឋដែលជាហត្ថលេខីសន្យាថាមិនប្រើការបង្ខំ ឲ្យធ្វើការជាទម្ងន់តាមរយៈ

១) ជាមធ្យោបាយបង្ខិតបង្ខំផ្នែកនយោបាយ ឬការអប់រំ ឬជាការដាក់ចេញសម្រាប់ ដាក់ទណ្ឌកម្មចំពោះការសម្តែង ឬបញ្ចេញ ទស្សនៈនយោបាយ ឬទស្សនៈនានាដែល ប្រឆាំងផ្នែកមនោគមវិជ្ជាទៅនឹងប្រព័ន្ធសេដ្ឋកិច្ច នយោបាយ និងសង្គម ។ ២) ជាមធ្យោបាយនៃការប្រមូលផ្តុំនិងការប្រើប្រាស់ កម្លាំងពលកម្មសម្រាប់គោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ៣) ជាមធ្យោបាយនៃការដាក់វិន័យការងារ ។ ៤) ជាការ ផ្តន្ទាទោសចំពោះការដែលបានចូលរួមក្នុងការធ្វើកូដកម្ម ។ ៥) ជាមធ្យោបាយនៃការបែងចែកពូជសាសន៍សង្គមជាតិ ឬសាសនា ។ អំពើទាសភាពអនុវត្តឡើងដោយមានចេតនា បំផ្លិចបំផ្លាញដល់ក្រុមមួយដែលពឹងទៅលើលក្ខណៈពិសេស ដែលរៀបរាប់ដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ អាចឈានទៅដល់ទំហំដែលអាចក្លាយទៅជាអំពើប្រល័យ ពូជសាសន៍ ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**

# សៀវភៅខ្មៅ

## ទស្សនៈខ្មែរក្រហមចំពោះទឹកដីកម្ពុជាក្រោម

*បោះពុម្ពផ្សាយដោយមន្ទីរឃោសនាការនិងពត៌មាន*
*នៃក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ*
*ខែកញ្ញា ឆ្នាំ១៩៧៨*

### ១) អំពើឈ្លានពានវាតទីនិងលេបទឹកដីរបស់វៀតណាមក្នុងអតីតកាល

អំពើឈ្លានពាននឹងការលេបទឹកដីដោយប្រទេសវៀតណាមក្នុងអតីតកាលក៏ដូចជាបច្ចុប្បន្ន បានបង្ហាញយ៉ាងច្បាស់នូវសារជាតិពិតប្រាកដរបស់វៀតណាមជាសារជាតិនៃអ្នកឈ្លានពានវាតទីនិងលេបយកទឹកដីបណ្តាប្រទេសដទៃទៀត ។ ការវាតទីយកទឹកដីចម្ប៉ានិងកម្ពុជាក្រោមបានចង្អុលនូវសារជាតិពិតបែបនេះ ។

#### ក) ទឹកដីចម្ប៉ា

ប្រទេសចម្ប៉ាត្រូវបានបង្កើតឡើងនៅក្នុងសតវត្សរ៍ទី២ នៅក្នុងសម័យនគរភ្នំក្នុងប្រទេសកម្ពុជា ទឹកដីចម្ប៉ាបានលាតសន្ធឹងលើភាគកណ្តាលនៃប្រទេសវៀតណាមនាពេលបច្ចុប្បន្ននេះ ។ ប្រជាជននៃទឹកដីចម្ប៉ាត្រូវបានហៅថា«ចាម» ។ ចម្ប៉ាធ្លាប់មានអរិយធម៌ដ៏ភ្លឺត្រចះត្រចង់និងជាអរិយធម៌ដ៏ចំណាស់មួយនៅក្នុងអាស៊ីភាគអគ្នេយ៍ដូចដែលចង្អុលបង្ហាញដោយប្រាសាទមីសុន ។ ប្រជាជនវៀតណាមបានប្រព្រឹត្តនូវអំពើឈ្លានពានមកលើទឹកដីចម្ប៉ាឥតឈប់ឈរ ។

ក្នុងឆ្នាំ១៨៧១ ប្រជាជនវៀតណាមវាយយករាជធានីចម្ប៉ាឈ្មោះវិចាយ៉ា ហើយបានហៅទីក្រុងនេះថា «វិញឌីញ» ជាភាសាវៀតណាមវិញ ។ ចាប់ពីពេលនោះមកចម្ប៉ាចាប់ផ្តើមធ្លាក់ចុះហើយបានបាត់បង់អត្តសញ្ញាណជាតិបន្តិចម្តងៗ ។ ក្រោយមកវៀតណាមបានលេបយកទឹកដីចម្ប៉ាទាំងមូល ថែមទាំងបានស្រូបយកប្រជាជនចាមដែលរស់នៅភាគខាងត្បូងនៃរាជធានីវិចាយ៉ា ។

ក្នុងឆ្នាំ១៦១១ ប្រជាជនវៀតណាមបានឈ្លានពានយកទឹកដីហ៊ូយៀន នៅភាគខាងត្បូង ។ ក្នុងឆ្នាំ១៦៥៣ វៀតណាមឈ្លានពានយកតំបន់ ថាន់ ភាសាចាមហៅថា«កាន់តារ៉ា» នៅ

ក្បែរញ៉ាត្រាង និង ដាន់វ៉ាន ភាសាចាមហៅថា«ហាន់ឌូវ៉ាន់ហ្គា» ។

ក្នុងឆ្នាំ១៦៩៣ វៀតណាមបានលេបយកទឹកដីចម្ប៉ាទាំងមូលដោយវាតទីយកតំបន់ផានធាន ។ ពូជសាសន៍ចាមត្រូវបានបោសសម្អាតទាំងស្រុងដោយវៀតណាម ។ នៅក្នុងទិសដៅស្របគ្នាជាមួយនឹងការវាយលេបយកទឹកដីចម្ប៉ា វៀតណាមក៏បានដាក់នឹមអាណានិគមមកលើប្រជាជនឡាវ ។ បន្ទាប់ពីគ្រប់គ្រងយកទឹកដីចម្ប៉ាមក វៀតណាមបានបន្តបោះជំហានវាតទីទឹកដីឆ្ពោះមកកម្ពុជាក្រោម ហៅថា«កម្ពុជាភាគខាងត្បូង» ។

## ១) កម្ពុជាក្រោម

ទឹកដីកម្ពុជាក្រោមគឺជាទឹកដីមួយផ្នែកនៃទឹកដីវៀតណាមខាងត្បូងនាពេលបច្ចុប្បន្ន រួមមានតំបន់ភាគខាងលិចនៃទន្លេដូនញ៉ៃនិងដីសណ្តនៃទន្លេមេគង្គ ។ បារាំងហៅទឹកដីកម្ពុជាក្រោមថា «កូសាំងស៊ីន» ។ ទឹកដីនេះជាផ្នែកមួយដ៏សំខាន់នៃប្រទេសកម្ពុជាអស់រយៈកាលជាង២០០០ឆ្នាំមកហើយ ។ វៀតណាមបានឈ្លានពានយកទឹកដីនេះនៅដើមសតវត្សរ៍ទី១៧ ។

ក្នុងឆ្នាំ១៦២៣ វៀតណាមបានទទួលការអនុញ្ញាតឲ្យមកធ្វើពាណិជ្ជកម្មនៅព្រៃនគរហៅថា«សៃហ្គន» ហើយវៀតណាមបានឆ្លៀតយកឱកាសដើម្បីបញ្ជូនប្រជាជនរបស់ខ្លួនមករស់នៅទីនោះ ។

វៀតណាមបានស្នើសុំការអនុញ្ញាតបន្តការរកស៊ីនៅព្រៃនគរ(សៃហ្គន)តែរយៈពេលប្រាំឆ្នាំប៉ុណ្ណោះ ។ ក្រោយមកប្រជាជនវៀតណាមបានបដិសេធមិនព្រមចាកចេញ ។ ក្នុងឆ្នាំ១៦៨៥ កម្ពុជាបានទាមទារឲ្យដាក់ឈ្មោះព្រៃនគរវិញតែវៀតណាមបានបដិសេធ ។ ឆ្នាំ១៦៨៣ កម្ពុជាបានទាមទារជាថ្មីម្តងទៀតឲ្យវៀតណាមប្រគល់ទឹកដីព្រៃនគរមកឲ្យខ្មែរវិញ ។ វៀតណាមបានសន្យាថានឹងប្រគល់ទឹកដីនេះឲ្យកម្ពុជាវិញ ក៏ប៉ុន្តែគ្រាន់តែជាការសន្យាបោកប្រាស់តែប៉ុណ្ណោះ ពីព្រោះធាតុពិតវៀតណាមបានបន្តបញ្ជូនប្រជាជនរបស់ខ្លួនរាប់ពាន់នាក់មកតាំងលំនៅស្ថាននៅទឹកដីព្រៃនគរជាហូរហែ ។ វៀតណាមបានបន្តការវាតទីនិងពង្រីកទឹកដីរបស់ខ្លួនដោយប្រើប្រាស់ទឹកដីព្រៃនគរជាឈ្នាន់របស់ខ្លួន ។

កាលបរិច្ឆេទដែលត្រូវបានលើកយកមកនិយាយខាងក្រោមនេះ ដែលបានមកពីមគ្គុទ្ទេសក៍ពីមុន បង្ហាញពីការជ្រៀតចូលក្នុងទឹកដីកម្ពុជា ប៉ុន្តែវៀតណាមពុំមានបំណងថាខ្លួននឹងយកជាកម្មសិទ្ធិនៃទឹកដីទាំងអស់នេះទៅតាមកាលបរិច្ឆេទនេះទេ ព្រោះប្រជាជាតិនិងប្រជាជនទាំងមូលបានវាយប្រយុទ្ធប្រឆាំងនឹងការលុកលុយនឹងការឈ្លានពានរបស់ប្រទេសវៀតណាម ។

ក្នុងឆ្នាំ១៦៩៩ វៀតណាមបានកាន់កាប់ខេត្តបារិយ៉ា វៀតណាមហៅថា«ភឿកឡេ» កំពង់ស្រកាត្រីវៀតណាមហៅ«បៀនហោ» និងព្រៃនគរ វៀតណាមហៅ «សៃហ្គន» ។ ក្នុងឆ្នាំ១៧១៥ ដោយពុំមានការដឹងឮពីអាជ្ញាធរខ្មែរ វៀតណាមបានតាំងទីលំនៅរបស់ខ្លួនគ្រប់គ្រងលើខេត្តមួយចំនួននៅពាមបន្ទាយមាស វៀតណាមហៅ«ហាទៀង» និងក្រមួនស(រាជយ៉ា)ក្នុងឆ្នាំ១៧៣២ វៀតណាមបានកាន់កាប់ខេត្តពាមមេស ហៅ«មីថូ» និង ឡុងហោ ហៅ«វិញឡុង» ។ ក្នុងឆ្នាំ១៧៥៧ វៀតណាមព្យាយាមបោះព្រំដែននៅមាត់ជ្រូក (ចូវដុក) ។

ឆ្នាំ១៧៥៨ វៀតណាមបានយកខេត្តព្រះត្រពាំង(ត្រាវិញ) និងខេត្តឃ្លាំងហៅ«សុកត្រាង» ធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ ប្រជាជនកម្ពុជាបានតស៊ូដោយឥតឈប់ឈរប្រឆាំងនឹងការជ្រៀតជ្រែករបស់វៀតណាម ដើម្បីស្រោចស្រង់ទឹកដីដែលជារបស់ប្រជាជនកម្ពុជាមកវិញ ។ ឯកសារនេះសូមដកស្រង់នូវព្រឹត្តិការណ៍សំខាន់ដូចខាងក្រោម÷

នៅក្នុងឆ្នាំ១៧៣១ ប្រជាជនកម្ពុជានៃខេត្តបាភ្នំ (កម្ពុជាភាគខាងកើត) បានក្រោកឡើងវាយបណ្តេញប្រជាជនវៀតណាម ។

ក្នុងឆ្នាំ១៧៣៨ កងទ័ពកម្ពុជាបានបណ្តេញប្រជាជនវៀតណាមទាំងអស់ចេញពីខេត្តពាមបន្ទាយមាស (ហាទៀង) ។

ក្នុងឆ្នាំ១៧៨៣ ប្រជាជននៃខេត្តឃ្លាំង(សុកត្រាង)បានក្រោកធ្វើបដិវត្តន៍ ហើយបានបណ្តេញវៀតណាមចេញពីខេត្តនេះ ។

ក្នុងឆ្នាំ១៧៨៨ ប្រជាជននៃខេត្តឃ្លាំងបានទប់ស្កាត់ប្រជាជនវៀតណាមកុំឲ្យវិលត្រឡប់មកវិញ ទ័ពកម្ពុជាបានវាយកម្ទេចទ័ពវៀតណាមនៅតំបន់សាបអន្លង់ខេត្តពោធិសាត់ ។

នៅក្នុងឆ្នាំ១៧៧៦ ប្រជាជនក្នុងខេត្តពាមមេស (មីថូ) និងឡុងហោ (វិញឡុង) បានក្រោកបះបោរឡើងប្រឆាំងនឹងវៀតណាម ហើយទ័ពកម្ពុជាបានវាយរំដោះបានខេត្តទាំងពីរនេះ ។

នៅក្នុងចន្លោះឆ្នាំ១៨៣៥និងឆ្នាំ១៨៣៧ ប្រជាជនក្នុងខេត្ត

ព្រះត្រពាំង(ត្រាវិញ) បានងើបឡើងប្រឆាំងនឹងប្រជាជនវៀតណាម ។

ក្នុងឆ្នាំ១៨៤៥ ប្រជាជនកម្ពុជាទាំងមូលបានងើបឡើងវាយកម្ទេចប្រជាជនវៀតណាម ។

នៅក្នុងឆ្នាំ១៨៥៨ ប្រជាជនកម្ពុជានៃខេត្តមាត់ជ្រូក ហៅ «ចូវដុក» បានរំដោះទឹកដីរបស់ខ្លួន ហើយបានភ្ជាប់ទឹកដីខេត្តមាត់ជ្រូកទៅនឹងទឹកដីកម្ពុជាឡើងវិញ ។ កងទ័ពកម្ពុជាបានវាយបណ្តេញប្រជាជនវៀតណាមចេញពីខេត្តឃ្លាំង ហៅ



«សុកត្រាង» ព្រះត្រពាំងហៅ«ត្រាវិញ» និងក្រមួនស ហៅ «រាជយ៉ា» ។

នៅក្រោមការគ្រប់គ្រងរបស់អាណានិគមនិយមបារាំង ចន្លោះឆ្នាំ១៨៦៣-១៩៥៤ប្រជាជនវៀតណាមបានយកទឹកដីរបស់កម្ពុជាត្រង់តំបន់ដទៃទៀតមកធ្វើជាកម្មសិទ្ធិ ។ ប្រជាជនវៀតណាមសមគំនិតចូលដៃជាមួយពួកអាណានិគមបារាំងបានកាន់កាប់តំបន់ព្រៃនគរ(សៃហ្គន) ក្នុងឆ្នាំ១៨៥៩ ។ នៅក្នុងអំឡុងរបបអាណានិគមកម្ពុជាបានបាត់បង់ទឹកដីរបស់ខ្លួនដូចខាងក្រោមនេះ÷

ចន្លោះឆ្នាំ១៨៧០ ដល់ឆ្នាំ១៩៧៣ៈ ខេត្តរោងដំរី (តាយនិញ) ជាតំបន់ដែលមានទីតាំងនៅតាមបណ្តោយទន្លេវៃកូទាំងពីរ ទឹកដីនៃខេត្តពាមបន្ទាយមាស (ហាទៀង) មាត់ជ្រូក (ចូវដុក) និងប្រាសាទដាប់(ដុងថាប់) ។ ចន្លោះឆ្នាំ១៨៩០ ដល់ឆ្នាំ១៩១៤ៈ ខេត្តដើងព្រះ ហៅ «សុងប៊ែ» ។

ឆ្នាំ១៩២៩ ពួកអាណានិគមនិយមបារាំងយកតំបន់ដាឡាក់ (វៀតណាមហៅ«ដាឡាក់»ដែរ) ដាក់ក្រោមអាណានិគមរបស់ខ្លួន ហើយបានប្រគល់ទឹកដីនេះទៅឲ្យប្រជាជនវៀតណាម ។

ក្នុងឆ្នាំ១៩៣៩ ពួកអាណានិគមនិយមបារាំងភ្ជាប់កោះតាង (ភូក្វក) កោះបុស្សី (ហុងដុក) និងកោះតូចៗមួយចំនួនទៀតទៅនឹងទឹកដីកូសាំងស៊ីន នៅក្រោមការត្រួតត្រារបស់ខ្លួន ហើយជាបន្តបន្ទាប់ធ្លាក់ក្រោមការត្រួតត្រារបស់វៀតណាម ។ របូតមកទល់នឹងសង្គ្រាមលោកលើកទី២ វៀតណាមបានច្បាមយកទឹកដី៥០០០គីឡូម៉ែត្រក្រឡានៃទឹកដីកម្ពុជាក្រោម ហើយបានស្រូបយកប្រជាជានកម្ពុជាជាងមួយលាននាក់ ប្រជាជនកម្ពុជាក្រោមបច្ចុប្បន្ននេះត្រូវបានហៅថា«ខ្មែរក្រោម» គឺមានចំនួនជិត៤លាននាក់ ។ **(នៅមានត)**

# ជនដៃដល់ ឬជនរងគ្រោះ?
## កសិណរបស់យុទ្ធជនវ័យក្មេងនៃមន្ទីរ ស-២១

តាមរយៈឯកសារសន្តិសុខ នៃរបបខ្មែរក្រហមបានបញ្ជាក់ឲ្យដឹងថា កម្លាំងយុទ្ធជនធ្វើការនៅមន្ទីរស-២១(ប្កុកទួលស្លែង) សរុបទាំងអស់មានចំនួន១៦៨៥នាក់ ដែលចែកជាក្រុមយុទ្ធជនការពារ សួរចម្លើយ ចាប់អ្នកទោស និងភ័ស្តុភារ ។ ឯកសារប្រវត្តិរូបនៃយុទ្ធជនមន្ទីរ ស-២១ ចំនួន៧៦២ប្រវត្តិរូបតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងនោះមានយុទ្ធជនដែលជម្រើសចេញមកពីតំបន់៣១(ខេត្តកំពង់ឆ្នាំង) ចំនួន១៦៩នាក់ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅខេត្តកំពង់ឆ្នាំង ហើយជួបសម្ភាសផ្ទាល់ជាមួយអតីតយុទ្ធជនមន្ទីរ ស-២១ ទាំងនោះបានចំនួន១៨នាក់ហើយនិងឪពុកម្តាយសាច់ញាតិរបស់អតីតយុទ្ធជន ស-២១ ចំនួន១៩នាក់ដែលបាត់ខ្លួន ។ យុទ្ធជនខាងលើគឺជាអតីតកុមារដែលត្រូវឃ្លាតឆ្ងាយពីទឹកដីភ្នំនាងកង្រីនិងល្បែងកម្សាន្តនានាជាមួយក្មេងៗ ម្រាក់លើវាលស្រែ វត្តអារាម សាលារៀន ឪពុកម្តាយ និងផ្ទះសម្បែង ដើម្បីចូលបម្រើបដិវត្តន៍ខ្មែរក្រហម







**អតីតកាលនិងបច្ចុប្បន្ន** **អតីតកាលនិងបច្ចុប្បន្ន**







នៅថ្នាក់មជ្ឈិម ។ តើដំណើរនៃការក្លាយខ្លួនពីកុមារតំបន់៣១ទៅជាយុទ្ធជនមន្ទីរ ស-២១ មានលក្ខណៈបែបណា? ។

ទ្រឹស្តីប៉ុលពត មួយឃ្លាបានចែងថា «កសាងសង្គមថ្មីត្រូវការមនុស្សថ្មី» ។ តាមរយៈទ្រឹស្តីនេះ កងឈ្លបភូមិស្រុករបស់ខ្មែរក្រហមមានអាយុត្រឹម១២ឬ១៣ឆ្នាំតែប៉ុណ្ណោះ ។ ក្រោយពីត្រូវបានគណៈស្រុកបំពាក់បំប៉នគោលជំហរសតិអារម្មណ៍ និងពិនិត្យប្រវត្តិរូបយ៉ាងហ្មត់ចត់រួចមក កងឈ្លបកុមារត្រូវចាត់តាំងឲ្យទៅបំពេញភារកិច្ចនៅមជ្ឈិមបក្សដែលមាននាទីជាយុទ្ធជនមន្ទីរ ស-២១ ។

ទាំងការចូលឈ្លប ទាំងការចេញដំណើរទៅធ្វើការនៅមជ្ឈិម កុមារខ្លះសប្បាយរីករាយ ប៉ុន្តែកុមារខ្លះទៀតព្រួយបារម្ភ ។ «ម៉ូត» អតីតកម្មាភិបាលខ្មែរក្រហមម្នាក់បានឲ្យដឹងថា ក្មេងៗខ្លះមានចិត្តចង់ចូលជានិរសាឈ្លបភូមិស្រុកដែរ ដោយក្មេងៗទាំងនោះចង់ធ្វើការងារស្រួលនិងហូបចុកគ្រប់គ្រាន់ ហើយបាននៅក្នុងភូមិថែមទៀត ។ គង់ អតីតឈ្លបឃុំស្វាយ ស្រុកសាមគ្គីមានជ័យបានរៀបរាប់ឲ្យដឹងថា កាលនោះគាត់ចង់ចូលឈ្លបព្រោះគាត់បានហូបគ្រប់គ្រាន់និងមិនចង់ធ្វើការធ្ងន់ ។ ចំណែក ធីម មិនចង់ធ្វើជាឈ្លប

នឹងគេទេ ព្រោះគាត់ចង់នៅផ្ទះជួយថែទាំម្តាយចាស់ជរារបស់គាត់ ។ អ៊ំស្រី យ៉ាន់ ម្តាយរបស់ ធឹម បានសុំអនុរគណៈស្រុកកំពង់ត្រឡាច ឈ្មោះ តារិន កុំឲ្យ ធឹម ចូលឈ្លប ព្រោះគាត់មាន ធឹម តែម្នាក់គត់គ្រាន់ជួយថែទាំ ។ នៅឆ្នាំ១៩៧៥ កងឈ្លបភូមិស្រុកត្រូវគណៈស្រុកចាត់តាំងឲ្យទៅមជ្ឈិម ។ សឿ ត្រូវគណៈស្រុកឈ្មោះ រិន ចាត់តាំងឲ្យឡើងឡានចេញពីភូមិដើម្បីទៅបំពេញភារកិច្ចនៅមជ្ឈិម ។ កាលនោះ សឿ មានការអល់អែក តែក្រោយមកដោយឮថាមានក្មេងប្រាក់គាត់ឈ្មោះ ពៅ មឿន ហុង ដែលរស់នៅក្នុងភូមិជាមួយគ្នាស្ម័គ្រចិត្តទៅមជ្ឈិម ដូច្នេះគាត់ក៏សម្រេចចិត្តទៅនឹងគេដែរ ។ សឿ រំឭកថា ពេលនៅក្នុងឡានតាមផ្លូវ ក្រុមគាត់នាំគ្នាច្រៀងលេងយ៉ាងសប្បាយ ប៉ុន្តែក្រោយពេលមកដល់មន្ទីរ ស-២១ ម្នាក់ៗយំលែងចេញ ហើយគិតថាគ្មានជីវិតរស់ត្រឡប់ទៅភូមិវិញទេ ។

ក្រោយពេលមកដល់មជ្ឈិម និងមុនពេលចូលបំពេញភារកិច្ចជាយុទ្ធជនមន្ទីរស-២១ កងឈ្លបភូមិស្រុកទាំងអស់ត្រូវបានចាត់តាំងឲ្យចូលរួមហាត់ហ្វឹកហ្វឺនបច្ចេកទេសយោធាបង្ហាត់បង្រៀនដោយគ្រូមកពីប្រទេសចិននៅតាខ្មៅក្បែរស្ទឹងព្រែកត្នោតក្នុងរយៈពេល



សមមិត្ត ខៀវ ចេស ហៅ ពៅ
យុទ្ធជនមន្ទីរស-២១



ខៀវ ចេស ហៅ ពៅ
បច្ចុប្បន្នជាកសិករ

៤ខែ អំពីវិធីសាស្ត្របាញ់កាំភ្លើង បោកគ្រាប់បែក និងក្បាច់ប្រយុទ្ធជាដើម ។ ចប់ការហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រយោធាកងឈ្លបទាំងអស់ត្រូវបានចាត់តាំងជាយុទ្ធជនចាប់អ្នកទោស យុទ្ធជនការពារ យុទ្ធជនសួរចម្លើយ និងយុទ្ធជនភ័ស្តុភារ នៃមន្ទីរ ស-២១ ក្រោមការគ្រប់គ្រងរបស់សមមិត្ត ឌុច ប្រធានមន្ទីរ ស-២១ ។ យោងតាមឯកសារមន្ទីរស-២១និងឯកសាររបស់ ឌុច បានបញ្ជាក់ឲ្យដឹងអំពីការងាររបស់ក្រុមយុទ្ធជនចាប់អ្នកទោសថា សមមិត្ត ហ៊ី អនុប្រធានមន្ទីរ ស-២១ មានភារកិច្ចដឹកនាំយុទ្ធជនចាប់អ្នកទោសចុះទៅគ្រប់ខេត្តតាមបញ្ជារបស់សមមិត្ត នួន ជា លេខារងទីមួយនៃបក្សកុម្មុយនិស្តកម្ពុជា និងរូបគាត់ (ឌុច) ដែរ ។ ពៅ អតីតយុទ្ធជនចាប់អ្នកទោសនៃមន្ទីរស-២១ រៀបរាប់ថា ពេលខ្លះយុទ្ធជនក្រុមគាត់ចុះតាមខេត្តដោយរថយន្តហ្ស៊ីបឬកាម៉្មង់កា ដើម្បីទៅចាប់អ្នកទោស ។ ពៅ បន្ថែមថាក្រុមចាប់អ្នកទោសមានក្បាច់គុនល្អដោយសារមានគ្រូចិនជាអ្នកបង្ហាត់ផ្ទាល់ ហើយពេលខ្លះគ្រូចិនទាំងនោះក៏ចូលរួមចាប់អ្នកទោសដែរ ដូចជាការចាប់ទាហានបូព៌ាក្នុងឆ្នាំ១៩៧៨ ជាដើម ។ ពៅ នៅចាំឈ្មោះគ្រូបង្វឹកជនជាតិចិនរបស់គាត់ដែលធំជាងគេគឺ ហូ វ៉ាន់ ហឺង ។

យុទ្ធជនការពារមានភារកិច្ចយាមអ្នកទោស យាមការពារបរិវេណជុំវិញគុកដើម្បីរក្សាសុវត្ថិភាពនិងមើលថែទាំអ្នកទោសកុំឲ្យមានបញ្ហាកើតឡើង ។ យុទ្ធជនការពារបំពេញភារកិច្ចយាមកាមចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង១១យប់ ឬចាប់ពីម៉ោង១១យប់រហូតដល់ភ្លឺ ។ យុទ្ធជនការពារធ្វើការដោយប្រុងប្រយ័ត្ន ។ នៅពេលមានបញ្ហាអ្វីមួយកើតឡើងឧទាហរណ៍ដូចជាមានអ្នកទោសរត់ចេញពីគុក គឺអ្នកយាមត្រូវចុចកណ្តឹងជាសញ្ញានិងបើកចរន្តអគ្គិសនីឆក់តាមរបងភ្លាម ។ ម្យ៉ាងទៀតយុទ្ធជនការពារក៏មានភារកិច្ចទាក់ទងជាមួយយុទ្ធជនសួរចម្លើយដែរ ។ ខេង អតីតយុទ្ធជនការពារ រៀបរាប់ពីការងារខ្សែសង្វាក់របស់ក្រុមទាំងពីរ

នេះថា យុទ្ធជនសួរចម្លើយត្រូវបង្ហាញលិខិតដល់យុទ្ធជនការពារនូវលេខអ្នកទោសដែលចង់នាំទៅសួរចម្លើយ ឧទាហរណ៍អ្នកទោសលេខ៦ឬលេខ៧ ។ ក្រោយមកទើបយុទ្ធជនការពារនាំអ្នកទោសរូបនោះទៅឲ្យយុទ្ធជនសួរចម្លើយដោយរុំមុខបណ្តើរយកទៅតែម្តង ។ ពេលនាំអ្នកទោសដល់បន្ទប់សួរចម្លើយយុទ្ធជនសួរចម្លើយឲ្យអ្នកទោសអង្គុយចុះលើកៅអី រួចចាប់ផ្តើមសួរនិងកត់ត្រាចម្លើយសារភាពដើម្បីបញ្ជូនទៅគណៈមន្ទីរ ស-២១ ជាអ្នកសម្រេចលើករណីនីមួយៗ ។ ការធ្វើទារុណកម្មអ្នកទោសត្រូវបានលើកទឹកចិត្តដោយគណៈមន្ទីរ ស-២១ ក្រោមមូលហេតុថា ដើម្បីវណ្ណៈ ជាតិ និងអន្តរជាតិ ។ សឿ រៀបរាប់ថា យុទ្ធជនសួរចម្លើយជាប្រភេទយុទ្ធជនដាច់ខាត បើអ្នកទោសឆ្លើយមិនត្រូវចិត្តច្បាស់ជាត្រូវដំបង ស្បែកជើង ឬខ្សែភ្លើងឆក់មិនខាន ។ «បើវាវៃមិនដល់វាឲ្យអ្នកទោសអង្គុយឬឱនចុះ រួចវាវៃភ្លូស! ជួនកាលវៃជ្រុលដៃរហូតដល់ស្លាប់ក៏មានដែរ» ។

យុទ្ធជនភស្តុភារមានភារកិច្ចចិញ្ចឹមចៀម ពពែ ទន្សាយ និងធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ដល់មន្ទីរស-២១ និងសាខាមន្ទីរ


សមមិត្ត ហ៊ឹម ខេង
យុទ្ធជនមន្ទីរស-២១


ហ៊ឹម ខេង
បច្ចុប្បន្នជាកសិករ

ស-២១ ទាំងអស់ ។ យុទ្ធជនចិញ្ចឹមសត្វមានភារកិច្ចរកស្មៅ ត្រកួន មកឲ្យសត្វទាំងនោះស៊ី និងមើលថែទាំសត្វកុំឲ្យស្លាប់ ។ ជាម អតីតយុទ្ធជនចិញ្ចឹមសត្វបានរៀបរាប់ថា ការងារគាត់ពេលនោះលំបាកណាស់ អត់មានពេលសម្រាកថ្ងៃសៅរ៍ឬថ្ងៃអាទិត្យទេ ។

ក្រៅពីភារកិច្ចស្នូល យុទ្ធជនមន្ទីរស-២១នៅមានភារកិច្ចចូលរួមប្រជុំប្រចាំសប្តាហ៍ ។ គោលបំណងនៃការប្រជុំនេះគឺដើម្បីបំពាក់បំប៉នមនោគមវិជ្ជាពង្រឹងគុណភាពការងារឲ្យស្រឡាញ់អង្គការ និងជួយជំរុញបក្សឲ្យជឿនលឿនលោតផ្លោះតាមទ្រឹស្តីលទ្ធិម៉ាក្ស-ឡេនីន ម៉ៅសេទុង ដ៏ល្អបរិសុទ្ធ ។ ការប្រជុំនេះជំរុញឲ្យយុទ្ធជនមន្ទីរ ស-២១ មានចិត្តគំនិតលះបង់ប្រយោជន៍បុគ្គលមនោសញ្ចេតនាឪពុកម្តាយ ហើយគិតតែប្រយោជន៍សមូហភាពរបស់អង្គការ ។ សឿ បានសុំសមមិត្ត ប៉េង ប្រធានកងការពារជាច្រើនលើកដើម្បីមកលេងឪពុកម្តាយ ផ្ទះសម្បែង ប៉ុន្តែត្រូវបាន ប៉េង បដិសេធជានិច្ច ។ សឿ បន្តថា ពេលនោះសមមិត្ត ប៉េង បានអប់រំយុទ្ធជនមន្ទីរស-២១កុំឲ្យនឹកបារម្ភពីឪពុកម្តាយនៅឯក្រោយ ព្រោះមានអង្គការទំនុកបម្រុងល្អហើយ ដូច្នេះយុទ្ធជនមន្ទីរ ស-២១ ជឿនិងសុខចិត្តប្រឹងធ្វើការបម្រើបដិវត្តន៍ខ្មែរក្រហម ។ សឿ រំឭកពាក្យសម្តីភូតកុហកទាំងនោះថា «ខំប្រឹងធ្វើការងារតាមផែនការរបស់បក្ស ខំហាត់រៀនលត់ដំខ្លួនទៅ ម៉ែឪខាងក្រោយកុំព្រួយ អង្គការឧបត្ថម្ភមួយថ្ងៃបីពេលហើយ» ។

ទីបំផុតដំណើរជីវិតផ្សងព្រេងរបស់កុមារតំបន់៣១ទាំងអស់មានត្រឹមតែ១៨នាក់ប៉ុណ្ណោះដែលមានវាសនាត្រឡប់ទៅឃើញភ្នំនាងកង្រី វាលស្រែ និងសាលារៀនម្តងទៀត ។ ប៉ុន្តែពេលវេលាបានកន្លងផុតទៅហើយ អតីតកុមារទាំងនោះគ្មានឱកាសទៅសាលាដើម្បីរៀន ឬទៅវាលស្រែដើម្បីរត់ដេញប្រឡែងលេងនឹងក្មេងប្រុសស្រីរបស់គាត់ទៀតទេ គឺពេលនេះគាត់ទាំងអស់ទៅវាលស្រែដើម្បីភ្ជួររាស់ច្រូតកាត់ចិញ្ចឹមគ្រួសារនិងប្រពន្ធកូន ហើយម្នាក់ៗរស់នៅក្នុងក្តីសោកស្តាយជាមួយនឹងអតីតកាលដែលពុំអាចបំភ្លេចបាន ។ **អៀ ម៉េងទ្រី**

# ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ

## គណៈកម្មការស្វែងរកការពិត

**(តពីលេខមុន)** ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនអាចនៅជាបញ្ហារ៉ាំរ៉ៃតទៅទៀតទេ ហើយតុលាការសម្រាប់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមជាមួយគណៈកម្មការស្វែងរកការពិតអាចកាត់បន្ថយបញ្ហានេះ និងបង្កើតឲ្យមានការចងចាំប្រវត្តិសាស្ត្ររួមគ្នាមួយដើម្បីធ្វើឲ្យប្រជាជនកម្ពុជាអាចបិទទំព័រសម័យកាលមួយដែលគ្រប់គ្រងដោយខ្មែរក្រហម ។

អ្នកដែលបានផ្តល់បទសម្ភាសន៍បានទទួចជារឿយៗអំពីក្តីប្រាថ្នាស្វែងរកមុខអ្នកដែលគាំទ្រខ្មែរក្រហមទាំងដោយផ្ទាល់និងដោយប្រយោល ។ ដោយភាពអាថ៌កំបាំងរបស់ខ្មែរក្រហមប្រជាជនកម្ពុជាភាគច្រើនពុំបានដឹងពីសមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍និងគណៈកម្មាធិការដទៃទៀតដែលរៀបចំបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ ។ របបនេះត្រូវបានយល់ថាមានលក្ខណៈជា“គុកឥតជញ្ជាំង” ដោយវាត្រូវបានរៀបចំឡើងដើម្បីដកហូតសិទ្ធិសេរីភាពនិងបុគ្គលភាពរបស់អ្នកទោស (ប្រជាជនកម្ពុជា) ។ អ្នកទោសពុំអាចធ្វើសកម្មភាពអ្វីមួយដោយពុំមានការអនុញ្ញាតពីអ្នកមើលការខុសត្រូវ (ពួកមេដឹកនាំខ្មែរក្រហម) ឡើយ ។ អ្នកទោសបានឃើញតែមុខអ្នកយាមប្រចាំនៅកន្លែងរបស់ខ្លួនប៉ុណ្ណោះ ។ អ្នកទោសពុំដែលបានស្គាល់អត្តសញ្ញាណអ្នកយាមនិងមន្ត្រីគុកផ្សេងទៀតឡើយ ។ មនុស្សភាគច្រើនស្គាល់តែឈ្មោះអ្នកមើលការខុសត្រូវ (ប៉ុល ពត) ប៉ុន្តែពុំដែលបានស្គាល់រូបរាងឡើយ ។ ជាសំណាងល្អសម្រាប់អ្នកស្រាវជ្រាវស៊ើបអង្កេតពីសម័យកាលនោះ ដែលក្នុងនោះក៏មានវត្តមានមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយខ្មែរក្រហមបានបន្សល់ទុកនូវក្រដាសស្នាមជាច្រើនដែលជាឯកសារនៃការកាប់សម្លាប់របស់ខ្លួនដែលបានកត់ត្រាទុកយ៉ាងទៀងទាត់និងសុក្រឹតបំផុត ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលពត៌មានចាំបាច់មួយចំនួនធំរួចមកហើយ ប៉ុន្តែនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ ទិន្នន័យដែលបានប្រមូលរួចមកហើយត្រូវតែវិភាគនិងវាយតម្លៃដោយស្ថាប័នជំនាញការនិងឯករាជ្យមួយ ។ ជាងនេះទៅទៀត ការចុះស្វែងរកអង្គហេតុនិងការស្រាវជ្រាវត្រូវការចាំបាច់ចំពោះការឧបត្ថម្ភជាប្រយោលនិងពិរុទ្ធភាពនៃជាតិផ្សេងៗ ។ ដូច្នេះមិនមែនត្រឹមតែអ្នកមើលការខុសត្រូវគុកទេដែលត្រូវស្វែងរក ប៉ុន្តែគឺរួមទាំងរដ្ឋាភិបាលដែលបានឧបត្ថម្ភគុក និងបណ្តាអង្គការដែលបញ្ជូនទីប្រឹក្សាមកជួយសម្រួលដំណើរការរបស់ការងារនេះទៀតផង ។ វាប្រហែលជាការចាំបាច់ក្នុងការពិនិត្យមើលអំពីពិរុទ្ធភាពនៃបណ្តាប្រទេសទាំងនោះដែលអាចទម្លាយគុកនោះហើយរំដោះអ្នកទោសចេញ ប៉ុន្តែខកខានពុំបានធ្វើ ។ ដើម្បីប្រមូលនូវអ្វីដែលប្រជាជនកម្ពុជាចង់ដឹងអំពីខ្មែរក្រហម គណៈកម្មការស្វែងរកការពិតដែលផ្តោតទៅលើការស្រាវជ្រាវនិងការស៊ើបអង្កេត ប្រហែលជាមានប្រសិទ្ធភាពជាងតុលាការ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍បានស្នើថា ប្រជាជនកម្ពុជា ជាពិសេសអ្នកនៅតាមទីជនបទស្រែចម្ការនិងអ្នកដែលមានឋានៈសេដ្ឋកិច្ចសង្គមទាបៗ បានផ្តល់អាទិភាពខ្ពស់ទៅលើសន្តិភាពនិងស្ថិរភាពជាងការទាមទាររកយុត្តិធម៌ពីខ្មែរក្រហម ។ ចំណែកឯប្រជាជនកម្ពុជាដែលមានឋានៈសេដ្ឋកិច្ចសង្គមខ្ពស់ៗវិញជឿថា ទស្សនវិជ្ជានៃពុទ្ធសាសនាចង់ឲ្យធ្វើការលើកលែងទោសនិងស្វែងរកការពិតជាជាងការសងសឹក ។ ប្រសិនបើហេតុផលដ៏មាំទាំមួយអាចលើកឡើងដើម្បីធ្វើការផ្តន្ទាទោសរបបប្រល័យពូជសាសន៍តាមគំរូនៃច្បាប់អន្តរជាតិ និងដែលផលប៉ះពាល់របស់វាធ្វើឲ្យមានភាពងាយនឹងប្រេះស្រាំនោះ រដ្ឋដ៏ក្មេងខ្ចីដូចជាកម្ពុជាប្រហែលជាពុំអាចទ្រាំទ្ររួចចំពោះផលដែលកើតចេញពីការកាត់ក្តីដ៏ទូលំទូលាយបានទេ ។ ប្រសិនបើចំនួននិងសមាសភាពនៃអ្នកដែលត្រូវនាំខ្លួនទៅកាត់ទោសត្រូវបានកំណត់ពីដំបូង ប្រជាជនកម្ពុជាផ្សេងទៀតដែលមានការពាក់ព័ន្ធជាមួយខ្មែរក្រហម អាចមានការភ័យបារម្ភតិចតួចអំពីការបង្កើតតុលាការ ។ ដូច្នេះ ទោះជារបួសចាស់នៅពុំទាន់ជាសះស្បើយក្តី ការភ័យបារម្ភអំពីការផ្តន្ទាទោសពី

សាធារណជនទូទៅអាចត្រូវបានស្រាកស្រាន្ត ។ ដាងនេះទៅទៀត គណៈកម្មការស្វែងរកការពិតអាចចង្អុលបង្ហាញឲ្យឃើញពិរុទ្ធជនគ្រប់ជាន់ថ្នាក់ដែលមានការពាក់ព័ន្ធទៅនឹងការបញ្ជាជាខ្សែសង្វាក់របស់ខ្មែរក្រហម ហើយបង្ហាញឲ្យឃើញពីទង្វើរបស់ពិរុទ្ធជនទាំងនោះ ទន្ទឹមនឹងការលើកលែងទោសនិងការធ្វើឲ្យសង្គមជាតិបានសះស្បើយ ។ ទាំងអ្នកដែលបានផ្តល់បទសម្ភាសន៍ទាំងផ្ទៃនៃប្រទេសដែលទើបរួចផុតពីសង្គ្រាមជាង២០ឆ្នាំនេះ បានបង្ហាញពីសេចក្តីត្រូវការចង់បានយន្តការនៃការទទួលខុសត្រូវមួយដើម្បីផ្តល់នូវសំណងដ៏សមរម្យចំពោះប្រជាជនកម្ពុជា ។ អាទិភាពចម្បងគឺមានការបង្កើតឲ្យមានប្រព័ន្ធអប់រំនិងប្រព័ន្ធច្បាប់ ។ គោលដៅទាំងពីរនេះពុំអាចសម្រេចបានទេបើពុំមានកិច្ចសហប្រតិបត្តិការពីរដ្ឋាភិបាល ហើយរដ្ឋាភិបាលតែឯកឯងក៏ពុំអាចសម្រេចកិច្ចការនេះដោយពុំមានជំនួយពីអន្តរជាតិទាំងខាងផ្នែកបច្ចេកទេសក៏ដូចជាខាងផ្នែកហិរញ្ញវត្ថុ ។ តុលាការអន្តរជាតិមួយដែលមានបំណងផ្តន្ទាទោសសមាជិកជាច្រើនរបស់ខ្មែរក្រហមគឺទាមទារការចំណាយច្រើនខ្លាំងណាស់ ហើយវាអាចធ្វើឲ្យហោចថវិកាសម្រាប់គោលដៅអភិវឌ្ឍសំខាន់ៗផ្សេងទៀត ។ នៅពេលដែលត្រូវបានបង្ហាញអំពីជម្រើសរវាងតុលាការនិងការអភិវឌ្ឍស្ថាប័នស៊ីវិលដែលចាំបាច់ដល់ស្ថិរភាពនៃលទ្ធិប្រជាធិបតេយ្យ ចម្លើយរបស់ប្រជាជនកម្ពុជាភាគច្រើនគឺការអភិវឌ្ឍ ។

### អនុសាសន៍

ចាប់ផ្តើមពីការសន្និដ្ឋានថា គណៈកម្មការស្វែងរកការពិតមានសារៈសំខាន់ជាអាយុជីវិតដល់ការធ្វើឲ្យសង្គមកម្ពុជាបានល្អប្រសើរឡើងវិញ វាជាការងាយស្រួលក្នុងការបង្ហាញពីយោបល់ផ្សេងៗអំពីវចនាសម្ព័ន្ធរបស់វា ។ បើតាមនិយមន័យ គណៈកម្មការស្វែងរកការពិតគឺជាយន្តការនៃការទទួលខុសត្រូវមួយដែលមានលក្ខណៈអាចបត់បែនយ៉ាងងាយ ហើយអាចត្រូវបានកែសម្រួលទៅតាមសេចក្តីត្រូវការរបស់ប្រទេសនីមួយៗ ។

ទី១ ឧក្រិដ្ឋកម្មនៅប្រទេសកម្ពុជាមានលក្ខណៈជាឧក្រិដ្ឋកម្មដែលមានការឃ្លាំមើលពីថ្នាក់លើយ៉ាងជិតដល់ដែលជាហេតុធ្វើឲ្យប្រជាជនកម្ពុជាសឹងតែពុំអាចបំពាននឹងបញ្ជារបស់កម្មាភិបាលខ្មែរក្រហម ។ មនុស្សភាគច្រើនបាននៅរស់ជីវិតរួចរស់ពីរបបខ្មែរក្រហមដោយសារខ្លួនគោរពតាមបញ្ជាខ្មែរក្រហម គឺរាប់តាំងពីការបែងចែកអាហារក្នុងចំណែកដ៏តិចតួចពុំគ្រប់គ្រាន់ រហូតដល់ការចាក់កញ្ចឹងកនឹងចំពុះទុង ។ វាជាការច្បាស់ណាស់ដែលថាមេដឹកនាំកំពូលមានទោសកំហុស ប៉ុន្តែបញ្ហាពិរុទ្ធភាពមានលក្ខណៈស្មុគស្មាញចំពោះជនផ្សេងទៀត ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជានឹងដោះស្រាយបញ្ហានេះហើយមានអនុសាសន៍មួយចង់ឲ្យធ្វើតាមរបៀបនៃការលើកលែងទោសដោយមានលក្ខខណ្ឌអនុវត្តដោយគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅអាហ្វ្រិកខាងត្បូង ។ សម្រាប់ករណីដោយឡែកនៃប្រទេសកម្ពុជា ការលើកលែងទោសអាចអនុញ្ញាតឲ្យប្រជាជនទាំងជនរងគ្រោះ ទាំងឧក្រិដ្ឋជន បានបង្ហាញឲ្យដឹងពីអ្វីដែលខ្លួនបានជួបប្រទះក្នុងពេលតែមួយជាមួយគ្នាតែម្តង ដោយផ្តល់នូវការលើកលែងទោសដល់ជនឧក្រិដ្ឋដែលបានសារភាពពីអំពើឃោរឃៅដែលខ្លួនបានប្រព្រឹត្ត ។ ដូច្នេះ វត្តមាននៃការដាក់ទោសដោយឲ្យទទួលទោសកំហុសជាសាធារណៈគឺជាការផ្តន្ទាចំពោះកំហុសទាំងនោះ ។ វាអាចជំរុញឲ្យប្រជាជនកម្ពុជានិយាយប្រាប់រឿងរ៉ាវរបស់ខ្លួន ទោះបីរឿងដែលខ្លួនបានសម្លាប់ជនរួមជាតិរបស់ខ្លួនក៏ដោយ ។ សម្រាប់ករណីប្រទេសកម្ពុជា ការលើកលែងទោសហាក់ដូចជាមាគ៌ាដ៏ច្បាស់លាស់តែមួយគត់ដើម្បីទទួលបានចម្លើយសាក្សីពីសំណាក់ប្រជាជនក្នុងចំនួនដ៏ច្រើនលើសលប់ ។

ភាគច្រើននៃអ្នកដែលបានផ្តល់បទសម្ភាសន៍បានបដិសេធការលើកលែងទោសមេដឹកនាំកំពូលៗ ប៉ុន្តែទស្សនៈអ្នកទាំងនោះចំពោះការលើកលែងទោសដល់ឧក្រិដ្ឋជនខ្មែរក្រហមដែលមានឋានៈតូចតាច គឺពុំមានលក្ខណៈច្បាស់លាស់ឡើយ ។ ប្រសិនបើតុលាការត្រូវបានបង្កើតឡើងសម្រាប់តែកាត់ទោសមេដឹកនាំកំពូលៗ ការលើកលែងទោសអាចត្រូវបានផ្តល់ឲ្យអ្នកដែលទទួលបញ្ជាជាខ្សែសង្វាក់ដែលមានឋានៈតូចតាចទាំងនោះក្រោយពេលដែលខ្លួនបានសារភាពនៅចំពោះមុខគណៈកម្មការស្វែងរកការពិត ។ តាមរយៈវិធីនេះ ការផ្តន្ទាទោសអាចធ្វើឡើងចំពោះពិរុទ្ធជនដែលបានប្រព្រឹត្តអំពើឃោរឃៅក្នុងរបបខ្មែរក្រហមតាមបែប

មួយដែលនឹងជួយបញ្ចប់ការចងពៀរនិងការសងសឹក ។ ខុសពីការលើកលែងទោសជាទូទៅដែលបណ្តោយឲ្យការរំលោភបំពានក្នុងអតីតកាលរួចខ្លួន ការលើកលែងទោសដោយមានលក្ខខណ្ឌអាចចូលរួមចំណែកក្នុងការកសាងសង្គមស៊ីវិលដោយការជំរុញឲ្យមានការជជែកពិភាក្សាគ្នា និងដោយការដាក់ទណ្ឌកម្មក្រៅផ្លូវច្បាប់ ។ ភាពអាម៉ាស់មុខចំពោះសង្គមដោយការសារភាពនិងសុំទោសជាសាធារណៈ គឺជាការផ្តន្ទាទោសមួយ ហើយការដឹងឮជាសាធារណៈពីអំពើឃោរឃៅអាចមានប្រយោជន៍ចំពោះដំណើរការជាសះស្បើយរបស់ជនរងគ្រោះ និងដំណើរទៅមុខនៃវិធានការច្បាប់ ដូចជាការវិនិច្ឆ័យទោសទៅតាមច្បាប់ដែរ ។

គណៈកម្មការស្វែងរកការពិតកម្ពុជាចាំបាច់ត្រូវស្ថិតនៅក្នុងប្រទេសកម្ពុជា ដើម្បីអាចស៊ើបអង្កេតនិងទទួលបានសក្ខីកម្មមួយដ៏ពេញលេញ ។ ទោះបីជាយ៉ាងនេះក្តី អ្នកដែលបានផ្តល់បទសម្ភាសន៍បានយល់ស្របគ្នាទាំងអស់ថា រដ្ឋាភិបាលកម្ពុជាពុំអាចរៀបចំឲ្យមានតុលាការឬគណៈកម្មការស្វែងរកការពិតមួយមិនលម្អៀងបានឡើយ ។ ដូច្នេះ គណៈកម្មការស្វែងរកការពិតគួរតែត្រូវបង្កើតឡើងដោយអង្គការសហប្រជាជាតិដោយមានការជួយឧបត្ថម្ភគាំទ្រពីសហគមន៍អាស៊ាន ។ អ្នកដែលបានផ្តល់បទសម្ភាសន៍ជាច្រើនបានបង្ហាញឲ្យឃើញពីបំណងចង់ឲ្យមានចៅក្រមពីប្រទេសប្រជាធិបតេយ្យនៃលោកខាងលិច ប៉ុន្តែអ្នកខ្លះយល់ថាការចូលរួមរបស់កម្ពុជាក៏មានសារៈសំខាន់ណាស់ដែរ ។ សម្រាប់សាក្សីសំខាន់ៗ ការជ្រើសយកការផ្តល់ចម្លើយជាអនាមិកគួរតែត្រូវបានអនុញ្ញាត ។ ស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន និងវត្តមាននៃអតីតសមាជិកខ្មែរក្រហមជាច្រើននៅក្នុងជួរថ្នាក់ដឹកនាំ ការភ័យខ្លាចការគុំកួនគឺជាការបារម្ភមួយដ៏ពិតប្រាកដ ។ នៅពេលដែលការបំផ្លាញសក្ខីកម្មកាន់តែមានច្រើនឡើង ការភ័យខ្លាចការគុំកួនក៏កាន់តែមានទំហំធំឡើងដែរ ។ ដូច្នេះ បើគណៈកម្មការស្វែងរកការពិតពុំមាន«ខ»ដែលចែងអំពីការផ្តល់ចម្លើយដោយអនាមិក វានឹងប្រឈមនឹងការបាត់សាក្សីដែលដឹងពត៌មានពាក់ព័ន្ធសំខាន់ៗ ។

អ្នកដែលបានផ្តល់បទសម្ភាសន៍គ្រប់រូបបានទទួលស្គាល់សារៈសំខាន់នៃការផ្សព្វផ្សាយលទ្ធផលឲ្យបានទូលំទូលាយ ប៉ុន្តែការអនុវត្តអាចជាបញ្ហានៅក្នុងប្រទេសកម្ពុជា ។ មានការលំបាកធំៗពីរដែលជាឧបសគ្គចំពោះការផ្សព្វផ្សាយនេះ សេរីភាពសារពត៌មាន និងការគិតគូរអំពីដំណើរការក្តីត្រឹមត្រូវមួយ ។ សម្រាប់ករណីប្រទេសកម្ពុជា ពាក់ព័ន្ធនឹងក្តីកង្វល់ពីកង្វះខាតសេរីភាពសារពត៌មាន អង្គការអន្តរជាតិដាច់ខាតត្រូវចូលរួមដើម្បីធានាការផ្សព្វផ្សាយមិនលម្អៀងល្អិតល្អន់ និងត្រឹមត្រូវពីការរកឃើញ ។ វាក៏មានសារៈសំខាន់



កម្មាភិបាលខ្មែរក្រហម

ខ្លាំងណាស់ដែរចំពោះការគិតគូរពីដំណើរការក្តីត្រឹមត្រូវមួយ ។ គណៈកម្មការស្វែងរកការពិតត្រូវតែយកចិត្តទុកដាក់ឲ្យបានខ្លាំងបំផុតចំពោះការកំណត់ឈ្មោះឧក្រិដ្ឋជន ។ ក្នុងខណៈដែលការផ្សព្វផ្សាយឈ្មោះឧក្រិដ្ឋជនត្រូវបានទទួលនូវការអបអរពីសំណាក់អ្នកដែលបានផ្តល់បទសម្ភាសន៍ការចោទប្រកាន់ពីពិរុទ្ធភាពត្រូវតែពិនិត្យឲ្យបានហ្មត់ចត់នៅពេលធ្វើការកំណត់ក្នុងវេទិកាពុំមែនតុលាការ ។ ប្រសិនបើគណៈកម្មការស្វែងរកការពិតប្រើវិធីលើកលែងទោសដោយមានលក្ខខណ្ឌ វានាំទៅដល់ការសារភាពដោយស្ម័គ្រចិត្តអំពីពិរុទ្ធភាព បញ្ចៀសបញ្ហាដំណើរការក្តីយ៉ាងពិតប្រាកដ ។

ចំពោះការផ្សព្វផ្សាយលទ្ធផលដោយមានការកំណត់ឈ្មោះជនរងគ្រោះទទួលបានការគាំទ្របន្តិចបន្តួចប៉ុណ្ណោះ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍បានជំទាស់ចំពោះការផ្សាយឈ្មោះជនរងគ្រោះដោយហេតុផលពីរ ចំនួនជនរងគ្រោះច្រើន ហើយប្រជាជនបានស្គាល់ឈ្មោះអ្នកដែលត្រូវបានសម្លាប់ទាំងនោះរួចហើយ ។ ជាងនេះទៅទៀត អ្វីដែលប្រជាជនកម្ពុជាបានជួបប្រទះខុសពីអ្វីដែលប្រទេសជាច្រើនទៀតបានជួបប្រទះ ពិសេសក្នុងទ្វីបអាមេរិកឡាទីនដែលមានបង្កើតឡើងនូវគណៈកម្មការស្វែងរកការពិតត្រូវបានបង្កើតឡើង ។ ទី១ ទំហំនៃការសម្លាប់រង្គាលនៃរបបប្រល័យពូជសាសន៍ដែលសម្លាប់ប្រជាជនកម្ពុជាសឹងតែ ១ភាគ៣នេះ ធ្វើឲ្យការស៊ើបអង្កេតលើគ្រប់ជនរងគ្រោះទាំងអស់ពុំអាចធ្វើទៅរួច ។ ទី២ ក្តីសង្ឃឹមថាមិត្តភក្តិឬសមាជិកគ្រួសារអាចនៅរស់រានមានជីវិតនៅកន្លែងណាមួយនោះបានរលត់រលាយបាត់ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ដូច្នេះប្រជាជនពុំចង់ឃើញឈ្មោះមនុស្សដែលខ្លួនស្រឡាញ់ ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ពីការស្លាប់បាត់បង់ជីវិតរបស់អ្នកទាំងនោះឡើយ ។ ទី៣ ចាប់ពីអំពើឃោរឃៅបានកើតឡើងមកដល់ពេលនេះ ប្រជាជនបានដិតជាប់ក្នុងអារម្មណ៍គ្រប់ពេលវេលានូវអ្វីដែលបានកើតឡើងចំពោះសមាជិកគ្រួសារនិងមិត្តភក្តិរបស់ខ្លួន ហើយខ្លួនគាត់ពុំមានសេចក្តីត្រូវការជាបន្ទាន់ចង់ឲ្យរឿងរ៉ាវរបស់គាត់ត្រូវបានដឹងឮនិងត្រូវបានរកយុត្តិធម៌ឲ្យនោះឡើយ ។ កាលៈទេសៈចុងក្រោយនេះក៏ជាលទ្ធផលនៃការដឹងឮអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមដែរ ។ វាជាការច្បាស់ណាស់ថាឧក្រិដ្ឋកម្មពុំត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញម្តងណាឡើយ ។ ដូច្នេះគណៈកម្មការស្វែងរកការពិតកម្ពុជាពុំត្រូវការផ្សព្វផ្សាយឈ្មោះរបស់ជនរងគ្រោះឡើយ ។

សំណួរបែបទស្សនវិជ្ជាដ៏លំបាកបំផុតត្រូវបានលើកឡើងក្នុងការពិភាក្សារវាងតុលាការនិងគណៈកម្មការស្វែងរកការពិត ។ មធ្យោបាយមានប្រតិកម្មដ៏ខ្លាំងត្រូវការឲ្យផ្តន្ទាទោសអ្នកដែលទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សដ៏គួរឲ្យរន្ធត់ ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ប៉ុល ពត របស់ ណេត ថេយ័រ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ បានបង្ហាញឲ្យឃើញពីប្រតិកម្មនេះ ។ ការអះអាងរបស់ ប៉ុល ពត ដែលថាខ្លួនពុំមានវិប្បដិសារីចំពោះតួនាទីរបស់ខ្លួនក្នុងការប្រល័យពូជសាសន៍ជំរុញឲ្យមានការចង់នាំខ្លួន ប៉ុល ពត មកផ្តន្ទាទោស ហើយតាមមធ្យោបាយនេះបង្ខំឲ្យ ប៉ុល ពត សោកស្តាយចំពោះអំពើឃោរឃៅរបស់ខ្លួន ។ ប៉ុន្តែតុលាការផ្តល់នូវផលជាច្រើនលើសពីការនាំខ្លួនបុគ្គលម្នាក់មកកាត់ទោសឆ្ងាយណាស់ ។ យើងត្រូវត្រឡប់ក្រោយពិនិត្យមើលមិនត្រឹមតែនូវអ្វីដែលពុំមានលក្ខណៈជាខ្មែរនៃដំណោះស្រាយបង្កើតឲ្យមានតុលាការប៉ុណ្ណោះទេ ប៉ុន្តែផ្តល់នូវផលប្រយោជន៍ផ្សេងៗនៃតុលាការចំពោះលទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីថែមទៀត ។ ទី១ ទស្សនៈព្រះពុទ្ធសាសនាហាក់ដូចជាគាំទ្រទស្សនៈដែលចង់ឲ្យមានការលើកលែងទោស ។ ទី២ តុលាការប្រហែលជាមធ្យោបាយដ៏ងាយស្រួលមួយសម្រាប់ប្រទេសផ្សេងៗលាងដៃរបស់ខ្លួនពីកំហុសដែលខ្លួនបានអនុញ្ញាតឲ្យរបបនេះលេចចេញជារូបរាងឡើង និងសម្រាប់ប្រទេសមួយចំនួនដែលធ្លាប់គាំទ្រខ្មែរក្រហមក្នុងរយៈពេលបន្ទាប់ពីអំពើប្រល័យពូជសាសន៍នេះត្រូវបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់ ។ ការរួមបញ្ចូលគ្នារវាងតុលាការនិងគណៈកម្មការស្វែងរកការពិតនឹងធ្វើឲ្យប្រាកដថា រូបភាពដ៏ពេញលេញនៃប្រវត្តិសាស្ត្រកម្ពុជាត្រូវបានបង្ហាញឲ្យឃើញរូបរាង ហើយបង្ការពុំឲ្យមានអស្ថិរភាពដែលអាចលេចចេញពីតុលាការដែលមានលក្ខណៈទូលំទូលាយ ។

ផ្នែកដ៏សំខាន់នៃរចនាសម្ព័ន្ធរបស់គណៈកម្មការស្វែងរកការពិតគឺការប្រមូលព័ត៌មាននិងការពិនិត្យខ្សែសង្វាក់នៃបទបញ្ជា ។

តាមរយៈបទសម្ភាសន៍ស្វែងរកឲ្យឃើញអ្នកនៅពីក្រោយខ្មែរក្រហម និយាយឲ្យស្រួលស្ដាប់ ការស្វែងរកការពិតគឺជាអាទិភាពដ៏ចម្បងបំផុតសម្រាប់ប្រជាជនកម្ពុជា ។ ដោយផ្អែកទៅលើអាណត្តិស្វែងរកហេតុការណ៍ដែលបានកើតឡើងរបស់វា គណៈកម្មការស្វែងរកការពិតមានលក្ខណៈគ្រប់គ្រាន់ជាងតុលាការក្នុងការស្រាវជ្រាវនេះ ។ ជាការពិតដែលថាសេចក្ដីសម្រេចរបស់តុលាការអាចត្រូវបានបោះពុម្ពផ្សាយ ប៉ុន្តែសាធារណជនមានការងាយស្រួលច្រើនជាងក្នុងការទទួលបាននូវការរកឃើញរបស់គណៈកម្មការស្វែងរកការពិត ។ សំខាន់ជាងនេះទៅទៀត ការស្វែងរករបស់គណៈកម្មការស្វែងរកការពិត អាចធ្វើឡើងចំពោះរបបខ្មែរក្រហមទាំងមូលតែម្ដង ព្រមទាំងបង្ហាញឲ្យឃើញនូវរូបភាពនៃការបញ្ជាជាខ្សែសង្វាក់និងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើងនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ។ ដូច្នេះ ដោយផ្អែកទៅលើទស្សនវិជ្ជានិងរចនាសម្ព័ន្ធ គណៈកម្មការស្វែងរកការពិតមានសារៈសំខាន់ខ្លាំងណាស់ចំពោះការផ្សះផ្សាសង្គមកម្ពុជា ។

តាមរយៈការផ្ដន្ទាទោសក្រោមផ្លូវច្បាប់ចំពោះឧក្រិដ្ឋជនដែលបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនិងមានឋានៈតូចតាច ហើយអាចសម្រេចបានគោលដៅធ្វើឲ្យមានយុត្តិធម៌ដោយពុំបង្កឲ្យមានការប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីបាន ។ បញ្ហានៅពេលនេះពុំមែនថាតើត្រូវអាណិត ប៉ុល ពត ជាងអ្នកដែល ប៉ុល ពត សម្លាប់ឬយ៉ាងណានោះទេ ប៉ុន្តែថាតើត្រូវប៉ាន់ស្មានឲ្យបានត្រឹមត្រូវពិតប្រាកដយ៉ាងដូចម្ដេចចំពោះអ្វីដែលចាំបាច់សម្រាប់ស្ដាបនាជាតិដែលបានឆ្លងកាត់សង្គ្រាម២០ឆ្នាំឡើងវិញ ។ អ្នកទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជា ប៉ុល ពត ត្រូវប្រឈមមុខនឹងតុលាការអន្តរជាតិ ។ គណៈកម្មការស្វែងរកការពិតគួរតែជួយជនកម្ពុជាផ្សេងទៀតក្នុងការបង្កើតឡើងនូវប្រវត្តិសាស្ត្ររួមរបស់សង្គម ។

## សេចក្ដីសន្និដ្ឋាន

ក្នុងកិច្ចសម្ភាសន៍មួយជាមួយប្រជាជនកម្ពុជា អ្នកនិពន្ធត្រូវបានជូនយោបល់សូមបង្កើតឲ្យមានតុលាការសម្រាប់មេដឹកនាំកំពូលៗ និងគណៈកម្មការស្វែងរកការពិតសម្រាប់សមាជិកខ្មែរក្រហមដែលមានឋានៈតូចតាច ។ ក្នុងខែមីនា ឆ្នាំ១៩៩៩ លោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងក្រុមជំនាញអង្គការសហប្រជាជាតិសម្រាប់បញ្ហាកម្ពុជា បានផ្ដល់ការយល់ព្រមចំពោះគំនិតដែលចង់បង្កើតឲ្យមានតុលាការសម្រាប់មន្ត្រីខ្មែរក្រហម និងគណៈកម្មការស្វែងរកការពិតសម្រាប់ជនកម្ពុជាផ្សេងទៀតនេះ ។ រដ្ឋាភិបាលកម្ពុជាបានប្រានចោលសំណើនេះដោយចង់ឲ្យមានតុលាការជាតិដែលមានការចូលរួមពីចៅក្រមអន្តរជាតិក្នុងចំនួនតិចតួចនិងជំនួយបច្ចេកទេសពីអង្គការសហប្រជាជាតិ ។ ផែនការនេះពុំមានបញ្ចូល «ខ» បង្កើតឲ្យមានគណៈកម្មការស្វែងរកការពិតទេ ។

យើងអាចយល់បានពីក្ដីកង្វល់របស់រដ្ឋាភិបាលកម្ពុជាអំពីអធិបតេយ្យភាព ។ ដោយផ្អែកលើអ្វីដែលប្រទេសកម្ពុជាបានទទួលពីសហគមន៍អន្តរជាតិក្នុងអំឡុងពេល២០ឆ្នាំមុននេះ ការជ្រើសយកតុលាការជាតិគឺជាការពុំបានគិតគូរវែងឆ្ងាយ ។ មានតែគណៈកម្មការស្វែងរកការពិតទេដែលអាចបំពេញនូវសេចក្ដីត្រូវការផ្នែកអប់រំនិងផ្សះផ្សាសង្គមជាតិរយៈពេលវែងបាន ។ ការដែលថាតុលាការកម្ពុជាពុំមានភាពមិនលម្អៀងនិងភាពឯករាជ្យដែលត្រូវការសម្រាប់កាត់ទោសខ្មែរក្រហមឲ្យបានត្រឹមត្រូវទទួលបានការយល់ស្របជាទូទៅ ។ ជាងនេះទៅទៀត គណៈកម្មការស្វែងរកការពិតមានលក្ខណៈសមស្របជាមួយប្រវត្តិសាស្ត្រនិងវប្បធម៌កម្ពុជាទៀតផង ។ គណៈកម្មការស្វែងរកការពិតមានភាពចាំបាច់សម្រាប់បង្កើតឲ្យមានរូបភាពនៃប្រវត្តិសាស្ត្រកម្ពុជាដ៏ទូលំទូលាយមួយដែលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការព្យាបាលសង្គមកម្ពុជាឲ្យបានសះស្បើយ ។ បន្ទាប់ពីសោកនាដកម្មបានកន្លងផុតទៅជាង២០ឆ្នាំ វាជាពេលវេលាដែលប្រជាជនកម្ពុជាត្រូវបានផ្ដល់ឲ្យនូវការទទួលស្គាល់ និងការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងដែលខ្លួនបានទទួលរងក្រោមដៃខ្មែរក្រហម ។ បញ្ហានេះអាចត្រូវបានបំពេញយ៉ាងមានប្រសិទ្ធភាពបំផុតតាមរយៈការបង្កើតឲ្យមានតុលាការសម្រាប់មេដឹកនាំកំពូលៗរបស់ខ្មែរក្រហម និងគណៈកម្មការស្វែងរកការពិតសម្រាប់កម្មាភិបាលដែលជាជនដៃដល់ផ្សេងទៀត ។

**ចាយ៉ា រ៉ាមជី**



# ស្នាដៃតាម៉ុក

## ខាលពិឃាតនៅធន្លេបាទីៈ គុកសង់

**(តពីលេខមុន)** នៅខែកញ្ញា ឆ្នាំ១៩៧៧ ឈិម សូម៉ាលី ត្រូវបានចាប់យកទៅជាមួយនឹងមនុស្ស៨៥នាក់ផ្សេងទៀត ។ «ពួកខ្មែរក្រហមបានយកខ្ញុំទៅគុកសង់ទន្លេបាទី ។ ពួកវាបាននាំខ្ញុំយកទៅសម្លាប់ចោល ។ ទាំង៨៥នាក់ស្លាប់អស់នៅសល់តែខ្ញុំម្នាក់...» ។ សូម៉ាលី បានរៀបរាប់អំពីស្ថានភាពនៅឯគុកសង់ថា «យើងធ្វើរាល់កិច្ចការទាំងអស់តាំងពីដកសំណាបស្ទូងស្រូវរហូតដល់ជីកដី រែកដី ។ ពេលដែលយើងរែកដីយើងត្រូវដាក់ច្រវាក់ជាប់ជើងទាំងពីរ... ។ ពួកវាតែងដាក់ច្រវាក់អ្នកឯងជានិច្ចមិនមែនទាល់តែពេលចូលគុកទើបដាក់ច្រវាក់នោះទេ... ។ ខ្នោះនោះធ្វើអំពីដែកមានទំហំប្រហែលប៉ុនបង្គោលចម្រឹងដែកបន្តួច ។ ពួកខ្មែរក្រហមពត់ដែកនោះឲ្យត្រឹមនឹងភ្នែកគោរ ។ រួចហើយធ្វើប្រហោងដើម្បីស៊កដែកវែងដែលដាក់បានមនុស្សប្រហែល១០នាក់ក្នុងមួយជួរ...។ ។ នៅក្នុង១បន្ទប់មាន១០ជួរ ក្នុងមួយជួរៗមាន១០នាក់ ។ ពួកខ្មែរក្រហមមិនដោះលែងអ្នកឯងទេ» ។ ស្ត្រីអ្នកភូមិម្នាក់ទៀតបានក្លាយជាអ្នកទោសនៅគុកសង់តាមរបៀបផ្សេងពីគេឯង ។ ឈឹម ស៊ុន ឆ្លល់ថាហេតុអ្វីបានជាប្តីគាត់មិនមកជួបគាត់រៀងរាល់១០ថ្ងៃម្តងតាមការអនុញ្ញាតរបស់ខ្មែរក្រហមយ៉ាងដូច្នេះ ។ ក្រោយមកមានមនុស្សម្នាក់បានប្រាប់គាត់ថា ប្តីរបស់គាត់ត្រូវបានចាប់យកទៅដាក់គុកសង់ហើយ ។ ដឹងភ្លាមគាត់ក៏ធ្វើដំណើរទៅរកប្តី ។ ពេលគាត់ទៅដល់គុកភ្លាម មានកម្មាភិបាលខ្មែរក្រហមក្មេងៗជាច្រើននាក់ហៅគាត់ឈប់ហើយស្រែកថា«សត្រូមមាចមិនស្គាល់ភ្លើង» ។ ឈឹម ស៊ុន មានការភ្ញាក់ផ្អើលជាខ្លាំងចំពោះអាកប្បកិរិយាប្រទ្បាងខាមរបៀបនេះហើយគិតថា «តើអាក្មេងតូចប៉ុណ្ណឹងវាហ៊ាននិយាយដូច្នេះចំពោះអញផង?» ។ ពេលនោះកម្មាភិបាលខ្មែរក្រហមក្មេងៗក៏ចាប់គាត់ដាក់គុកនៅទីនោះ ។ ស៊ុន ក៏ក្លាយជាអ្នកទោសរហូតមកដល់ខែមករា ឆ្នាំ១៩៧៩ ។ ពេលដែល ស៊ុន ជាប់គុកសង់ គាត់បានឃើញព្រឹត្តិការណ៍ផ្សេងៗជាច្រើន ។ «ម្តងៗមានប្រជាជន៧០ឬ៨០នាក់ត្រូវបាននាំចេញពីភូមិ ។ ប្រជាជនទាំងអស់នោះស្លាប់ទាំងអស់គ្មានអ្នកណារួចខ្លួនម្នាក់ឡើយ» ។ ពេលដែលបែករបបខ្មែរក្រហមភ្លាម អ្នកស្រុក

អ្នកភូមិក៏ក្រោកឈរឡើង ហើយចាប់កម្មាភិបាលខ្មែរក្រហមដែលនៅសេសសល់នៅតំបន់នោះ ។ អាជ្ញាធរថ្មីនិងប្រជាជនបាននាំខ្លួនអតីតឆ្មាំខ្មែរក្រហមនិងបុគ្គលិកធ្វើការនៅគុកសង់ជាច្រើនយកទៅវាលពិឃាតនៅជិតគុកសង់ បន្ទាប់មកបង្ខំឲ្យជីករណ្តៅសាកសពរួមនៅទីនោះ ។ ដូច្នេះអ្នកដែលនៅរស់បានទៅរកមើលភស្តុតាងដែលនៅសេសសល់របស់អ្នកដែលជាទីស្រលាញ់របស់ខ្លួនដែលបានបាត់បង់ជីវិតទៅ ។ ចៅអធិការវត្តក្រូចសើចព្រះនាម ពេញ សាម៉ន បានមានសង្ឃដីកាថាមានការជីករណ្តៅសាកសពរួមនៅទន្លេបាទីក្នុងឆ្នាំ១៩៧៩ ។ «មានតែរណ្តៅសាកសពចំនួនប្រហែលជា៣០ទៅ៦០តែប៉ុណ្ណោះត្រូវបានប្រជាជនគាស់កកាយ ។ អដ្ឋិធាតុនៃជនរងគ្រោះត្រូវបានដឹកយកមកដាក់នៅក្នុងអតីតអគារគុក» ។ (រូបភាពថតដោយ ដារីដ ហល នៅឆ្នាំ១៩៨០ នៃអដ្ឋិធាតុដែលរកឃើញនៅវាលពិឃាតគុកសង់ ត្រូវបានយកមកធ្វើជាក្របក្រៅនៃទស្សនាវដ្តីស្វែងរកការពិតលេខ៨) ។ រូបថតត្រូវបានដាក់តាំងឡើងវិញរំឭកអំពីការឈឺចាប់របស់ប្រជាជននៅក្នុងរបបខ្មែរក្រហម និងបង្ហាញពីមនុស្សគំរក់ដូចជា តាម៉ុក នេះ ។ ប៉ុន្តែជាច្រើនឆ្នាំក្រោយមកមានអ្នកស្រុកអ្នកភូមិខ្លះបានមករុះរើដំបូលគុកសង់យកទៅធ្វើជាផ្ទះសម្បែងរបស់ខ្លួន។ ២០ឆ្នាំក្រោយមកអដ្ឋិធាតុជនរងគ្រោះរាប់ពាន់នាក់នៅទីនោះបានចាប់ផ្តើមចុះទ្រុឌទ្រោមយ៉ាងខ្លាំង ។ ព្រះចៅអធិការវត្តក្រូចសើចសម្រេចចិត្តថាគេត្រូវតែជួយថែរក្សាការចងចាំចំពោះអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ។ ព្រះអង្គក៏ដឹកនាំការកសាងស្តូបមួយនៅក្បែរអគារគុកនោះដើម្បីតម្កល់អដ្ឋិធាតុ ។ «អាត្មាសង្កេតឃើញថា អដ្ឋិធាតុគ្មានការថែរក្សាឲ្យបានត្រឹមត្រូវឡើយ នៅហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់ ទៅជាពុកផុយ មិនតែប៉ុណ្ណោះថែមទាំងត្រូវសត្វគោស៊ីទៀតផង ។ ដូច្នេះវាបានជំរុញអាត្មាឲ្យគិតថា ប្រសិនបើអដ្ឋិធាតុនៅតែបន្តស្ថិតនៅក្នុងសភាពបែបនេះទៀតវានឹងបាត់បង់អស់ជាមិនខាន ហើយភស្តុតាងនឹងត្រូវរលុបអស់ក្មេងៗជំនាន់ក្រោយនឹងមិនបានឃើញទៀតឡើយ» ។

ដូច្នេះហើយបានជានៅចុងឆ្នាំ១៩៩៩ ព្រះសង្ឃបានរៃអង្គាសថវិកាពីសប្បុរសជននានាមកសង់បូជនីយដ្ឋានថ្មីមួយជាប់នឹងទីតាំងគុកសង់និងមានពិធីដ៏ធំមួយដង្ហែអដ្ឋិធាតុដែលជាស្នាដៃរបស់ តាម៉ុក ពីគុកសង់ទៅតម្កល់ក្នុងបូជនីយដ្ឋានថ្មីនោះ ។ ព្រះចៅអធិការវត្តមានដីកាថា រដ្ឋាភិបាលមានផែនការរុះរើសំណង់គុកចាស់ចោល ហើយសង់ជាសាលារដ្ឋបាលជំនួសវិញ ។ បើផែនការនេះត្រូវបានធ្វើមែននោះ ភស្តុតាងនៃគុកព្រមទាំងរណ្តៅសាកសពរួមដែលមិនទាន់បានជីកនៅឡើយនឹងបាត់អស់ជាមិនខាន ។ ពេលគឺអ្វីៗទាំងអស់នឹងបាត់បង់ លើកលែងតែការចងចាំតែប៉ុណ្ណោះ ។ នៅមានរឿងរ៉ាវមួយចំនួនដែលមិនអាចបំភ្លេចទោះជាប្រជាជនព្យាយាមបំភ្លេចយ៉ាងណាក៏ដោយ ។ អ្នករួចខ្លួននៅរស់រានមានជីវិតម្នាក់ឈ្មោះ ស៊ុន រឹម នៅមានអនុស្សាវរីយ៍ឈឺចាប់ទាំងនោះ ។ រឹម រំឭកថា ពេលដែលប្រជាជនជីករណ្តៅពិឃាតគុកសង់ក្រោយពីបែកសម័យខ្មែរក្រហមភ្លាម អ្នកស្រុកបានឃើញមានទារកតូចៗដែលត្រូវបានពួកខ្មែរក្រហមរុំខ្ចប់ប្រមុះនឹងថង់ប្លាស្ទិកហើយបោះចូលក្នុងរណ្តៅដាក់ពីលើឪពុកម្តាយដូចជាសំរាមអីចឹង ។ រឹម និយាយថា «ហេតុអ្វី បានជាពួកខ្មែរក្រហមចាំបាច់ចំណាយពេលឥតប្រយោជន៍វាយដំកូនក្មេងដែលមានអាយុ២-៣ខែធ្វើអី? គ្រាន់តែខ្ចប់នឹងថង់ហើយកប់ទៅវាស្រេចបាត់ទៅហើយ ។ ហេតុនេះហើយបានជាខ្ញុំនិយាយថា នេះហើយជាការឈឺចាប់របស់ប្រជាជនខ្មែរយើង...ហេតុនេះហើយបានជាខ្ញុំថាអ្នកដែលមិនដឹងនៅតែមិនដឹង ។ នេះជាការពិត ប៉ុន្តែយ៉ាងហោចណាស់ប្រជាជនខ្មែរត្រូវតែដឹងអំពីការពិតនៅគុកសង់និងស្នាដៃរបស់តាម៉ុក ។»

**ក្រេក អេចឆេសាន់**

## ពាក្យស្លោកខ្មែរក្រហម

◆**វិធានការជាននយោបាយ វិធានការជាសតិអារម្មណ៍ វិធានការជាចាត់តាំង វិធានការជាចំពោះមុខ វិធានការជាយូរអង្វែង។**

(ដកស្រង់ចេញពីឯកសារ កណហ០៧៩ ទំព័រ១៨)

◆**ស្ពួនគួនិងស្ពួនរួមខាទាក់ទងគ្នាដល់មូលធននិយមដល់សក្តមនិយម។**

(ដកស្រង់ពីឯកសារលេខកណហ០៧៩ ទំព័រ១១)

# ព្រលឹងវិលវល់



រណ្តៅសាកសពនៅទួលគោក

នាពាក់កណ្តាលអាធ្រាតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០០ ចៅអធិការវត្តកកោះព្រះនាម កែវ កុសល និងព្រះសង្ឃ១អង្គទៀត បានឃើញបាតុភូតគួរឲ្យរន្ធត់មួយដែលក្នុងនោះមានជនរងគ្រោះក្រោមរបបខ្មែរក្រហមរាប់រយនាក់ ដើរចេញពីផ្នូរសំដៅមករកវិហារធំដែលជាអតីតគុករបស់ខ្មែរក្រហម ។ ការជីករណ្តៅសាកសពរួមចំនួនរាប់រយនាពេលថ្មីៗនេះ ព្រះចៅអធិការវត្តកកោះមានជំនឿថា ព្រះតេជគុណបានបើកទ្វារផ្ទះឲ្យជនរងគ្រោះក្រោមរបបខ្មែរក្រហមដែលមានព្រលឹងនៅវិលវល់ ហើយសុំឲ្យព្រះតេជគុណធ្វើអ្វីមួយសម្រាប់ខ្លួន ។

ខ្មែរក្រហមបានប្រែក្លាយវត្តកកោះជាមន្ទីរសន្តិសុខ០៨ និងគុកក្នុងឆ្នាំ១៩៧៣ ហើយបន្តដំណើរការរហូតមកដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩ ។ គុកកកោះស្ថិតនៅក្នុងស្រុក៥៦តំបន់៣៣ ភូមិភាគនិរតី ឃុំកណ្តឹង ក្នុងស្រុកបាទី ខេត្តតាកែវ ។ មានប្រជាជនជាង៥ពាន់នាក់ត្រូវបានប៉ាន់ស្មានថាត្រូវសម្លាប់នៅគុកនេះ ។ ព្រះចៅអធិការវត្តកកោះ ដែលមានញោមប្រុស (ឪពុក) ស្លាប់នៅក្នុងគុកកកោះនេះ មានសង្ឃដីកាថា “អាត្មាបានឃើញខ្មោចរាប់រយនាក់ដើរស្រែកថ្ងូរដោយក្តីឈឺចាប់សំដៅមកព្រះវិហារ...ដូចជាដើរមករកសងសឹកអ៊ីចឹង...” ។ ពេលកំពុងមើលទៅឆ្អឹងដែលផុសចេញពីក្នុងរណ្តៅព្រះចៅអធិការបានមានសង្ឃដីកាពន្យល់ថា “ព្រលឹងនៃជនរងគ្រោះដែលស្លាប់ដោយជំងឺបានដល់សុគតិភពហើយ ប៉ុន្តែព្រលឹងអ្នកដែលត្រូវបានធ្វើទារុណកម្ម

និងកាប់ឲ្យស្លាប់ទាំងរស់ដោយមិនដឹងថាខ្លួនមានកំហុសនោះ នៅវិលវល់មិនស្ងប់ទេ ហើយក្លាយជាព្រលឹងក្រេវក្រោធវិលវល់ជុំវិញទីនេះ...» ។ ចំពោះយើងរាល់គ្នាវាហាក់ដូចជាអបិយជំនឿ ប៉ុន្តែសម្រាប់ជនរងគ្រោះម្នាក់ដែលរួចជីវិតពីគុកសង់ បានរស់នៅដោយក្តីវិលវល់ដូចដែលព្រះចៅអធិការវត្តកកោះមានសង្ឃដីកាអំពីព្រលឹងជនរងគ្រោះយ៉ាងដូច្នោះដែរ ។ ជនរងគ្រោះដែលរួចជីវិតម្នាក់នោះមានចម្លល់ថា ហេតុអ្វីបានជាគាត់ត្រូវបានធ្វើទារុណកម្មដោយអយុត្តិធម៌ ហើយជនរងគ្រោះដែលគួរឲ្យអាណិតនិងស្លូតត្រង់រាប់ពាន់នាក់ត្រូវកាប់យ៉ាងសាហាវទាល់តែស្លាប់ ។

លោកអ៊ឹ ចក់ អាយុ៦៨ឆ្នាំ ជាមនុស្សទី១ក្នុងចំណោមប្រជាជនមូលដ្ឋាន៦នាក់ដែលត្រូវបានចាប់ខ្លួននិងបញ្ជូនពីភូមិមកដាក់គុកកកោះ ។ អ៊ឹប្រុសមានប្រសាសន៍ថា «ខ្ញុំត្រូវបានប្រធានភូមិចោទប្រកាន់ថាជាប្រជាជនថ្មីបម្រើរបប លន់ ណុល» ។ ក្នុងអំឡុងពេលសួរចម្លើយអស់៧ថ្ងៃនៅគុកនោះ លោកអ៊ឹ ចក់ បានទទួលរងនូវការវាយធ្វើបាបយ៉ាងដំណំជាច្រើនដងក្នុងមួយថ្ងៃ។ «ក្រោយពីគេដឹងពីវណ្ណៈភាពរបស់ខ្ញុំ មេសន្តិសុខខ្មែរក្រហមឈ្មោះសមមិត្ត ពុតនិងអនុប្រធានឈ្មោះសមមិត្ត ស្រួយ មានការទុកចិត្តលើខ្ញុំ» ។ ដើម្បីរស់ លោកអ៊ឹ ចក់ បានធ្វើអ្វីៗគ្រប់បែបយ៉ាងតាមបញ្ជារបស់ខ្មែរក្រហមនៅក្នុងគុករហូតដល់ឆ្នាំ១៩៧៩ ។ បច្ចុប្បន្នលោកអ៊ឹ ចក់ រស់នៅជាជនពិការបណ្តាលមកពីការវាយដំប្រំធាក់របស់ខ្មែរក្រហម ។ អំពើដែលអាក្រក់ជាងគេដែលអ៊ឹប្រុស ចក់ បានឃើញនៅក្នុងគុកកកោះគឺការសម្លាប់មនុស្សជាច្រើនក្នុងឆ្នាំ១៩៧៨ ។

លោកអ៊ឹ ចក់ និយាយថា «ខ្ញុំបានឃើញសមមិត្ត ជឹម ប្រធានស្រុក៥៦ តំបន់៣៣ (ភូមិភាគនិរតី) ជិះម៉ូតូសេអិលពណ៌ក្រហមសំដៅទៅគុកគឺនៅថ្ងៃដែលខ្ញុំបានឃើញការសម្លាប់មនុស្សយ៉ាងច្រើននោះ ។ ទៅដល់គុកសមមិត្ត ជឹម បានសួររកបញ្ជីឈ្មោះអ្នកទោសនៅលើតុដែលស្ថិតនៅប្រហែល២០ម៉ែត្រពីរណ្តៅដែលនៅទីនោះមានសមមិត្ត ពុត និងអនុរបស់ ពុត អង្គុយ ។ ពេលនោះដោយគ្មានពិនិត្យអ្វីទាំងអស់ ជឹម ក៏គូសប៊ិកក្រហមលើឈ្មោះនៅក្នុងបញ្ជីដែលមានកម្រាស់ស្មើសៀវភៅពុម្ព ហើយចារសម្គាល់អក្សរ "X" នៅខាងចុងឈ្មោះនីមួយៗមួយសន្ទឹកម្តងៗក្រហមពេញក្រដាសទាំងអស់ ។ រួចហើយសមមិត្ត ជឹម ក៏ដើរចេញយ៉ាងលឿន ។ បន្ទាប់មកសមមិត្ត ពុត ក៏បញ្ជាឲ្យសន្តិសុខ១០នាក់ចាប់ផ្តើមនាំយកប្រជាជនម្តងប្រហែល៣០នាក់ៗចេញពីគុករួចហៅឈ្មោះជនរងគ្រោះម្តងម្នាក់មកចងមុខចងដៃទៅក្រោយបណ្តើរទៅមាត់រណ្តៅ ។ ទៅដល់រណ្តៅពួកខ្មែរក្រហមឲ្យជនរងគ្រោះលុតជង្គង់ចុះជុំវិញរណ្តៅ ឱនក្បាលរង់ចាំទទួលព្រនង់ ។ ខ្ញុំឃើញមនុស្សប្រកាច់មុនពេលដាច់ខ្យល់ស្លាប់ ។ ពួកខ្មែរក្រហមមិនសម្លាប់ត្រឹមតែម្តាយឪពុកទេសូម្បីតែកូនតូចក៏វាមិនទុកដែរ ។ ពេលខ្ញុំឃើញហេតុការណ៍នោះខ្លួនខ្ញុំញ័រអស់ហើយ ។ ពួកសន្តិសុខខ្មែរក្រហមសម្លាប់ហើយក៏ទាត់សាកសពទាំងអស់ទម្លាក់


ព្រះវិហារវត្តកកោះ អតីតមន្ទីរសន្តិសុខ១០៨

ចូលទៅក្នុងរណ្តៅ» ។

ចំពោះលោកអ៊ឹ ចក់ គឺច្បាស់លាស់ថា មេភូមិបានធ្វើបញ្ជីដែលអង្គការចាត់យល់ថាជាខ្មាំង ហើយចាត់បញ្ជូនទៅឲ្យសមមិត្ត ជឹម គណៈស្រុក ដែលបន្ទាប់មកបានគូសគំនូសក្រហម"X" មានន័យថា «យកទៅសម្លាប់» ឲ្យសមមិត្ត ពុត គណៈសន្តិសុខសម្លាប់មនុស្សអស់រាប់ពាន់នាក់ ។

ព្រះចៅអធិការ កែវ កុសល មានសង្ឃដីកាថា «អាត្មានឹងសូត្រមន្តស្រោចទឹកឲ្យព្រលឹងជនរងគ្រោះទាំងនោះបានស្ងប់...» ។ ប៉ុន្តែសង្ឃដីកានេះហាក់ដូចជាមិនអាចទទួលយកបានដោយលោកអ៊ឹ ចក់ និងប្រជាជនខ្មែរទូទៅឡើយ ។ លោកអ៊ឹ ចក់ និយាយថា "...ខ្ញុំចង់ដឹងថាតើអ្នកណាខ្លះនៅពីលើសមមិត្ត ជឹម ដែលនៅពីក្រោយការសម្លាប់នេះ» ។ តើ តាម៉ុក ដែលជាលេខាភូមិភាគនិរតីក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាឲ្យសមមិត្ត ជឹម សម្លាប់ប្រជាជនរាប់ពាន់នាក់នៅគុកវត្តកកោះឬមួយយ៉ាងណា? **ផាត កុសល**




**(តពីលេខមុន)** *ខ្ញុំត្រូវព្រួនង់ទីមួយដែលធ្វើឲ្យខ្ញុំផ្កាប់មុខទៅនឹងដីដែលមានសាកសពព័ទ្ធជុំជិតផ្នែកខាងក្រោមនៃរាងកាយរបស់ខ្ញុំ ។ ព្រួនង់នោះត្រូវចំស្ពាបប្រចៀវរបស់ខ្ញុំ ។ ពេលនោះខ្ញុំឮសំឡេងបាក់ឮស្ងូរតែផស់! ។ ខ្ញុំនៅចាំចំណុចនេះច្បាស់ណាស់ ។ ខ្ញុំមិនអាចស្រែកឲ្យបានឮដើម្បីបន្ថយការឈឺចាប់ឡើយ ។ ខ្ញុំព្យាយាមស្រែកឲ្យខ្លាំងដែរតែគ្មានប្រយោជន៍សោះ ។ ខ្ញុំនៅដឹងខ្លួននៅឡើយ ហើយរងនូវការឈឺចាប់ដែលមិនអាចទ្រាំទ្របាន ។ មួយព្រួនង់ទៀតបានចំលើកញ្ជឹងកខ្ញុំត្រង់ក្បាលផ្នែកខាងស្តាំ ។ ក្បាលខ្ញុំត្រូវពកប្រហែលជាងពីរសង់ទីម៉ែត្រ ។ ខ្ញុំជឿថាមួយព្រួនង់នេះហើយដែលធ្វើឲ្យខ្ញុំសន្លប់បាត់ស្មារតីនិងលង់លក់រហូតពេញមួយយប់ ។ ក្រៅពីនោះព្រួនង់យ៉ាងហោចណាស់ក៏ ១៥០ដែរ ដែលវាយសំពងមកលើខ្លួនប្រាណគ្របដណ្តប់ទៅដោយឆ្អឹងរបស់ខ្ញុំ ។ សំណាងល្អខ្ញុំមិនដឹងខ្លួនឡើយគឺដឹងតែប៉ុន្មានព្រួនង់ចុងក្រោយប៉ុណ្ណោះ ។ ក្រៅពីនេះខ្ញុំមិនបានដឹងអ្វីផ្សេងទៀតទេ លើកលែងតែខ្ញុំដឹងថាខ្ញុំបានដេកលក់ស្រួលណាស់ ។*

*ពេលខ្ញុំភ្ញាក់ឡើងក៏ឮស្ងូរមនុស្សដើរសំដៅមកវាលពិឃាត ។ ខ្ញុំក៏រំកិលខ្លួនបន្តិចម្តងៗហើយងើបអង្គុយលួចស្តាប់យ៉ាងកៀកនឹងសំឡេងនោះ ។ ខ្ញុំចាប់ផ្តើមភិតភ័យហើយនឹកក្នុងចិត្តថា «ពួកខ្មែរក្រហមប្រាកដជាមកបង្ហើយខ្ញុំម្នាក់ទៀតហើយ ។ ពួកវាច្បាស់ជាមកកប់ខ្ញុំទាំងរស់ហើយ» ។ នេះគ្រាន់តែជាការគិតរបស់ខ្ញុំ ប៉ុន្តែក៏អាចជាការពិតដែរ ។ ខ្ញុំមិនដឹងជារស់ដើម្បីអ្វីទៀតទេ ។ ស្ថិតក្នុងសភាពបែបនេះខ្ញុំហាក់ដូចជាដេកចាំតែស្លាប់ប៉ុណ្ណោះ ។*

*ពេលដែលមានសំឡេងកាន់តែខ្លាំងនិងកាន់តែជិតខ្ញុំ ខ្ញុំលែងមានក្តីសង្ឃឹមថានឹងមានជីវិតបន្តទៀតឡើយ ។ ខ្ញុំប្រឹងរំកិលខ្លួនយ៉ាងលឿនតម្រង់ទៅគម្ពោតព្រៃនៅខាងមុខ ។ ខ្ញុំស្ថិតនៅមិនលើសពី៦ម៉ែត្រឡើយពីកន្លែងដែលខ្ញុំចាប់ផ្តើមរំកិលខ្លួនមក ។ នៅកន្លែងថ្មីនោះខ្ញុំបានឃើញទិដ្ឋភាពដ៏ស្រស់ស្អាត ។ មិនយូរប៉ុន្មានក៏មានមនុស្សមកដល់ទីនោះ ។ ខ្ញុំមើលមិនខុសទេ ។ ទាហានខ្មែរក្រហមត្រឡប់មកវិញដោយនាំយកមកជាមួយនូវជនរងគ្រោះដទៃទៀត ។ ភាគច្រើននៃជនរងគ្រោះដែលទើបនឹងមកដល់នោះសុទ្ធតែជាបុរស មានស្ត្រីតែពីរឬបីនាក់ប៉ុណ្ណោះ ។ ប្រជាជនទាំងនោះត្រូវបានចងស្លាបសេក ប៉ុន្តែមិនមែនយកបន្ទះក្រណាត់ចងដូចពីមុនទេ គឺចងដោយខ្សែមែនទែន ។ ខ្ញុំនឹកក្នុងចិត្តថា អ្នកទាំងអស់នេះគ្មានផ្លូវនឹងអាចរើរួចពីចំណងនេះបានឡើយ» ។ ដោយញញឹមនិងនិយាយគ្នាបណ្តើរ ពួកខ្មែរក្រហមទាំងនោះបានបន្តវាយនិងប្រានជនរងគ្រោះទៅមុខដូចជាដេញគោមិនមែនមនុស្សទេ ។ បន្តិចក្រោយមក ទាហានម្នាក់ក្នុងចំណោមទាហានវ័យចំណាស់ជាច្រើននាក់ក៏ចេញបញ្ជាម្តងទៀត ។ នៅពេលព្រលឹមដែលមានពន្លឺជះភ្លឺច្បាស់គួរសម ខ្ញុំក៏បានឃើញការសម្លាប់មនុស្សម្តងទៀត ។ គ្រាន់តែប៉ុន្មានវិនាទីប៉ុណ្ណោះជនរងគ្រោះទាំងអស់ត្រូវបានសម្លាប់ដោយគ្មានមេត្តាដូចក្រុមគ្រួសារនិងមិត្តភក្តិរបស់ខ្ញុំដែរ ។ សាកសពរបស់ជនរងគ្រោះស្ថិតនៅរគាត់រគាយនៅក្នុងភក់ក្បែរនោះ ។ រំពេចនោះ*

បេះដូងខ្ញុំឈប់លោត ខ្លួនខ្ញុំទាំងមូលញ័រទប់លែងឈ្នះ ហើយចង់គេចចេញពីទីនោះឲ្យបានលឿនបំផុត ។ ដៃស្តាំខ្ញុំប្របាច់មាត់ជាប់ខ្លាចក្រែងខ្ញុំភ្លាត់សំឡេងឮដល់ពួកខ្មែរក្រហម ។ ពេលនោះខ្ញុំគិតថាខ្ញុំច្បាស់ជានឹងឆ្លងកាត់ការឈឺចាប់ដូចពេលមុនម្តងទៀតហើយ ។ ខ្ញុំមិនចង់ទទួលយកការពិតនេះម្តងទៀតឡើយ ។ ពេលនោះខ្ញុំលែងដឹងអ្វីហើយក៏សន្លប់នៅក្នុងព្រៃនោះតែម្តង ។ ខ្ញុំមិនដឹងខ្លួនរហូតដល់យប់បន្ទាប់ ។ មួយថ្ងៃបានកន្លងផុតទៅហាក់ដូចជាខ្ញុំមិននៅទីនោះអ៊ីចឹង ។ ខ្ញុំនៅចាំបានថាភ្ញាក់ដឹងខ្លួនជាច្រើនលើក ប៉ុន្តែអ្វីៗមើលទៅហាក់ដូចជាអ័ព្ទអ៊ីចឹង ។ មួយសន្ទុះក្រោយពី ខ្ញុំភ្ញាក់ដឹងខ្លួនមានមនុស្សជាច្រើនផ្សេងទៀតដើរសំដៅមករកខ្ញុំ ។ ខ្ញុំគិតថាប្រជាជនទាំងនោះគឺជាជនរងគ្រោះដែលត្រូវសម្លាប់ ។ ខ្ញុំមិននៅរង់ចាំដើម្បីឲ្យដឹងការពិតឡើយ ។ ពេលនោះខ្ញុំក៏សម្រេចចិត្តចង់រស់ដើម្បីសងសឹកឲ្យគ្រួសារមិត្តភក្តិញាតិសន្តានរបស់ខ្ញុំ ។ កំហឹងឈឺចាប់ជាកម្លាំងចិត្តដ៏ខ្លាំងបំផុតដែលខ្ញុំត្រូវការ ។ ខ្ញុំលែងខ្លាចទៀតហើយ ។ ដោយសារអារម្មណ៍ឈឺចាប់មាននៅក្នុងខ្លួនដែលធ្វើឲ្យខ្ញុំខិតខំបន្តដំណើរទៅមុខទៀត ។ ខ្ញុំក៏លាមនុស្សជាទីស្រលាញ់ ហើយចាប់ផ្តើមវារដោយកែងដៃនិងក្បាលជង្គង់ភៀសខ្លួនចេញពីកន្លែងនោះទៅ ។ ទោះជាខ្ញុំចង់ដើរក៏ខ្ញុំមិនអាចងើបដើរបានឡើយ ។ ខ្លួនប្រាណខ្ញុំលែងចេញឈាមទៀតហើយ ប៉ុន្តែខ្ញុំហាក់ដូចជាស្ថិតក្នុងរូបភាពអាក្រក់មែនទែន ។ ខ្ញុំខ្សត់ខ្សោយកម្លាំង ឃ្លាននិងស្រេកទឹកខ្លាំងណាស់ ។ មាត់ខ្ញុំប្រេះដូចជាភក់ត្រូវកម្តៅព្រះអាទិត្យអ៊ីចឹង ។ ភក់និងឈាមដែលត្រូវនឹងកម្តៅថ្ងៃស្ងួតរឹងនោះក៏ចាប់ផ្តើមប្រេះចេញពីខ្លួនខ្ញុំ ។ ខ្ញុំត្រូវតែរកទឹកផឹក បើមិនដូច្នេះទេខ្ញុំប្រាកដជាស្លាប់ដោយស្រេកទឹកមិនខាន ។ ខ្ញុំវារកាត់តាមប្រឡាយរាក់មួយដែលទើបតែស្ងួតតម្រង់ទៅទិសខាងជើង ។ ពេលនោះមេឃចាប់ផ្តើមងងឹតនិងត្រជាក់ទៀតហើយ ។ កែងដៃនិងក្បាលជង្គង់របស់ខ្ញុំដាច់ខ្ទេចខ្ទីនិងមានស្នាមជាំទាំងដុំៗ ប៉ុន្តែខ្ញុំខាំមាត់សង្កត់ចិត្តហើយបន្តដំណើរទៅមុខទៀត ។ ចេះតែវារៗទៅខ្ញុំក៏ដឹងខ្លួនថាមកដល់ព្រៃមួយកន្លែងតែព្រៃនោះមិនមានកន្លែងចូលឡើយ ។ ខ្ញុំវារទៅមុខទៅក្រោយដើម្បីរកច្រកចូលទៅក្នុងព្រៃដ៏ក្រាស់នោះ ។ ចុងបញ្ចប់ខ្ញុំក៏មកដល់កន្លែងដែលខ្ញុំចាប់ផ្តើមចេញដំណើរដែលនៅជិតវាលពិឃាតនោះដដែល ។ បន្ទាប់ពីព្យាយាមបួនប្រាំលើកមកខ្ញុំក៏មកដល់ពាក់កណ្តាលព្រៃដោយមិនដឹងខ្លួន ហើយក៏វង្វេងនៅក្នុងព្រៃនោះតែម្តង ។ ពេលពិបាកចិត្តខ្លាំងខ្ញុំក៏ស្រែកលូដូចជាឆ្កែចចកនៅក្នុងព្រៃដោយគ្មានបារម្ភខ្លាចពួកពេជ្ឈឃាតខ្មែរក្រហមឮឡើយ ។ ក្រោយមកទើបខ្ញុំដឹងថាការវង្វេងក្នុងព្រៃនិងការធ្វើដំណើរបកក្រោយវិញ គឺជាវិធីសាស្ត្រដ៏ល្អបំផុតធ្វើឲ្យទាហានខ្មែរក្រហមដែលតាមស្វែងរកជនរងគ្រោះដែលរត់គេចត្រូវវង្វេង ។

ខ្ញុំនៅចាំបានថាពួកខ្មែរក្រហមចំណាយពេលអស់ជិតមួយសប្តាហ៍ទើបរកឃើញ ចាប់បាន និងសម្លាប់មិត្តរបស់ខ្ញុំម្នាក់ឈ្មោះ ឡៃ ។ ខ្ញុំបានព្យាយាមមិនធ្វើឲ្យឧបទ្ទវហេតុដ៏អាក្រក់បែបនេះកើតឡើងជាថ្មីម្តងទៀតឡើយ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ខ្ញុំមិនមែនជាអ្នករស់រានមានជីវិតតែម្នាក់ដែលរត់រួចពីការកាប់សម្លាប់ឡើយ ។ នៅពេលយប់ខ្ញុំបានឮសម្រឹបជើងនៅក្នុងព្រៃជ្រៅប៉ុន្តែខ្ញុំមិនហ៊ានធ្វើឲ្យឮសំឡេងឡើយដោយខ្លាចក្រែងក្លាយជាចំណុចដៅរបស់ព្រានមនុស្ស ។ ខ្ញុំមានបំណងចង់រស់ទោះជាត្រូវធ្វើយ៉ាងម៉េចក៏ដោយ ។ ខ្ញុំត្រូវតែរស់ដើម្បីគ្រួសារនិងមិត្តភក្តិរបស់ខ្ញុំដែលបានស្លាប់ទៅហើយនោះ ។ ខ្ញុំដឹងខ្លួនថាខ្ញុំកាន់តែខ្សោយទៅៗ ហើយត្រូវតែខិតខំរកផ្លូវចេញពីព្រៃដ៏សែនក្រាស់និងប្រទាក់ក្រឡាស្មុគស្មាញនោះ បើមិនដូច្នេះទេខ្ញុំច្បាស់ជានឹងត្រូវស្លាប់មិនខាន ។ ខ្ញុំក៏បានសម្រាកមួយយប់នៅកន្លែងដែលខ្ញុំមកដល់ដំបូងនៅក្នុងព្រៃដោយបង្ខំចិត្តរបស់ខ្លួនឲ្យដេកលក់ ។ យប់នោះខ្ញុំដេកដូចជាគល់ឈើអ៊ីចឹងគ្មានយល់សប្តិអាក្រក់អ្វីឡើយ ។

**យិមសុត វ៉ាណាឌិត**

**ពាក្យស្លោកខ្មែរក្រហម**

**◆កាត់ផ្តាច់របបកម្មសិទ្ធិ កម្ចាត់ចោលពាណិជ្ជកម្មចាស់ ហើយបង្កើតពាណិជ្ជកម្មថ្មី។**

**◆អ្នកដែលមិនបញ្ចេញពលកម្មដេកស្រួល ត្រូវឱ្យបង្កបង្កើតផល។** *(ដកស្រង់ពីឯកសារលេខកណាហ១៧៩)*

# រឿងខ្ញុំក្នុងថ្ងៃជម្លៀស

ថ្ងៃ១៧ មេសា ១៩៧៥ គឺជាថ្ងៃដួលរលំនៃរបប លន់ ណុល ហើយក៏ជាថ្ងៃជ័យជម្នះរបស់ពួកខ្មែរក្រហមដែលបានខំប្រឹងតស៊ូវាយយកក្រុងភ្នំពេញពីរបប លន់ ណុល អស់រយៈកាលជាយូរមកហើយ ។

ថ្ងៃនោះប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសកំពុងរង់ចាំមើលជ័យជម្នះរបស់ពួកខ្មែរតស៊ូមួយក្រុមដែលហៅខ្លួនថា«ខ្មែររំដោះ» តាំងពីព្រឹកព្រលឹមមក នៅតាមថ្នល់និងតាមគេហដ្ឋាននីមួយៗមានសភាពស្ងាត់ជ្រងំ ជួនឮសូរតែសំឡេងបាញ់ផ្លោងគ្រាំងៗ សំឡេងកាំភ្លើងជួនជិតជួនឆ្ងាយ ឮសូររបេះរប៉ោះគ្រប់ទិសទី ។ សំឡេងឡានហេអ៊ឹមសេរបស់ចិនបើកចុះបើកឡើងព្រោងព្រាត ។ ឡាននីមួយៗពេញដោយទាហាន មើលទៅមិនដឹងទាហានខាងណាខ្លះទេ ព្រោះជួនឃើញពាក់អាវពណ៌ខ្មៅជួនឃើញស្លៀកពាក់ខោអាវពណ៌ត្រីអ៊ីឡូកឡំគ្នា ។ ទឹកមុខម្នាក់ៗមើលទៅហាក់ដូចជាមានការភ័យព្រួយចំពោះព្រឹត្តិការណ៍ស្រុកទេសមិនដឹងជាថ្ងៃស្អែកនឹងមានអ្វីកើតឡើងទៀតទេ ។

ថ្ងៃនោះខ្ញុំនៅផ្ទះបងជីដូនមួយខ្ញុំនៅផ្សារដេប៉ូ ព្រោះខ្ញុំត្រូវគេចចេញពីផ្ទះរបស់ខ្ញុំនៅម្តុំអាងចិញ្ចឹមក្រពើ ជិតផ្លូវទៅពោធិចិនតុង ដោយសារមានការបាញ់ផ្លោងយ៉ាងខ្លាំងនៅម្តុំផ្ទះរបស់ខ្ញុំអស់រយៈកាល២-៣ថ្ងៃមកហើយ ។ ឃើញព្រឹត្តិការណ៍ដូច្នេះ ខ្ញុំមានការព្រួយបារម្ភចំពោះផ្ទះនិងទ្រព្យសម្បត្តិបន្តិចបន្តួចរបស់ខ្ញុំ ។

ខ្ញុំនឹកចង់ត្រឡប់ទៅផ្ទះវិញដើម្បីយករបស់របរមកខ្លះៗជាប់នឹងខ្លួន ។ ថ្ងៃបន្តិចដោយឃើញថាស្ងាត់គ្មានឃើញឡានទាហានចុះឡើងច្រើន ខ្ញុំក៏សម្រេចចិត្តទៅផ្ទះខ្ញុំមួយភ្លែត ។

ខ្ញុំនិងប្តីខ្ញុំជិះកង់តាមផ្លូវលំ ព្រោះតាមផ្លូវធំច្រើនមានឡានទាហានបើកល្បឿនយ៉ាងសាហាវ ជួនកាលមានទាហានដើរទាំងក្រុមៗទៀតផង ។ តាមផ្លូវលំអមផ្លូវទេពផន ខ្ញុំនិងប្តីខ្ញុំជិះកង់ឌុបគ្នារហូតដល់ផ្ទះនៅជិតអាងចិញ្ចឹមក្រពើ ។ ពេលទៅដល់ម្តុំនោះស្ងាត់ឈឹងក្រោមកម្តៅថ្ងៃក្តៅហែងនៃរដូវខែចេត្រ ។ យូរៗម្តងខ្ញុំឮសូរសំឡេងគ្រាប់ផ្ទុះ ក្ងាំងៗ! ធ្វើឲ្យខ្ញុំកាន់តែភ័យព្រួយ ស្នូរគ្រាប់កាំភ្លើងដៃឮរបេះរប៉ោះម្តងនៅឆ្ងាយម្តងហាក់ដូចនៅជិតបង្កើយ ។ មិនបង្អង់យូរ ខ្ញុំរត់ឡើងលើផ្ទះប្រញាប់ប្រញាប់ប្រមូលបានខោអាវញាត់ដាក់បានមួយស្បោង អង្ករជាងកន្ទះបាវនិងផ្សៀតត្រីប្រាបានពីរកន្ទុយធំៗដែលម្តាយខ្ញុំបានផ្ញើពីខេត្តតាកែវ ។ រៀបចំរួចខ្ញុំក៏អូសស្បោងខោអាវចុះមកក្រោម ពេលនោះស្រាប់តែគ្រាប់កាំភ្លើងមួយគ្រាប់ហើរ វឺវ! ប៉ប្រះត្រចៀកប្តីខ្ញុំ គាត់ក៏ស្រែកប្រាប់ថា «ទៅ! ទៅវិញឲ្យលឿន នៅមិនបានទេ ច្បាស់ជាត្រូវគេបាញ់ស្លាប់មិនខាន» ។ ឮដូច្នេះខ្ញុំក៏ប្រញាប់ប្រញាប់ជួយចងស្បោងខោអាវនិងអង្ករដាក់លើកង់បណ្តើរចេញទៅដោយអាឡោះអាល័យផ្ទះដែលនៅតែឯងស្ងាត់ជ្រងំ ។ ឆ្លៀតឱកាសនោះ ខ្ញុំបានបេះផ្លែនោងនៅទ្រើងខាងមុខផ្ទះ៤-៥ផ្លែដាក់តាមទុកស្ងោរហូប ។ ខ្ញុំបណ្តើរកង់រត់ប្រញាប់ប្រញាប់ចូលតាមផ្លូវលំតូចៗបាំងដើមឈើ ដើម្បីឲ្យគេចផុតពីភ្នែកទាហានដែលបាញ់ រហូតដល់ខ្ញុំបានមកដល់ផ្ទះបងជីដូនមួយខ្ញុំនៅផ្សារដេប៉ូវិញ ។

ត្រឡប់មកដល់ផ្ទះពេលក្រោយហូបបាយរួច តាមផ្ទះនីមួយៗកាន់តែស្ងាត់ទៅៗ ឃើញតែឡានទាហាន និងទាហានដើរតាមផ្លូវ ។ ទាហានទាំងនោះស្លៀកពាក់ខ្មៅ បង់កកន្សែងសខ្លះមួរជើងខោ ។ ប្រជាជនអើតពីក្នុងផ្ទះទៅនឹកក្នុងចិត្តថានេះប្រហែលជាទាហានរំដោះកន្សែងសហើយមើលទៅ ។ ប្រហែលម៉ោង១រសៀល រថយន្តដឹកទាហានពេញប្រៀបស្លៀកពាក់ខ្មៅ បង់កកន្សែងស លើកទង់ជ័យសស្រែកជយឃោស ។ ពេលនោះប្រជាជនតាមផ្ទះនាំគ្នាចេញមកព្រោងព្រាតមុខផ្ទះខ្លះជួយស្រែកអបអរសាទរនឹងជ័យជម្នះរបស់ទាហានរំដោះទាំងនេះរហូតមានអ្នកខ្លះរត់ទៅរកក្រណាត់សចងជាមួយឈើដើម្បីលើកគ្រវីអបអរសាទរនឹងគេ ។ អ្នកជិតខាងនិងបងប្អូនខ្ញុំនៅផ្ទះនាំគ្នានិយាយថា «យើងត្រូវអបអរនឹងគេ ទទួលគេទៅស្រុកយើងសាន្តត្រាណហើយពីថ្ងៃនេះទៅ» ។ ប្រជាជនម្នាក់ៗសប្បាយ

រីករាយដោយនឹកថាប្រទេសជាតិនឹងបានសុខសន្តិភាពលែងមានការបាញ់ផ្លោងចូលរាល់ថ្ងៃទៀតហើយ ។

សភាពអ៊ូរអររអម្បាញ់មិញក៏ស្ងាត់បាត់ទៅក្រោយពេលឡានទ័ពទាំងនោះលែងបើកតាមផ្លូវទៀត ។ ភាពស្ងាត់ជ្រងំក៏កើតមានឡើងជាថ្មីទៀត យូរៗឃើញទាហាន២-៣នាក់ ដើរអើតតាមមុខផ្ទះ ទាហានទាំងនោះក្មេងៗពាក់មួកកន្ទបចិន មូរដៃអាវជើងខោ ពាក់ស្បែកជើងកង់ឡាន ស្ពាយកាំភ្លើងមានគ្រាប់បែក ១ឬ២គ្រាប់ចងនៅចង្កេះ និងមានស្ពាយថង់អង្ករពាក់ឆៀងខ្លួន ។ ពេលឃើញទាហានទាំងនេះបងខ្ញុំនិយាយថា«អាណិតណាស់! សុទ្ធតែក្មេងៗមកធ្វើទាហានរំដោះគ្នាមិនដឹង នឿយហត់អត់ឃ្លានយ៉ាងណាទេ មិនដឹងដើរតាំងពីណាមកទេនេះ» ។ កំពុងតែនិយាយ ស្រាប់តែមានស៊ីក្លូមួយដឹកអ្នករបួសកាត់មុខផ្ទះ បងខ្ញុំឃើញក៏ស្រែកសួរអ្នកធាក់ស៊ីក្លូ ឆ្លើយថា«ត្រូវគ្រាប់ផ្លោងដឹកទៅពេទ្យសូវៀត» ។ ខ្ញុំមើលព្រឹត្តិការណ៍ថ្ងៃនោះទាំងទុក្ខព្រួយនិងភ័យខ្លាច ព្រោះខ្ញុំមិនដែលប្រទះសភាពបែបនេះសោះ មានអ្នករបួសស្រស់ៗ មានទាហានស្ពាយកាំភ្លើងគួរឲ្យខ្លាចតាមផ្លូវស្ងាត់ឈឹង តើថ្ងៃស្អែកនឹងទៅជាយ៉ាងណាទៀត? ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ មើលតែមុខគ្នាឡិងឡង់ៗ មិនដឹងនិយាយអ្វី ឬធ្វើដូចម្តេចទៀត គឺមានតែការទន្ទឹងរង់ចាំមើលតទៅទៀតប៉ុណ្ណោះ ។ មួយសន្ទុះក្រោយមក ស្រាប់តែមានទាហាន២-៣នាក់ដើរសំដៅមកផ្ទះខ្ញុំ ពេលនោះបងថ្លៃខ្ញុំកំពុងលាងឡានឡាំប្រឺតា ។ ទាហាននោះដើរមកហើយសួរថា «នរណាម្ចាស់ឡាំប្រឺតាហ្នឹង?» ។ បងខ្ញុំក៏ឆ្លើយថា«បាទ!ខ្ញុំបង ហើយទាហាននោះក៏បញ្ជាឲ្យបង ខ្ញុំយកកូនសោរឡានឲ្យទៅវាដោយពោលថា «សុំខ្ចីឡានបើកធ្វើការសិន បន្តិចទៀតយកមកឲ្យវិញ» ។ បងខ្ញុំជាមនុស្សរឹងត្អឹង (គាត់ធ្វើប៉េអឹម) គាត់ឆ្លើយថា «ទេ! មិនឲ្យទេ! ចេះខ្ចីឡានគេបើកស្រួលៗម៉េចអីចេះ» ។ ទាហាននោះក៏ដំឡើងសំឡេងខ្លាំងៗថា «ឲ្យឬមិនឲ្យ? បន្តិចទៀតគ្មានឡាន គ្មានម៉ូតូ គ្មានផ្ទះអីទេ មិត្តឯងជារបស់អង្គការទាំងអស់ហ្នឹង» ។ ឃើញដូច្នេះឪពុកក្មេកខ្ញុំគាត់ក៏អូសដៃបងខ្ញុំចេញ ព្រោះខ្លាចមានរឿងមិនល្អ រួចក៏ហុចសោរឡានឲ្យទៅទាហាននោះទៅ ។ ពេលបើកឡានចេញ ទាហានម្នាក់នោះរេទីយ៉ាងខ្លាំងចេញផ្សែងខ្មៅហុយទ្រប បងខ្ញុំនិយាយថា «នេះបែបមិនចេះបើកទេមើលទៅ» គាត់ពោលនឹកស្តាយឡានគាត់ ។




ម៉ោងប្រហែល២រសៀល ពេលដែលក្រុមគ្រួសារខ្ញុំនាំគ្នាអង្គុយជុំគ្នាក្នុងផ្ទះស្រាប់តែមានទាហាន២នាក់មកគោះទ្វារឲ្យបើក ។ ពេលបើកទ្វារឡើង បងខ្ញុំសួរថា «បងមានការអីដែរ?» ទាហាននោះឆ្លើយថា «សូមឲ្យបងប្អូនទាំងអស់គ្រប់ផ្ទះរៀបចំខ្លួនចេញពីទីក្រុងរយៈពេលបីថ្ងៃ ដើម្បីរៀបចំក្រុងឡើងវិញ ។ មិនបាច់យកស្អីទៅច្រើនទេ ទៅតែ២-៣ថ្ងៃប៉ុណ្ណឹងមកវិញហើយ ។» ឮដូច្នេះម្នាក់ៗ ពិបាកចិត្ត

ភ័យព្រួយមិនដឹងគិតដូចម្ដេច ចោទសួរគ្នាថា ទៅបីថ្ងៃឲ្យចេញទៅណា? ទៅដេកនៅឯណាទៅ? បានអីហូប?។ គ្រួសារជិតខាងចាំមើលគ្នាទៅវិញទៅមក មិនហ៊ានចេញឡើយ ចាំមើលគេឯងដែរ។

មិនយូរប៉ុន្មាន មានឡានទាហានស្លៀកពាក់ខ្មៅបើកប្រកាសតាមផ្លូវបញ្ជាឲ្យប្រជាជនទាំងអស់ចាកចេញពីទីក្រុងចម្ងាយ១០គីឡូម៉ែត្រក្នុងរយៈពេល៣ថ្ងៃ ដើម្បីរៀបចំក្រុងឡើងវិញ។ ផុតពីការស្រែកឃោសនានេះក៏ឃើញមនុស្សម្នាជាច្រើនចេញដំណើរមកពីថ្នល់ខាងលិចមក។ បងថ្លៃខ្ញុំមិនអស់ចិត្តរត់ទៅសួរថា «បងៗ! ចេញទៅណាហ្នឹង?» អ្នកទាំងនោះតបថា «គេដេញឲ្យចេញពីផ្ទះបីថ្ងៃ នរណាមិនទៅមិនបានទេ គេបាញ់ចោលនៅមុខៗហ្នឹង ខ្ញុំឃើញហើយកុំនៅ ទៅនឹងគេទៅចេះតែទៅតាមគេទៅ»។ ពុដូច្នេះគ្រួសារខ្ញុំក៏រៀបចំចេញដំណើរនឹងគេ។ ពេលនោះខ្ញុំភ័យ ខ្ញុំយំ ព្រួយបារម្ភត្រូវបែកពីឪពុកម្ដាយ គិតថាគាត់មករកខ្ញុំមិនឃើញទេ ព្រោះចេញទៅមិនដឹងទៅណា ហើយនឹកបងដែលនៅគីឡូម៉ែត្រលេខ៤ មិនដឹងជាគ្រួសារគាត់យ៉ាងម៉េចដែរទេ កូនក្មួយតូចៗតើចេញទៅដើរយ៉ាងណា នឹកឃើញភាពវេទនាតាមផ្លូវធ្វើឲ្យខ្ញុំយំៗរហូតរៀបចំបណ្ដើរ យំបណ្ដើរ នឹកម្ដងៗខ្ញុំចង់តែទៅរកបងស្រីខ្ញុំវិញទេ ព្រោះខ្ញុំស្ថិតនៅជាមួយគ្រួសារខាងប្ដីទាំងអស់។ ពេលហ្នឹងខ្ញុំនឹកបងស្រីខ្ញុំណាស់ នឹកឪពុកម្ដាយខ្ញុំនៅខេត្តតាកែវមិនដឹងគាត់សុខទុក្ខយ៉ាងណាពេលនេះបែកគ្នាអស់ហើយមិនដឹងទៅណាខ្លះទេ។ នៅលើផ្លូវប្រជាជនកាន់តែច្រើនឡើងៗ បណ្ដើរកូនចៅមានស្ពាយបង្វិចខោអាវ ខ្លះរែក ខ្លះទូល អ្នកខ្លះយំទ្រហឹងពេញផ្លូវព្រោះបែកបងប្អូនឪពុកម្ដាយ គ្រួសារខ្លះដាក់មនុស្សចាស់លើស៊ីក្លូដោយមានកូនចៅជួយរុញពីក្រោយ។ ខ្ញុំស្ពាយបាឡូខោអាវនិងសម្ភារសំខាន់មានថ្នាំពេទ្យខ្លះៗ ប្ដីខ្ញុំបណ្ដើរម៉ូតូដាក់ស្បោងខោអាវពីមុខដាក់អង្ករពីក្រោយ។ ម្នាក់ៗដើរចេញទៅទាំងទឹកមុខស្រងូតស្រងាត់ ទឹកភ្នែកអាឡោះអាល័យផ្ទះដែលធ្លាប់រស់នៅសុខសាន្តរាល់ថ្ងៃ។ នៅតាមផ្លូវចង្អៀតពេញទៅដោយអ្នកដំណើណែនណាន់តាន់តាប់ ទោះបីមានឡានឬម៉ូតូក៏មិនអាចបើកបានដែរ ព្រោះចង្អៀតគ្មានផ្លូវបើក គឺបានត្រឹមតែដើរមួយៗតាមពីក្រោយគ្នាប៉ុណ្ណោះ។ ប្រជាជននៅក្នុងទីក្រុងទាំងមូលត្រូវតែចាកចេញពីលំនៅស្ថានរបស់ខ្លួនទៅក្រៅក្រុងរយៈពេល៣ថ្ងៃតាមបញ្ជារបស់ទាហានរំដោះ។ យូរៗម្ដងឃើញទាហាននារីនៅតាមផ្លូវស្លៀកពាក់ខ្មៅ ទាហានប្រុសដើរទាត់អម្បែងដបទឹកក្រូចលេង ខ្លះដឹកទឹកក្រូចអស់បោកដបបែកខ្ចាយ។ ឃើញសភាពច្រងេងច្រងាងនៃទាហានទាំងនេះធ្វើឲ្យម្នាក់ៗកាន់តែភ័យញ័រថែមទៀត ខ្លាចនឹងភាពកាចសាហាវរបស់ទាហានទាំងនេះ។ ទីក្រុងពេលនោះក្លាយជាអ៊ូអរដោយហ្វូងមនុស្សស្រែកយំ ហ្វូងសត្វដែលប្រជាជនដឹកយកទៅតាមមានឆ្កែ ជ្រូកជាដើម កូនក្មេងយំក្ដៅ ខ្លះស្រេកទឹក ខ្លះយំឃ្លាន។ នៅលើផ្លូវឃើញទាហានខោអាវខ្មៅដើរទាត់ខ្នើយ ពូក ធាក់ទម្លាយចេញគហុយទ្រលោមពេញវាល។ ខ្ញុំដើរចេញពីផ្សារដេប៉ូចាក់ត្រង់មកស្ទឹងមានជ័យ រហូតដល់គល់ស្ពានផ្លូវបំបែកជិតពេទ្យសូវៀត ឃើញមានប្រជាជនរុញគ្រែអ្នកជំងឺកំពុងព្យួរសេរ៉ូមនៅដៃ ខ្លះវះកាត់មិនទាន់រួចស្រួលបួលផងក៏ចេញមកទាំងរបួសមិនទាន់ដេរ មានឈាមជិតជាមពេញក្រណាត់សដែលគ្របពីលើ មើលទៅគួរឲ្យរន្ធត់ចិត្តពន់ពេក។ ដើរហួសស្ពានស្ទឹងមានជ័យបន្តិច ខ្ញុំបានជួបប្រទះស្រស់ៗនូវខ្មោចទាហានដេកស្លាប់ដោយត្រូវគ្រាប់នៅលើផ្លូវ ឈាមហូរចេញពីគល់ករីមៗដេកស្ដូកស្ដឹងនៅលើផ្លូវក្នុងសម្លៀកបំពាក់ជាទាហាន លន់ ណុល ពាក់អាវពណ៌កាគីអាចម៍សេះ។ ទាហាន៣នាក់ដេកស្លាប់លើផ្លូវឃ្លាតពីគ្នាបន្តិចៗ ឡើងហើមស្ពឹងមិនដឹងស្លាប់តាំងពីពេលណា។ ខ្ញុំភ័យស្លុតត្រជាក់ដៃជើងអស់ហើយពេលដើរកាត់ខ្មោចស្រស់ៗយ៉ាងនេះ។ ខ្ញុំមិនដែលឃើញទេតាំងពីក្មេងរហូតមកដល់ធំប៉ុណ្ណេះ ទើបតែម្ដងនេះក្នុងព្រឹត្តិការណ៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញអស់ហើយទិដ្ឋភាពរន្ធត់ៗគ្រប់បែបយ៉ាងដូចជា ដើររំលងខ្មោច ឃើញមនុស្សស្លាប់ស្រស់ៗតាមផ្លូវ អ្នកជំងឺដែលត្រូវបណ្ដេញចេញពីមន្ទីរពេទ្យទាំងអស់។ ដើរបានមួយល្ងាចជិតយប់ទើបមកដល់រោងចក្រកែវនៅឆ្ងាយពីទីក្រុងជាង១០គីឡូម៉ែត្រ។ យប់នោះទាំងអស់គ្នាជាច្រើនរយគ្រួសារបានឈប់សម្រាកដាំបាយហូប។ សភាពរោងចក្រកែវពេលនេះប្រៀបដូចជាជំរំមួយដែលប្រមូលផ្ដុំមនុស្សរាប់រយនាក់។

*សំឡេងអ៊ូអរក្មេងយំទ្រហឹង ខ្លះយំស្រែកបាត់កូនដើរវង្វេងគ្នាមិនដឹងបាត់នៅត្រង់ណា ព្រោះមនុស្សច្រើនពេក ខ្លះកូនឈឺយំពេញទីនោះ ។ ពេលនោះខ្ញុំយកអង្ករទៅដាំបាយ បង្កាត់ភ្លើងទាំងអារម្មណ៍ព្រួយពន់ពេកនឹងសភាពបែបទាំងនេះ ព្រោះគ្រួសារខ្លះត្រូវគេបណ្តេញចេញមកតែខ្លួន គ្មានបានយកអ្វីមកទាំងអស់ សូម្បីតែអង្ករក៏គ្មានហូបដែរ ទោះបីជាដើរសុំទិញគេគ្មាននរណាលក់ឲ្យឡើយ ។ អ្នកភូមិនៅទីនេះមួយចំនួនហាក់ដូចជាស្អប់ខ្មើមអ្នកទីក្រុងណាស់ សូម្បីតែទឹកក៏មិនឲ្យដងដែរ ។ មើលទៅសែនវេទនាណាស់ នេះត្រឹមតែមួយយប់ ចុះទម្រាំប៉ុន្មានថ្ងៃទៅមុខទៀតតើវេទនាប៉ុណ្ណាទៅ? ។ បាយឆ្អិនហើយក៏នាំគ្នាហូបទាំងទឹកភ្នែកអួលណែនស្ទើរលេបបាយមិនចូល ព្រោះត្រូវបែកបាក់ក្រុមគ្រួសារអស់ ។ ខ្ញុំងាកមើលមកក្បែរខ្លួនខ្ញុំមានគ្រួសារចិនម្នាក់ទៅសុំទិញស្រូវបានប្រហែលមួយថ្នក់នាំគ្នាអង្គុយបកគ្រាប់ស្រូវមកដាំបាយហូប ។ មើលទៅសែនវេទនាណាស់ ។*

*យប់នេះម្នាក់ៗដេកស្ងាត់ស្ងៀម ចំណែកខ្ញុំដេកមិនលក់ចេះតែគិតថាប្រហែលមិនទាន់ចប់សង្គ្រាមទេមើលទៅ ។ ជុំវិញខ្លួនខ្ញុំ មនុស្សម្នាជាច្រើនដេកស្ងាត់អស់ហើយ ខ្លះកូនចៅយំប្រហែលឃ្លានឬឈឺអ្វីហើយ ។ យប់នោះខ្ញុំឃើញទាហានស្លៀកពាក់ខ្មៅដើរកាន់ពិលចុចមើលគ្រប់កន្លែងតែមិនដឹងថា គេកំពុងរកអ្វីឡើយ ។*

*ព្រលឹមឡើងនាំគ្នាភ្ញាក់ឡើងដើរសំដៅរកខុសដាំបាយទុកឲ្យហើយ ខ្លាចមានការអើដាំមិនទាន់ ។ ពេលនោះខ្ញុំបានដើរសំដៅទៅអណ្តូងទឹកដើម្បីដងទឹកយកមកដាំបាយហូប ។ នៅពេលទៅដល់ខ្ញុំឃើញមនុស្សឈរនៅជុំវិញអណ្តូងជាច្រើននាក់ ខ្ញុំស្មានតែឈរដងទឹក ។ នៅពេលដែលខ្ញុំទៅជិតឮមាត់ផ្អើលឆោឡោអើតមើលក្នុងអណ្តូងគ្រប់ៗគ្នា ។ ខ្ញុំទៅដល់អើតមើលនឹងគេស្រាប់តែភ្ញាក់ភ័យយ៉ាងខ្លាំង ព្រោះក្នុងអណ្តូងមានខ្មោចមនុស្សឃើញក្បាលអណ្តែតប៉ែលប៉ាលលើទឹក ។ ខ្ញុំក៏រត់មកវិញប្រាប់បងប្អូន នាំគ្នារអើមក្អួតក៏ក្អួតមិនចេញ ព្រោះពីយប់មិញយើងបានដងទឹកពីអណ្តូងនោះមកដាំបាយដាំទឹកហូបថែមទាំងផ្ទុតទៀត ។ បងថ្លៃខ្ញុំនិយាយថា «អីចឹងបានជាយប់មិញខ្ញុំឆ្ងល់អណ្តូងហ្នឹងអីក៏ពិបាកដងទឹកម្ល៉េះ ទម្រាំបានមួយធុងៗជ្រមុជ២–៣ដងទើបលិច មិននឹកស្មានថាមានខ្មោចក្នុងហ្នឹងអីចឹងបានជាពិបាកដងណាស់» ។ ដល់ជួបសភាពបែបនេះយើងក៏នាំគ្នាដើរទៅស្រះអ្នកស្រុកដងទឹកយកមកដាំបាយវិញ ។ ពេលមកដល់ស្រះនោះខ្ញុំឃើញទាហានស្លៀកពាក់ខ្មៅជាច្រើនដើរពីចម្ងាយសំដៅទៅជុំវិមនុស្សនៅ ។ ខ្ញុំដងទឹកបណ្តើរគិតបណ្តើរថាគេទៅណាច្រើនម្ល៉េះ? ពេលទៅដល់ខ្ញុំឃើញទាហានឲ្យប្រជាជនទាំងអស់អង្គុយជុំគ្នា រួចប្រាប់ថា «ហូបបាយហើយចេញពីទីនេះជាប្រញាប់ អ្នកណានៅស្រុកណាទៅស្រុកហ្នឹងទៅ» ។ ពេលឮដូច្នេះម្នាក់ៗឆ្ងល់និងព្រួយបារម្ភយ៉ាងខ្លាំង ពេលនោះមានពូម្នាក់សួរថា «ចុះបង! គេថាឲ្យចេញពីទីក្រុងតែ៣ថ្ងៃទេឲ្យចូលវិញ?» ទាហាននោះឆ្លើយថា «គ្មានចូលវិញទេ! អង្គការបញ្ជាឲ្យចេញពីទីក្រុងទាំងអស់» ។ ក្រោយពេលឮដូច្នេះទាំងគេទាំងខ្ញុំនាំគ្នាដាំបាយហូបរៀបចំចេញដំណើរទៅមុខទៀត ។ គ្រួសារខ្ញុំមានគោលបំណងទៅស្រុកកំណើតប្តីខ្ញុំនៅស្រុកគិរីវង្ស ខេត្តតាកែវ ។ ខ្ញុំគិតក្នុងចិត្តថា បើដល់តាកែវបានជួបឪពុកម្តាយខ្ញុំ ខ្ញុំនឹងនៅជាមួយគាត់នៅទីនោះហើយ មិនទៅស្រុកគិរីវង្សទេ ។*

*បន្ទាប់ពីហូបបាយហើយយើងនាំគ្នាចេញដំណើរទៅមុខទៀត ។ ពេលនោះខ្ញុំបានឃើញមនុស្សមួយខ្សែដើរជាជួរក្នុងសម្លៀកបំពាក់ជាប្រជាជន ខ្លះក៏ពាក់អាវ ខ្លះក៏ដោះអាវ មានទាហានស្លៀកពាក់ខ្មៅដើរពីមុខពីក្រោយ ។ គ្រប់គ្នាឆ្ងល់ណាស់តែមិនហ៊ានសួរ ព្រោះត្រូវដេញបង្ខំឲ្យចេញឲ្យលឿន ។*

*ប្រជាជនខ្មែរទាំងអស់ដែលមានក្រុមគ្រួសារខ្ញុំនៅលាយឡំដែរនោះ ចេះតែបន្តដំណើរពីមួយកន្លែងទៅមួយកន្លែង ។ រាល់ពេលឈប់សម្រាកតែងតែមានទាហានមកដេញឲ្យបន្តដំណើរទៅមុខទៀតមិនឲ្យនៅមួយកន្លែងឡើយ ។ គ្រួសារខ្ញុំនិងប្រជាជនទាំងអស់បានចាកចេញពីទីក្រុងក្នុងសភាពដូច្នេះតាំងពីថ្ងៃ១៧ មេសា ១៩៧៥ រហូតមកដល់គោលដៅស្រុកគិរីវង្សអស់រយៈពេល២១ថ្ងៃ ពោរពេញដោយភាពលំបាកវេទនាសព្វបែបយ៉ាងដែលខ្ញុំមិនដែលជួបប្រទះសោះឡើយក្នុងមួយជីវិត ។*

**លឹម គី**

**◆ យើងបញ្ជោញប្រជាជនឱ្យអស់ និងខ្មាំងឱ្យអស់។**

*(ដកស្រង់ពីឯកសារលេខ កណាហ១៧៩)*

## លិខិតរបស់លោក លី ឡេង អភិបាលរងស្រុកពញាក្រែក ខេត្តកំពង់ចាម សូមគោរពផ្ញើជូនឯកឧត្តម ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ឯកឧត្តមជាទីគោរព ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះអស់ពីដួងចិត្តចំពោះស្នាដៃរបស់ឯកឧត្តមព្រមទាំងសហការី ក្នុងការស្រាវជ្រាវរាល់ឯកសារនិងប្រភពពត៌មានទាំងរូបភាពក៏ដូចជាវត្ថុតាង មកថតបោះពុម្ពផ្សព្វផ្សាយបង្ហាញដល់ប្រជាជនកម្ពុជា ដើម្បីបានឃើញនិងយល់ដឹងនូវអ្វីដែលបានកើតឡើងនៅក្នុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ព្រោះថារូបភាពនិងឯកសារពត៌មានទាំងនេះ កុំថាឡើយយុវជនយុវនារីដែលកើតក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ សូម្បីតែអ្នករស់នៅផ្ទាល់ក្នុងរបបនេះក៏មិនដែលបានដឹងបានឃើញដែរ ។

ឯកឧត្តមជាទីគោរព នៅមុនពេលទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបោះពុម្ពនិងចេញផ្សាយ រូបខ្ញុំតែងមមៃថា រាល់អាថ៌កំបាំងដែលកើតមានឡើងក្នុងរបបខ្មែរក្រហមពិតជាមិនងាយនឹងមាននរណាម្នាក់អាចស្រាវជ្រាវចងក្រងកត់ត្រាទុកបានឡើយ ហើយវានឹងលាក់ខ្លួនគេចមុខចេញពីប្រវត្តិសាស្ត្រ និងបាត់បង់ការជឿជាក់ពីមនុស្សជំនាន់ក្រោយ ថាអំពើនេះពិតជាកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)ទៀតផង តែផ្ទុយទៅវិញ ឯកសារ រូបភាព និងពត៌មានជាច្រើនត្រូវបានទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការស្រាវជ្រាវប្រមូលនិងកត់ត្រាបានយ៉ាងពិស្តារ ហើយថែមទាំងបានបោះពុម្ពផ្សាយជាសាធារណៈនៅទូទាំងប្រទេសថែមទៀត ។

ឯកឧត្តមជាទីគោរព បន្ទាប់ពីទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានធ្វើការចែកផ្សាយរួចមក រូបខ្ញុំក៏មានការដក់ចិត្តដិតអារម្មណ៍ធ្វើការពិនិត្យតាមដានទាំងរូបភាពនិងខ្លឹមសារនៃអត្ថបទស្រាវជ្រាវរបស់ទស្សនាវដ្តីនេះ រហូតដល់មានរូបភាពនិងអត្ថបទខ្លះបានធ្វើឲ្យខ្ញុំមានការអាណោចអធមនិងរន្ធត់ចិត្តហាក់ដូចជារឿងនេះមិនទាន់បានបញ្ចប់និងឃ្លាតឆ្ងាយនៅឡើយនិងបានធ្វើឲ្យរូបខ្ញុំរឹតតែសម្តែងនូវក្តីដឹងគុណទ្វេឡើងថែមទៀតចំពោះអ្នកដែលបានដឹកនាំការសង្គ្រោះអាយុជីវិតនិងរំដោះប្រជាជនកម្ពុជាឲ្យរួចចាកផុតពីអំពើទុក្ខទារុណដ៏សាហាវព្រៃផ្សៃនៃរបបគ្រប់គ្រងដ៏សាហាវយង់ឃ្នងនេះ ។ រាល់រូបភាពនិងឯកសារទាំងនេះបានធ្វើឲ្យខ្ញុំយល់ឃើញថាជាឯកសារដ៏មានតម្លៃសម្រាប់ប្រវត្តិសាស្ត្រជាតិក៏ដូចជាសកលលោក ជាឯកសារដែលចងក្រងឡើងសម្រាប់ជាប្រយោជន៍ដល់សង្គមជាតិកម្ពុជាទាំងក្នុងពេលបច្ចុប្បន្នក៏ដូចជាអនាគត មិនមែនជាឯកសារដែលចងក្រងឡើងសម្រាប់បង្កនូវទំនាស់បាក់បែក ឬបំផុសគំនុំចងអាឃាតនៅក្នុងសង្គមកម្ពុជានោះទេ គឺជាឯកសារមេរៀនដ៏សំខាន់សម្រាប់កូនខ្មែរជំនាន់ក្រោយពិចារណា ។

ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តមនិងសហការី សូមទទួលបានសេចក្តីសុខចម្រើននិងសម្រេចបានដោយជោគជ័យក្នុងភារកិច្ចដ៏ប្រសើរថ្លៃថ្លានេះ ។ **លី ឡេង**

## លិខិតថ្លែងអំណរគុណ

ក្នុងនាមសមាគមនិស្សិតឱសថសាស្ត្រកម្ពុជានិងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណជាអនេកជូនដល់លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយផ្តល់នូវទស្សនាវដ្តី «ស្វែងរកការពិត» ដល់សមាគមយើងខ្ញុំ ។

ជួសមុខឲ្យនិស្សិតឱសថសាស្ត្រកម្ពុជា ខ្ញុំបាទសូមថ្លែងអំណរគុណសាជាថ្មី និងជូនពរសព្វសាធុកាជូនដល់លោកនាយកនិងសហការីទាំងអស់ឲ្យបានជួបប្រទះតែសេចក្តីសុខនិងជ័យជំនះគ្រប់យ៉ាង ដើម្បីស្រាវជ្រាវរកភ័ស្តុតាងទុកជាឯកសារសម្រាប់អ្នកជំនាន់ក្រោយសិក្សានិងសម្រាប់ឈានទៅរកការកាត់ទោសមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យផង ។

សូមលោកនាយកមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០០ អនុប្រធានសមាគម **គី សុផល**

កំណាព្យខ្មែរក្រហម

# មហាចលនាវាយសម្រុកធ្វើស្រែវស្សា

វគ្គវាយសម្រុកស្រែវស្សា
ប្រយុទ្ធខ្លាំងក្លាលឿនបោះពួយ
បានពីដើមដៃពេលមិនឆ្ងាយ
ពូជដីមិនព្រួយត្រៀមកម្លាំង ។

កន្លែងដីល្អធ្វើបានច្រើន
ពង្រីកបង្កើនតាំងពីប្រាំង
ភ្លៀងមានទឹកថែមយើងចាត់តាំង
បែងចែកកម្លាំងខំធ្វើស្រែ ។

យើងមានទំនប់ភ្លឺប្រឡាយ
ម្ចាស់ការដោះស្រាយបានទាន់ខែ
ស្រូវស្រាលកណ្តាលធនហូរហែ
ធ្វើបានគ្រប់ស្រែត្រៀមស្បៀងទៀត ។

ភ្ជួររាស់ដកស្ទូងជាបន្ត
ដំណើរការល្អគ្មានរវាត
ឯកភាពអនុវត្តទិសដាច់ខាត
ធ្វើស្រែឲ្យស្អាតបានអស់ដី ។

ពីខែមេសាមកឥឡូវ
ស្រែប្រែសុទ្ធស្រូវសន្ទូងថ្មី
កើនច្រើនហិកតាដើមថ្លៅសខ្ចី
លាតលយពេញផ្ទៃឆ្ងាយអនេក ។

ស្រូវស្ទូងរួចហើយក្នុងភ្លឺមាំ
ដាក់ដីថែទាំទឹកចាយចែក
បញ្ចេញបញ្ចូលមើលគ្រប់ផ្នែក
បង្ហូររំលែកបានពេញស្រែ ។

កន្លែងទឹកចូលមិនទាន់ស្មើ
រហាត់យើងប្រើបូមជួយដែរ
ធ្វើគ្រប់លទ្ធភាពរាល់ថ្ងៃខែ
ត្រៀមជាប់ហូរហែយប់ល្ងាចព្រឹក ។

ទំនប់ប្រឡាយភ្លឺទាំងអស់
មិនឲ្យបាត់ប្រោះធ្លាយចោលទឹក
នៅជាប់ស្រូវល្អបែកគុម្ពញឹក
ល្អប្លែកសន្ធឹកស្មើគ្រប់មុខ ។

ការងារភ្ជួររាស់ដេញស្ទូងថៃ
តជាប់ជាខ្សែពេញបន្ទុក
កម្លាំងស្រួចធំប្រមូលបុក
ដើម្បីសម្រុកបញ្ចប់វគ្គ ។

មកដល់ពេលនេះជិតចុងដៃ
ទឹកដោតដាំដីពេលខ្វីកៀក
សម្រុកឲ្យហើយស្រែជ្រោរាក់
តាមសភាពជាក់ស្តែងទូទៅ ។

ការដ្ឋានធ្វើស្រែគ្រប់ទាំងអស់
គ្មានសល់ចន្លោះស្ទុះលឿនស្មោ
មុខព្រួញសម្រុកខ្លាំងសន្ធៅ
ដាក់ទិសសំដៅខ្លាំងប្រយុទ្ធ ។

សហករណ៍ប្តេជ្ញាបង្កើនផល
ឲ្យបានកើនសល់ច្រើនបំផុត
ដើម្បីការពារកសាងរដ្ឋ
ឲ្យលឿនលោតផ្លោះមហាអស្ចារ្យ ។

**កត់ត្រាចងក្រងខាងឯកសារ**
**កញ្ញា សើ សាយ្យាណា**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 10, October 2000
Funded by the Royal Ministry of Foreign Affairs of Norway, Section for the Human Rights and Humanitarian Assistance, Department for Global Issues; the Canada Funds, Canadian Embassy, Phnom Penh; and the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh. *Supported by the Royal Netherlands Government, The Hague, The Netherlands.*